វិទ្យាស្ថានបណ្តុះបណ្តាល និង
ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# វិនិយោគបរទេស
# ក្នុងវិស័យកសិកម្មនៅកម្ពុជា






សាំង ច័ន្ទហង្ស, ហែម សុជិត្រ និង អ៊ូច ចាន់តារានី
រួមទាំង ផាន់ ដាលីស និង ប៉ុន ដូរីណា

ឯកសារពិភាក្សាលេខ ៦០

ខែធ្នូ ឆ្នាំ២០១២

ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI

# វិនិយោគបរទេសក្នុងវិស័យ
# កសិកម្មនៅកម្ពុជា

ឯកសារពិភាក្សាលេខ ៦០

**សាំង ច័ន្ទហង្ស, ហែម សុចិត្រ** និង **អ៊ុច ចាន់តារានី**
រួមទាំង **ផាន់ ដាលីស** និង **ប៉ុន ដូរីណា**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

**អង្គការស្បៀងអាហារ និងកសិកម្ម នៃអង្គការសហប្រជាជាតិ**

**ខែធ្នូ ឆ្នាំ២០១២**

**បេសកកម្ម CDRI**

ក្នុងលក្ខណៈជា វិទ្យាស្ថានកម្ពុជាឯករាជ្យផ្នែកស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ វបសអ មានបេសកកម្មរួមចំណែកដល់ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព។

វបសអ ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា។

**© រក្សាសិទ្ធិឆ្នាំ២០១៣ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)**

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ដែលអាចយកទៅចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង...។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី CDRI ឡើយ។

**ISBN-10: 99950–52–58-4**

**វិនិយោគបរទេសក្នុងវិស័យកសិកម្មនៅកម្ពុជា**

( Foreign Investment in Agriculture in Cambbodia)

សាំង ច័ន្ទហង្ស, ហែម សុចិត្រ និង អ៊ូច ដារានី រួមទាំង ផាន់ ដាលីស និង ប៉ុន ដូរីណា

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់ វបសអ ទេ។*

**វិទ្យាស្ថាន CDRI**

អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខ័ណ្ឌទួលគោក

ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

ទូរស័ព្ទ៖ (៨៥៥ ២៣) ៨៨១ ៣៨៤, ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣

ទូរសារ៖ (៨៥៥ ២៣) ៨៨០ ៧៣៤; អ៊ីមែល៖ cdri@cdri.org.kh; http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ នន សុខចំរើន, អ៊ុំ ចាន់ថា និង យូ-សិទ្ធីរិទ្ធ

បកប្រែដោយ៖ ខេង សេង

បោះពុម្ពនៅប្រទេសកម្ពុជាដោយ រោងពុម្ព ធី & អេស រាជធានីភ្នំពេញ

# មាតិកា


បញ្ជីរូបភាព ........ v

បញ្ជីតារាង ........ v

តារាងឧបសម្ព័ន្ធ ........ v

បញ្ជីអក្សរកាត់ ........ vi

សេចក្តីថ្លែងអំណរគុណ ........ vii

ខ្លឹមសារសង្ខេប ........ viii

**១. សេចក្តីផ្តើម** ........ 1

១.១. គោលដៅនៃការសិក្សា ........ 1

១.២. វិធីសាស្ត្រ ........ 2

១.៣. វិសាលភាព និងកំហិតនានា ........ 3

**២. តួនាទីកសិកម្មក្នុងសេដ្ឋកិច្ចជាតិ** ........ 4

២.១. ការរួមចំណែករបស់កសិកម្មនៅក្នុងផលិតផលជាតិ ........ 4

២.២. ផលិតកម្ម និងតំបន់ប្រមូលផល ........ 5

២.៣. ចំណូលរូបិយប័ណ្ណ ........ 8

២.៤. ការប្រៀបធៀបក្នុងតំបន់: ឱកាសល្អ និងបញ្ហាប្រឈម ........ 9

**៣. ទំហំ និងលក្ខណៈនៃវិនិយោគបរទេសក្នុងវិស័យកសិកម្មនៅកម្ពុជា** ........ 12

៣.១. វិនិយោគទទួលការអនុម័ត គិតតាមវិស័យ ........ 12

៣.២. FDI ក្នុងកសិកម្ម បែងចែកតាមសញ្ជាតិ ........ 15

៣.៣. វិនិយោគក្នុងកសិកម្ម បែងចែកតាមអនុវិស័យ ........ 15

៣.៤. FDI ផ្នែកកែច្នៃស្បៀងអាហារ ........ 18

៣.៥. ការចូលរួមរបស់វិនិយោគិនបរទេសក្នុង ELCs ........ 19

៣.៦. របាំងរារាំង FDI នៅកម្ពុជា ........ 22

**៤. គោលនយោបាយវិនិយោគ និងបទបញ្ញាច្បាប់តាមអនុវិស័យនៅកម្ពុជា** ........ 24

៤.១. ជលផល ........ 25

៤.២. ព្រៃឈើ ........ 26

៤.៣. សត្វចិញ្ចឹម ........ 27

៤.៤. ធនធានទឹក និងបច្ចេកវិទ្យា ........ 27

៤.៥. ដីសម្បទានសេដ្ឋកិច្ច និង ផលិតកម្មបែបពាណិជ្ជកម្ម ........ 28

៤.៦. ស្រូវ ........ 29

៤.៧. កៅស៊ូ ........ 30

**៥. ការវាយតម្លៃជាដំបូងៗពីផលប៉ះពាល់នៃវិនិយោគផ្ទាល់ពីបរទេសទៅលើវិស័យកសិកម្ម** ........ 31

៥.១ ដំណាំ ........ 33

*៥.១.១ ចំការអំពៅនៅខេត្តកោះកុង* ........ *33*

*៥.១.២ ចំការកៅស៊ូក្នុងខេត្តមណ្ឌលគិរី និង កំពង់ធំ* ........ *34*

*៥.១.៣. ចំការពោតនៅខេត្តកំពង់ស្ពឺ* ........ *37*

៥.២. ព្រៃឈើនៅខេត្តក្រចេះ 38
៥.៣. ការវាយតម្លៃជារួម 40

**៦. សេចក្តីសន្និដ្ឋាន** 41

**៧. អនុសាសន៍ខាងគោលនយោបាយ** 43
៧.១. រដ្ឋាភិបាលមជ្ឈឹម និងមូលដ្ឋាន 43
៧.២. ក្រុមហ៊ុនឯកជន 44
៧.៣. សហគមន៍រងការប៉ះពាល់ 44
៧.៤. អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល 44

**ឯកសារយោង** 45

**ឧបសម្ព័ន្ធ ១៖** តារាងបន្ថែម 47

**ឧបសម្ព័ន្ធ ២៖** បញ្ជីសំណួរដើម្បីពិនិត្យពីឧបសគ្គផ្សេងៗដល់វិនិយោគបរទេសខាងកសិកម្ម និងយន្តការសម្រាប់កាត់ បន្ថយ ឬ បំបាត់ឧបសគ្គ 59

**បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន** CDRI 63

## បញ្ជីរូបភាព


រូបភាព ១៖ ក្របខ័ណ្ឌវិភាគសម្រាប់ការវិភាគពី FDI ក្នុងកសិកម្ម ..... 2
រូបភាព ២៖ ផ្ទៃដីដាំដុះ និងផលិតកម្មស្រូវ ពីឆ្នាំ២០០៤-០៩ ..... 6
រូបភាព ៣៖ ផលិតកម្មដំណាំចម្បងៗ ពីឆ្នាំ២០០២-០៩ (ពាន់តោន) ..... 6
រូបភាព ៤៖ ចំការកៅស៊ូ ផលិតកម្ម និងថ្លៃ ពីឆ្នាំ២០០៤-១០ ..... 7
រូបភាព ៥៖ ផលិតកម្មសត្វចិញ្ចឹម ឆ្នាំ២០០២-០៩ (ពាន់ក្បាល) ..... 7
រូបភាព ៦៖ ផលិតកម្មត្រី ឆ្នាំ២០០២-០៩ (ពាន់តោន) ..... 8
រូបភាព ៧៖ ទិន្នផលស្រូវ ឆ្នាំ២០០០-០៩ (តោន/ហិកតា) ..... 10
រូបភាព ៨៖ ទិន្នផលផលិតផលកសិកម្មសំខាន់ៗមួយចំនួន ឆ្នាំ២០០៩ (តោន/ហិកតា) ..... 10
រូបភាព ៩៖ ចំណែកនៃវិនិយោគបានអនុម័ត គិតតាមវិស័យ ឆ្នាំ២០០០ ដល់ មិថុនា ២០១០ (លានដុល្លារ) ..... 14
រូបភាព ១០៖ ចំណែកនៃវិនិយោគបានអនុម័ត គិតតាមវិស័យ ឆ្នាំ២០០០ ដល់ មិថុនា ២០១០ ..... 14


## បញ្ជីតារាង


តារាង ១៖ ចំណែកនៃផលិតកម្មកសិកម្មនៅក្នុងផលិតផលជាតិ ឆ្នាំ២០០២-២០០៩ ..... 4
តារាង ២៖ ទំនិញនាំចេញកសិកម្មចម្បងៗរបស់កម្ពុជា ឆ្នាំ២០០២-០៩ (លានដុល្លារ) ..... 9
តារាង ៣៖ ឧបសគ្គទំនងកើតមានដល់ការអភិវឌ្ឍកសិកម្មនៅកម្ពុជា ..... 11
តារាង ៤៖ វិនិយោគអនុម័តដោយ CIB ឆ្នាំ២០០០-១០ (គិតជាទ្រព្យជាប់លាប់ ជាលានដុល្លារ) ..... 13
តារាង ៥៖ វិនិយោគខាងកសិកម្មអនុម័តដោយ CIB ឆ្នាំ២០០០-១០ (ជាលានដុល្លារនៃទ្រព្យជាប់លាប់) ..... 16
តារាង ៦៖ វិនិយោគបង្គរទុកតាមអនុវិស័យកសិកម្មពីឆ្នាំ២០០០ ដល់ មិថុនា ២០១០ (លានដុល្លារនៃទ្រព្យ ជាប់លាប់) ..... 17
តារាង ៧៖ វិនិយោគជាទ្រព្យជាប់លាប់ក្នុងការកែច្នៃស្បៀងអាហារ ឆ្នាំ២០០០ ដល់ មិថុនា ២០១០ ..... 19
តារាង ៨៖ ELCs បានអនុម័ត និងបានលុបចេញ ឆ្នាំ១៩៩៥-២០០៩ ..... 20
តារាង ៩៖ របាយ ELCs បែងចែកតាមសញ្ជាតិ ឆ្នាំ១៩៩៥-២០០៩ ..... 21
តារាង ១០៖ សង្ខេបពីការចុះសិក្សាដល់កន្លែង អនុវត្តដោយ CDRI និង សមាគមសេដ្ឋកិច្ចកម្ពុជា (CEA) ក្នុងឆ្នាំ២០១០ ..... 32
តារាង ១១៖ លក្ខណៈនៃ ELCs នៅឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ ..... 39
តារាង ១២៖ កំណើនផ្ទៃដីដាំស្រូវ និងទំហំដី ELC ឆ្នាំ២០០៤-២០០៩ ..... 40


## តារាងឧបសម្ព័ន្ធ


តារាង ក ១៖ បញ្ជីលំអិតពី ELCs ទទួលបានពី MAFF ១៩៩៥-២០០៩ ..... 47
តារាង ក ២៖ ទំហំដី ELC និងគម្រោងថ្នាក់ជាតិ និងថ្នាក់ខេត្ត ១៩៩៥- ២០០៩ ..... 51
តារាង ក ៣៖ បញ្ជីឈ្មោះក្រុមហ៊ុនក្នុងវិស័យកសិកម្ម និងការកែច្នៃអាហារ ២០០០-មិថុនា ១០ ..... 52
តារាង ក ៤៖ បញ្ជីទំនាក់ទំនងក្រុមហ៊ុនដើម្បីសំភាសន៍ ខែ វិច្ឆកា ២០១០ ..... 58

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី ( Asian Development Bank) |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( Council for the Development of Cambodia) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ( Cambodia Development Resource Institute) |
| CEA | សមាគមន៍សេដ្ឋកិច្ចកម្ពុជា ( Cambodia Economic Association) |
| CIB | ក្រុមប្រឹក្សាវិនិយោគកម្ពុជា ( Cambodia Investment Board) |
| ELC | សម្បទានដីសេដ្ឋកិច្ច ( Economic Land Concession) |
| FAO | អង្គការស្បៀងអាហារ និងកសិកម្ម ( Food and Agriculture Organisation) |
| FDI | វិនិយោគផ្ទាល់បរទេស ( Foreign Direct Investment) |
| FGD | ការពិភាក្សាក្រុមស្នូល ( Focus Group Discussion) |
| GTC | ក្រុមហ៊ុនពាណិជ្ជកម្មបៃតង (Green Trade Company) |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Ministry of Agriculture, Forestry and Fisheries) |
| MoE | ក្រសួងបរិស្ថាន (Ministry of Environment) |
| MoP | ក្រសួងផែនការ (Ministry of Planning) |
| MoWRaM | ក្រសួងធនធានទឹក និងឧត្តុនិយម (Ministry of Water Resources and Meteorology) |
| NGO | អង្គការមិនមែនរដ្ឋាភិបាល (Non-governmental Organisation) |
| NSDP | ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (National Strategic Development Plan) |
| SLC | សម្បទានដីសង្គមកិច្ច (Social Land Concession) |

# សេចក្ដីថ្លែងអំណរគុណ

ក្រុមអ្នកនិពន្ធសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) ដែលបានផ្ដល់ជំនួយគាំទ្រហិរញ្ញវត្ថុ តាមរយៈ គម្រោងផ្ដល់មូលនិធិដោយជប៉ុន ឈ្មោះថា "ជំនួយគាំទ្រដល់ការសិក្សាពីវិធានការគោលនយោបាយសមស្របសម្រាប់បង្កើនវិនិយោគខាងកសិកម្ម និងជំរុញផលិតកម្មស្បៀង" (GCP/GLO/267/JPN) ដែលបានញ៉ាំងឲ្យការសិក្សានេះអាចប្រព្រឹត្តទៅបាន។ យើងខ្ញុំក៏សូមអរគុណយ៉ាងជ្រាលជ្រៅដល់ សហសេវិកនានានៅ វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ក៏ដូចជាបុគ្គល និងស្ថាប័នជាច្រើនទៀត ចំពោះការជួយសហការ និងសន្ទុះចិត្តគាំទ្រដល់ការសិក្សានេះ។ យើងខ្ញុំសូមអរគុណជាពន្លឹកដល់ លោក Saifullah Syed លោក Pascal Liu និងលោក Masahiro Miyazako នៃអង្គការ FAO ដែលបានជួយផ្ដល់យោបល់ក្នុងរយៈពេលទាំងមូលនៃការស្រាវជ្រាវ។ យើងខ្ញុំសូមអរគុណជាអនេកដល់ លោក យុន កក្កដា នាយករងនៃនាយកដ្ឋានអភិវឌ្ឍន៍ដំណាំកៅស៊ូ នៃ អគ្គនាយកដ្ឋានចំការកៅស៊ូ និង សហគមន៍នៅតាមមូលដ្ឋាន ដែលបានចែករំលែកចំណេះដឹងជួយឲ្យយើងខ្ញុំអាចយល់ដឹងស៊ីជម្រៅពី បញ្ហាផ្សេងៗពាក់ព័ន្ធដល់សម្បទានដីសេដ្ឋកិច្ច។

ក្រុមអ្នកនិពន្ធសូមអរគុណដល់ លោក Larry Strange ជានាយកប្រតិបត្តិ និង បណ្ឌិត Rebecca Catalla ជាទីប្រឹក្សាស្រាវជ្រាវនៃ CDRI ចំពោះការជួយគាំទ្រ និងការយកចិត្តទុកដាក់ដល់ការសិក្សានេះ។ យើងខ្ញុំសូមអរគុណផងដែរដល់ លោកស្រី ប៉ុន ដូរីណា ដែលបានជួយសម្របសម្រួលការចុះសិក្សាដល់កន្លែង និង កញ្ញា ផាន់ ដាលីស ចំពោះការប្រមូលទិន្នន័យ និងជំនួយការងារនៅពេលចុះសិក្សាដល់កន្លែង។ យើងខ្ញុំសូមអរគុណដល់ លោកស្រី Susan Watkins អ្នកកែសម្រួលអត្ថបទជាភាសាអង់គ្លេស ដែលបានយកចិត្តទុកដាក់កែជួយសម្រួលឯកសារជាច្រើនសារ។ យើងខ្ញុំក៏សូមអរគុណដល់ លោក អ៊ឹង ស៊ានលី នាយកផ្នែកប្រតិបត្តិការ បណ្ឌិត តុង គឹមស៊ុន អ្នកសម្របសម្រួលកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ និងបុគ្គលិកជំនួយជាច្រើនទៀត ដែលបានជួយសម្រួលដល់ការសិក្សានេះ។

ភ្នំពេញ
ខែធ្នូ ឆ្នាំ២០១២

# ខ្លឹមសារសង្ខេប

កំណើនគួរឲ្យកត់សម្គាល់នៃវិនិយោគផ្ទាល់ពីបរទេស (FDI) ទៅលើដីធ្លីកសិកម្មនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ នៅអាហ្វ្រិក អាស៊ីខាងត្បូង អាស៊ីកណ្តាល និង អាមេរិកឡាទីន ក្នុងប៉ុន្មានឆ្នាំថ្មីៗ បានបង្កក្តីបារម្ភក្នុងចំណោមក្រុមសង្គមស៊ីវិល និងអង្គការអន្តរជាតិ អំពីការប៉ះពាល់ដែលអាចកើតមានទៅលើលទ្ធភាពសហគមន៍ក្រីក្រនៅមូលដ្ឋានក្នុងការប្រើប្រាស់ធនធានផ្សេងៗ។ កំណើនការយកចិត្តទុកដាក់របស់វិនិយោគិនបរទេសទៅលើវិស័យកសិកម្មនៅកម្ពុជា ក៏បានបំផុសក្តីបារម្ភពីឥទ្ធិពលនៃវិនិយោគរបស់ពួកគេទៅលើជីវភាពរស់នៅរបស់សហគមន៍ បរិស្ថាន និងសន្តិសុខស្បៀង។

តាំងពីដើមរៀងមក វិស័យកសិកម្មតែងចូលរួមចំណែកយ៉ាងទៀងទាត់ដល់សេដ្ឋកិច្ចជាតិ ប្រើប្រាស់កម្លាំងពលកម្មនៅជនបទអស់មួយចំណែកធំ និងផ្តល់ចំណូលយ៉ាងច្រើនជារូបិយប័ណ្ណ។ ក្នុងអាណត្តិទី៤ នេះ រដ្ឋាភិបាលកម្ពុជាបានប្រឹងប្រែងកាន់តែខ្លាំងជំរុញវិស័យនេះ ដោយបន្ធូរបន្ថយពន្ធលើផលិតផលកសិកម្ម អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដូចជា ផ្លូវថ្នល់ និងប្រព័ន្ធស្រោចស្រព ព្រមទាំង ដាក់អនុវត្តវិធានការថ្មីៗជួយដល់សហគមន៍មូលដ្ឋាន ដូចជា ដកហូតឡូត៍នេសាទធំៗចេញពីការគ្រប់គ្រងរបស់ឯកជន ដើម្បីឲ្យប្រជាជនអាចប្រើប្រាស់ធនធានជលផល ដោយមិនចាំបាច់ទៅនេសាទនៅទឹកជ្រៅ ឬឆ្ងាយពីច្រាំងនោះទេ។

រដ្ឋាភិបាលក៏បានធ្វើកំណែទម្រង់ព្រៃឈើ ដើម្បីជួយសម្រួលវិនិយោគក្នុងផ្នែកព្រៃឈើ និងដំណាំ តាមរយៈការបង្កើតច្បាប់ស្តីពីសម្បទាន ការបង្កើតសហគមន៍ព្រៃឈើ និងការការពារបរិស្ថាន។ អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច (ELC) ឆ្នាំ២០០៥ បានជួយសម្រួលការផ្តល់ដីសម្បទានទៅឲ្យវិនិយោគិនបរទេស និងក្នុងស្រុក ដើម្បីធ្វើអាជីវកម្មលើដីមិនប្រើប្រាស់ និង/ឬ គ្មានជីជាតិ។

ច្បាប់ពាក់ព័ន្ធដល់បញ្ហាអនាម័យ និងភូតគាមអនាម័យ និងសុខភាពសត្វ បានអនុម័តចេញដើម្បីគ្រប់គ្រងលើផលិតកម្មសត្វចិញ្ចឹម និងទប់ស្កាត់ជំងឺឆ្លង និងការខូចខាត។ នាពេលថ្មីៗនេះ តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) រដ្ឋាភិបាលបានហាមឃាត់ការនាំចូលសត្វចិញ្ចឹមពីប្រទេសជិតខាងដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺផ្តាសាយជ្រូក និងកាត់បន្ថយហានិភ័យនៃការឆ្លងរាលដាលជំងឺសត្វ។

ដោយមានជំនួយគាំទ្រពីដៃគូអភិវឌ្ឍន៍នានា រដ្ឋាភិបាលបានផ្តល់ជំនួយបច្ចេកទេសដល់ប្រជាជនជនបទដែលធ្វើស្រែ នេសាទ និងចិញ្ចឹមសត្វ និងបានប្រឹងប្រែងកែលំអប្រព័ន្ធធារាសាស្ត្រថែមទៀតដើម្បីកាត់បន្ថយការពឹងផ្អែកទៅលើទឹកភ្លៀង ជាពិសេសក្នុងការធ្វើស្រែ និងបង្កើនភាពធន់ទ្រាំនឹងបម្រែបម្រួលអាកាសធាតុ។

ដោយសារកសិកម្មជាវិស័យជំរុញកំណើនសេដ្ឋកិច្ចដ៏ចម្បងមួយនៅកម្ពុជា មានការបង្កើតយន្តការទីផ្សារមួយឡើងសំដៅលើកកម្ពស់ពាណិជ្ជកម្ម និងតម្រែតម្រង់ផលិតផលកសិកម្មឲ្យចូលទៅដល់ទីផ្សារក្នុងស្រុក និងអន្តរជាតិ។ ដើម្បីជួយឲ្យវិស័យកសិកម្មកាន់តែអាចប្រកួតប្រជែងនឹងគេ ក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិ បែបបទការិយាធិបតេយ្យ និងបន្ទុកចំណាយធ្វើអាជីវកម្ម ក៏ត្រូវបានកែលំអឡើងដែរ។ ដោយឡែក ការទាក់ទាញវិនិយោគទៅក្នុងវិស័យថាមពលមានសារៈសំខាន់ណាស់ ពីព្រោះថ្លៃអគ្គិសនីនៅកម្ពុជានៅតែខ្ពស់ខ្លាំង បើធៀបនឹងប្រទេសឯទៀតក្នុងតំបន់។

វិនិយោគផ្នែកកសិកម្ម មានចំណែកតូចនៅក្នុងវិនិយោគសរុប ត្រឹមតែ ៦% ជាមធ្យមចាប់ពីឆ្នាំ២០០០ ដល់ខែមិថុនា ២០១០ ទោះបីក្នុងអំឡុងពេលនោះ មានកំណើនការយកចិត្តទុកដាក់ពីសំណាក់វិនិយោគិនមកពីប្រទេសជាច្រើន ដូចជា ថៃ ចិន វៀតណាម កូរ៉េ សិង្ហបុរី ជប៉ុន ម៉ាឡេស៊ី កាណាដា ឥណ្ឌា បារាំង អង់គ្លេស សហរដ្ឋអាមេរិក និងដាណឺម៉ាកក្តី។ វិនិយោគិនចូលរួមជាសំខាន់ក្នុងផ្នែកដំណាំដាំដុះ ដូចជា កៅស៊ូ ដំឡូងឈើ ពោត អំពៅ ស្វាយចន្ទី ព្រមទាំងព្រៃឈើ ដូចជា ដើមម៉ៃសាក់ និងអាកាស្យា ជាដើម។ ក្នុងការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងប៉ុន្មានឆ្នាំថ្មីៗ បានបង្កក្តីបារម្ភក្នុងចំណោមអ្នកពាក់ព័ន្ធនានា ពីឥទ្ធិពលនៃគម្រោង ELC បរទេស ទៅលើជីវភាពសហគមន៍ គុណភាពបរិស្ថាននៅមូលដ្ឋាន និងសន្តិសុខស្បៀងជាតិ។

ការពិនិត្យជាដំបូងៗដោយប្រើទិន្នន័យបានពី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) និង MAFF បានបង្ហាញពីឥទ្ធិពលទាំងវិជ្ជមាន និងអវិជ្ជមាន នៃគម្រោង FDI នានា។ គម្រោងខ្លះបានបង្កើតការងារជាច្រើនសម្រាប់សហគមន៍មូលដ្ឋាន ហើយខ្លះទៀតគ្មានសោះទេ។ បញ្ហាគួរកត់សម្គាល់មួយ គឺ ទំនាស់ដីធ្លីផុសចេញពីប្រព័ន្ធកាន់កាប់ដីធ្លីអន់ខ្សោយ និងការពិគ្រោះយោបល់តិចតួចជាមួយសហគមន៍មូលដ្ឋានមុនពេលសម្រេចយល់ព្រមលើគម្រោង ELC ឃើញកើតមានពាសពេញ។ ម៉្យាងទៀត គម្រោងខ្លះដែលត្រូវមានការកាប់រានព្រៃឈើ បានបំផ្លាញអស់នូវប្រភពជាប្រពៃណី និងសំខាន់បំផុតនៃប្រាក់ចំណូលពីបរិស្ថានមួយចំនួន ដែលបានពីការបេះប្រមូលអនុផលព្រៃឈើ ដូចជា វល្លិ៍ ជ័រឈើ ឫស្សី ផ្តៅ និងការបរបាញ់ ជាដើម។ ម៉្យាងទៀត ការចាក់ដីបំពេញជ្រោះអូរដោយក្រុមហ៊ុន ELC ខ្លះ បានបង្កកង្វះខាតទឹក។ ជារួម ការស្រាវជ្រាវលើគម្រោងជ្រើសរើសមួយចំនួន ហាក់បង្ហាញថា បន្ទុកចំណាយលើគម្រោង FDI ច្រើនតែធំជាងអត្ថប្រយោជន៍ទទួលបាន។

ដោយសារកំណើនប្រជាជនយ៉ាងលឿន និងដីធ្លីដែលកាន់តែខ្វះខាតឡើង សន្តិសុខស្បៀងបានក្លាយជាក្តីបារម្ភកាន់តែធំឡើងនៅកម្ពុជា។ ការវិភាគលើទិន្នន័យបានពី CDC (2000-09) និង MAFF (1995-99) ស្តីពីវិនិយោគរបស់ ELC និងការចុះសិក្សាដល់កន្លែងលើគម្រោង FDI មួយចំនួន បានបង្ហាញថា កម្ពុជានឹងពុំជួបអសន្តិសុខស្បៀងទេក្នុងរយៈពេលខ្លី និងមធ្យម ទោះបីមានការនាំចេញស្រូវជាច្រើនជាលក្ខណៈក្រៅផ្លូវការ ទៅ ថៃ និង វៀតណាមក្តី។ ប៉ុន្តែក្នុងរយៈពេលវែង ទំនាស់លើការប្រើប្រាស់ដី កង្វះទឹក និងការបាត់បង់ប្រភពចំណូល ដែលកាន់តែធ្ងន់ធ្ងរឡើងដោយសារកំណើនយ៉ាងខ្លាំងនៃវិនិយោគ ELC ក្នុងប៉ុន្មានឆ្នាំថ្មីៗ អាចនាំឲ្យមានការថយចុះការហូបស្បៀងតាមគ្រួសារ និងកម្រិតអាហារូបត្ថម្ភ ហើយអ្នកងាយរងគ្រោះជាងគេ គឺ គ្រួសារធ្វើកសិកម្មបានត្រឹមមួយរស់ និងគ្រួសារមិនអាចរកចំណូលបានគ្រប់គ្រាន់ពីការធ្វើស្រែ ដូចជានៅឃុំក្រយា ក្នុងខេត្តកំពង់ធំ ជាដើម។

# ១
# សេចក្តីផ្តើម

ក្នុងពីរបីឆ្នាំកន្លងមកនេះ វិនិយោគផ្ទាល់បរទេស (FDI) បានកើនឡើងគួរឲ្យកត់សម្គាល់លើដីធ្លីកសិកម្មនៅតាមប្រទេសកំពុងអភិវឌ្ឍន៍នៅអាហ្វ្រិក អាស៊ីខាងត្បូង អាស៊ីកណ្តាល និង អាមេរិកឡាទីន ដោយសារជាសំខាន់ប្រទេសនាំចូលស្បៀងនិងថាមពលនានា ខំប្រឹងប្រែងដោះស្រាយវិបត្តិស្បៀងនិងថាមពលក្នុងស្រុករបស់ខ្លួន ក្រោយពេលត្រូវប៉ះទង្គិចដោយថ្លៃស្បៀងអាហារសាកលដ៏ខ្ពស់ក្នុងឆ្នាំ២០០៨ និងថ្លៃប្រេងដ៏ខ្ពស់ក្នុងឆ្នាំ២០០៧ និងដើមឆ្នាំ២០០៨។ ក្នុងនេះ ធនាគារវិនិយោគដូចជា Black Rock (USA), Deutsche Bank (Germany), Goldman Sachs (USA), និង Knight Frank (UK) ជាដើម បានខំស្វែងរកដីកសិកម្មធំៗក្នុងប្រទេសកំពុងអភិវឌ្ឍន៍ មកធ្វើជាប្រភពវិនិយោគថ្មី (Braun & Mainzen-Dick 2009; Smaller & Man2009)។ ស្ថានភាពនេះបានបង្កក្តីបារម្ភក្នុងចំណោមក្រុមសង្គមស៊ីវិល និងអង្គការអន្តរជាតិនានាអំពីផលប៉ះពាល់ដែលអាចកើតមានដល់ លទ្ធភាពប្រើប្រាស់ធនធានធម្មជាតិរបស់សហគមន៍ក្រីក្រនៅតាមមូលដ្ឋាន។

កម្ពុជាមានធនបម្រុងជាផ្ទៃទឹកសាបយ៉ាងធំ (បឹងទន្លេសាបទំហំ២៧០គ.ម២នៅរដូវប្រាំងនិង១៦.០០០គ.ម២ នៅរដូវវស្សា និង ទន្លេមេគង្គប្រវែង ៤៨០គ.ម) និងផ្ទៃដីអាចដាំដុះបានយ៉ាងធំដែរ។ ប្រទេសនាំចូលស្បៀងដូចរៀបរាប់ខាងលើមួយចំនួន ដូចជា ចិន គុវ៉ែត ម៉ាឡេស៊ី កាតារ កូរ៉េ និង វៀតណាម បានផ្តោតការយកចិត្តទុកដាក់មកលើធនធានធម្មជាតិរបស់កម្ពុជា។ដីកម្មសិទ្ធិឯកជនរបស់រដ្ឋក្នុងទម្រង់ជាសម្បទានដីសេដ្ឋកិច្ច (ELC) ត្រូវបានជួលទៅឲ្យសម្បទានិកសម្រាប់ធ្វើអាជីវកម្មកសិកម្មរហូតដល់ ៩៩ឆ្នាំ (GTZ 2009)។ នាបច្ចុប្បន្ន មាន ៨៥ ក្រុមហ៊ុន ទាំងក្នុងស្រុក និងបរទេស ដែលមានកិច្ចសន្យាធ្វើអាជីវកម្មលើផ្ទៃដីសរុប ៣៧៩.០៣៤ ហិកតា (MAFF 2010)។

អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល (NGO) បានបង្ហាញក្តីបារម្ភធ្ងន់ធ្ងរពីផលប៉ះពាល់នៃសកម្មភាពរបស់អ្នកកាន់កាប់ ELC ទៅលើសហគមន៍ក្រីក្រនៅក្នុងមូលដ្ឋានដែលនៅជិតខាង។ មកទល់សព្វថ្ងៃ មានការស្រាវជ្រាវតិចតួចណាស់ពីផលប៉ះពាល់ខាងសេដ្ឋកិច្ច បរិស្ថាន និងសង្គមកិច្ចនៃលំហូរFDIទៅក្នុងវិស័យកសិកម្មឬក៏អត្ថប្រយោជន៍ដល់ប្រទេសកម្ពុជា។ ប៉ុន្តែភស្តុតាងនៅអន្តរជាតិ អំពីបន្ទុកចំណាយ និងអត្ថប្រយោជន៍នៃវិនិយោគបែបនេះ បង្ហាញថា ថ្វីបើការធ្វើអាជីវកម្មលើដីកសិកម្មខ្នាតធំ វាអាចកាត់បន្ថយលទ្ធភាពប្រើប្រាស់ដី និងទឹករបស់សហគមន៍មូលដ្ឋានក្តី ប៉ុន្តែវាក៏អាចរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ឆ្លងតាមការចូលរួមរបស់វិនិយោគិន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងស្រុកដ៏ចាំបាច់ សម្រាប់ការរីកលូតលាស់កសិកម្ម ជាពិសេសប្រព័ន្ធស្រោចស្រព។ ពេលនេះ សមល្មមដល់ពេលត្រូវធ្វើការស្រាវជ្រាវលំអិតពីឥទ្ធិពលផ្សេងៗនៅកម្ពុជាហើយ ដើម្បីអាចចាត់វិធានការកាត់បន្ថយឥទ្ធិពលអវិជ្ជមានផ្សេងៗដែលអាចកើតឡើង។

## ១.១. គោលដៅនៃការសិក្សា

ការសិក្សានេះមានគោលដៅ ពិនិត្យពីភាពសមរម្យនៃក្តីបារម្ភដែលគេលើកឡើងនៅកម្ពុជា អំពីឥទ្ធិពលនៃ FDI ខាងកសិកម្ម ទៅលើសហគមន៍ និងបរិស្ថាននៅតាមមូលដ្ឋាន។ ជាដំបូងការសិក្សាផ្តោតលើ ទំហំ និងប្រភេទនៃ FDI ក្នុងវិស័យកសិកម្ម និងលំអិតតាមអនុវិស័យ ដូចជា ដំណាំ សត្វចិញ្ចឹម ការកែច្នៃស្បៀងអាហារ ព្រៃឈើនិងជលផល។ បន្ទាប់មក មានការវិភាគពីគោលនយោបាយ និងក្របខ័ណ្ឌច្បាប់និងស្ថាប័នដែលគ្រប់គ្រង និងជួយសម្រួល FDI ទាំងនោះ ព្រមទាំងគំរូអាជីវកម្មជាទូទៅ ដើម្បីទទួលបានដីកសិកម្ម។ នៅចុងបញ្ចប់ មានការលើកជាអនុសាសន៍មួយចំនួនដើម្បីដោះស្រាយបញ្ហាផ្សេងៗដែលវិស័យនេះកំពុងប្រឈមមុខ។

## ១.២. វិធីសាស្ត្រ

គេអាចរកបានដោយចោះៗខ្លាំងណាស់នូវទិន្នន័យស្តីពីការទទួលបានដី ជាពិសេសទិន្នន័យស្តីពីរបៀបរបបធ្វើកិច្ចសន្យា និងទិន្នន័យមុនពេលបានដី និងក្រោយពេលបានដី ស្តីពីសូចនាករខាងសេដ្ឋកិច្ចសង្គមកិច្ច និងបរិស្ថាននៅតាមទីតាំងគម្រោងជ្រើសរើសមួយចំនួន។ ដូច្នេះការសិក្សានេះ ត្រូវផ្អែកជាសំខាន់លើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ និងការពិភាក្សានៅតាមសហគមន៍នៅក្នុង ឬនៅជិតតំបន់ដីសម្បទាន ដើម្បីផ្តល់ឲ្យអ្នកកំណត់គោលនយោបាយ និងតួអង្គដទៃទៀតនូវគំនិតជាទូទៅមួយពីផលប៉ះពាល់ដែលអាចកើតចេញពីគម្រោង FDI ប្រភេទខ្លះ ទៅលើសហគមន៍មូលដ្ឋាន និងបរិស្ថាន។

ករណីសិក្សាពី FDI ក្នុងអនុវិស័យដំណាំ សត្វចិញ្ចឹម ការកែច្នៃស្បៀងអាហារ ព្រៃឈើនិងជលផល បានផ្អែកលើការស្រាវជ្រាវពីមុនៗ និងការពិភាក្សាជាមួយមន្ត្រីរដ្ឋាភិបាល និងអ្នកតំណាងមកពីសហគមន៍នៅជិតកន្លែងដីសម្បទាន។ ការពិភាក្សាតាមក្រុមស្នូល (FDG) បានធ្វើឡើងជាមួយសហគមន៍មូលដ្ឋាន និងអាជ្ញាធរភូមិ ដើម្បីក្តាប់ព័ត៌មានអំពីផលប៉ះពាល់ចម្បងៗខាងសេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន។ សូចនាករខាងសេដ្ឋកិច្ចរួមមាន ប្រាក់ចំណូល ការងារ ការអភិវឌ្ឍប្រព័ន្ធស្រោចស្រពនិងផ្លូវថ្នល់ សូចនាករខាងសង្គមកិច្ច ដែលគិតគូរពីការថែទាំសុខភាព លទ្ធភាពប្រើប្រាស់ទឹក និងដី និងទំនាស់ដីធ្លី ហើយសូចនាករខាងបរិស្ថាន ផ្តោតលើការប្រើ/ការប្រើលើសកម្រិតនូវថ្នាំសម្លាប់សត្វចង្រៃនិងដី និងការកាប់ឈើ (គម្របព្រៃឈើ)។ ក្រុមសិក្សាក៏បានជួបជាមួយវិនិយោគិនបរទេស ដើម្បីពិភាក្សាពីបន្ទុកចំណាយ និងផលចំណេញនៃគម្រោងពួកគេ និងឧបសគ្គផ្សេងៗដែលអាចកើតមានដល់ការវិនិយោគនៅកម្ពុជា។

ក្រុមស្រាវជ្រាវក៏បានប្រមូលទិន្នន័យទី២ ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF), CDC, វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ (MoP), ក្រសួងបរិស្ថាន (MoE), និង អង្គការអន្តរជាតិ ដែរ។ រូបភាព ១ បង្ហាញពីរចនាសម្ព័ន្ធទាំងមូលនៃការវិភាគ។

រូបភាព ១៖ ក្របខ័ណ្ឌវិភាគសម្រាប់ការវិភាគពី FDI ក្នុងកសិកម្ម



## ១.៣. វិសាលភាព និងកំហិតនានា

ការសិក្សាមានវិសាលភាពធំទូលាយបែបនេះ មិនមែនសំដៅបំផុសចំណុចលំអិតនៃគម្រោង FDI និងការលំបាកនៃវិនិយោគក្នុងអនុវិស័យផ្សេងរបស់កសិកម្មនោះទេ ប៉ុន្តែដើម្បីស្រាវជ្រាវពីគម្រោង និងសហគ្រាសជ្រើសរើសមួយចំនួនដោយផ្អែកលើការពិគ្រោះជាមួយសហគមន៍មូលដ្ឋាន និងការវិនិច្ឆ័យរបស់ក្រុមស្រាវជ្រាវ។ ម្យ៉ាងទៀត ដោយសារកំហិតខាងពេលវេលា ការសិក្សានេះបានព្យាយាមបង្ហាញពីរូបភាពជារួមនៃ FDI នៅក្នុងអនុវិស័យទាំងនោះប៉ុណ្ណោះ ដោយប្រមូលព័ត៌មានពីឥទ្ធិពលដែលទំនងកើតមានលើសហគមន៍មូលដ្ឋាន និងបរិស្ថានជិតៗនោះ តាមការអនុវត្តវិធីសាស្ត្រហេតុការណ៍ផ្ទុយ (counterfactual approach)។[១] ក្រុមស្រាវជ្រាវក៏បានព្យាយាមទៅ ពិគ្រោះជាមួយវិនិយោគិនបរទេសដែរ ប៉ុន្តែត្រូវលំបាកខ្លាំង ពីព្រោះពិបាករកឃើញពួកគេណាស់ ហើយនៅទីបំផុតធ្វើសម្ភាសន៍បានតែពីរនាក់ប៉ុណ្ណោះ។

---

[១] គុណវិបត្តិនៃវិធីសាស្ត្រនេះ គឺផលប៉ះពាល់ដែលត្រូវវាស់វែង គឺគេអាចប៉ាន់ស្មានវាខ្ពស់ពេក ឬទាបពេក ពីព្រោះការស្នើឲ្យអ្នកឆ្លើយសម្ភាសន៍ប្រៀបធៀបស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចរបស់ខ្លួននៅមុនពេល និងក្រោយពេលមានគម្រោង តែងមានចូលលាយឡំច្រើននូវការយល់ឃើញផ្ទាល់របស់បុគ្គល។ ការវិភាគផលប៉ះពាល់ស៊ីជម្រៅនៃគម្រោងជាក់លាក់ ដែលត្រូវប្រើបច្ចេកទេសវាយតម្លៃស្មុគស្មាញ ដូចជា propensity score matching, before and after, difference-in-difference and instrumental variables គឺអាចសិក្សាស្រាវជ្រាវនៅពេលក្រោយ។

# ២
# តួនាទីកសិកម្មក្នុងសេដ្ឋកិច្ចជាតិ

ទោះបីក្នុងពីរទសវត្សរ៍កន្លងទៅនេះ ចំណែកកសិកម្មនៅក្នុងផលិតផលជាតិសរុប (ផសស) បានថយចុះគួរឲ្យកត់សំគាល់ពី ៤៦% នៅឆ្នាំ១៩៩៣ មកត្រឹម ២៨% នៅឆ្នាំ២០០៩ក្តី (MEF 2010) ក៏វិស័យនេះនៅតែជាកម្លាំងសំខាន់ជំរុញកំណើន និងកាត់បន្ថយភាពក្រីក្រ ពីព្រោះប្រមាណ ៨៥% នៃប្រជាជនកម្ពុជារស់នៅក្នុងតំបន់ជនបទ ហើយភាគច្រើនបានយករបរកសិកម្ម (ជាពិសេសការធ្វើស្រែ) ធ្វើជាមធ្យោបាយចម្បងសម្រាប់រកចំណូល និងទ្រទ្រង់ជីវភាព។ ដូចមានចែងក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី១ និង ទី២ របស់រដ្ឋាភិបាល ផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ (NSDP) ឆ្នាំ២០០៦-១០ និង NSDP ធ្វើបច្ចុប្បន្នភាពឆ្នាំ២០០៩-១៣ ដើម្បីទទួលបានកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនោះ វិស័យកសិកម្មមានចំណាត់ថ្នាក់ខ្ពស់នៅក្នុងអាទិភាពអភិវឌ្ឍន៍ជាយុទ្ធសាស្រ្តធំៗទាំងបួន។ អាទិភាពបីទៀត គឺមានការស្តារកសាងហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍវិស័យឯកជន និងការបង្កើតការងារ ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។

## ២.១. ការរួមចំណែករបស់កសិកម្មនៅក្នុងផលិតផលជាតិ

នៅមុនឆ្នាំ២០០០ ផលិតកម្មកសិកម្មតំណាងឲ្យជិតពាក់កណ្តាលនៃផលិតផលជាតិសរុប (ផសស) និងឆ្លុះបញ្ចាំងពីលក្ខណៈកសិកម្មនៃសេដ្ឋកិច្ចកម្ពុជា ប៉ុន្តែវាបានថយចុះគួរឲ្យកត់សំគាល់ក្នុងពីរទសវត្សរ៍កន្លងទៅនេះ។ ទិន្នន័យចុងក្រោយបានពី MAFF បង្ហាញថា កសិកម្មរួមចំណែកបានត្រឹម ៣៥,៥% នៃ ផសស កម្ពុជាប៉ុណ្ណោះ នៅឆ្នាំ២០០៩ ធៀបនឹង ៤៥,៣% នៅឆ្នាំ១៩៩៣។ ចំណែកកសិកម្មនៅក្នុងការងារសម្រាប់កម្លាំងពលកម្មកម្ពុជា ក៏បានថយចុះពី ៦៧,៤% នៅឆ្នាំ២០០២ មកត្រឹម ៥៥,៩% នៅឆ្នាំ២០០៧ ទោះបីវានៅធំគួរសមក្តី។ ការប្រែប្រួលគួរឲ្យកត់សំគាល់ក្នុងរចនាសម្ព័ន្ធនៃសេដ្ឋកិច្ចកម្ពុជានេះ ផុសចេញពីកំណើនយ៉ាងលឿនក្នុងផ្នែកកម្មន្តសាល (វាយនភ័ណ្ឌ និងសម្លៀកបំពាក់) និងវិស័យសេវាកម្ម។

តារាង ១៖ ចំណែកនៃផលិតកម្មកសិកម្មនៅក្នុងផលិតផលជាតិឆ្នាំ២០០២-២០០៩

| ប្រភេទ | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|---|---|---|
| ចំណែកកសិកម្មក្នុង ផសស (%) | 33.3 | 31.5 | 32.0 | 30.7 | 30.1 | 29.7 | 32.8 | 33.5 |
| ចំណែកនៃការងារនៅក្នុងកសិកម្ម* (%) | 67.4 | 64.2 | 60.3 | 59.1 | 57.4 | 55.9 | - | - |
| តម្លៃបន្ថែមនៃកសិកម្ម (ពាន់លានរៀល) | 5108 | 5645 | 5596 | 6476 | 6830 | 7174 | 7562 | 7994 |
| កំណើនតម្លៃបន្ថែម (y-o-y) (%) | -2.5 | 10.5 | -0.9 | 15.7 | 5.5 | 5.0 | 5.4 | 5.7 |
| ចំណែកអនុវិស័យនានាក្នុងកសិកម្ម | | | | | | | | |
| ដំណាំ (%) | 42.4 | 46.8 | 46.1 | 50.9 | 50.8 | 52.2 | 52.7 | 52.9 |
| ជលផល (%) | 31.6 | 29.1 | 28.8 | 26.3 | 25.9 | 24.8 | 25.0 | 25.2 |
| សត្វចិញ្ចឹមរួមទាំងមាន់ទា (%) | 16.8 | 16.1 | 16.9 | 15.4 | 15.8 | 15.6 | 15.5 | 15.3 |
| ព្រៃឈើ និងការកាប់ឈើ (%) | 9.1 | 8.0 | 8.1 | 7.4 | 7.5 | 7.3 | 6.9 | 6.6 |

កំណត់សំគាល់៖ *ទិន្នន័យបានពី IMF (2007, 2009)

ប្រភព៖ MAFF (2008, 2009, 2010)

កំណើនមធ្យមប្រចាំឆ្នាំ (តម្លៃបន្ថែមដុល) ក្នុងវិស័យកសិកម្មមានប្រហែល ៥,៦% ពីឆ្នាំ២០០២ ដល់ ២០០៩។ កំណើនយឺតបែបនេះអាចដោយសារចំណងតភ្ជាប់ (linkage) ជនបទ-ទីក្រុងទន់ខ្សោយ កម្មសិទ្ធិដីធ្លី គ្មានសុវត្ថិភាព វិនិយោគខ្សោយទាំងសាធារណៈ និងឯកជន (ជាពិសេសផ្នែកស្រោចស្រព ដឹកជញ្ជូន ស្រាវជ្រាវកសិកម្ម) និងហេដ្ឋារចនាសម្ព័ន្ធជួយគាំទ្រតិចតួច ដូចជា វត្តមាន និងលទ្ធភាពទទួលបានហិរញ្ញវត្ថុ និងថាមពលមានតម្លៃសមរម្យអាចប្រើបាន និងសេវាទូរគមនាគមន៍ (World Bank 2004a, 2004b, 2006)។

ដំណាំកសិកម្មគ្របដណ្តប់ដោយការធ្វើស្រែស្រូវ រួមចំណែកប្រហែលពាក់កណ្តាលនៃទិន្នផលកសិកម្មជាតិ។ ការនេសាទ រួមមានទឹកសាប វារីវប្បកម្ម និងទឹកប្រៃមានប្រហែល ៣៣% សត្វចិញ្ចឹម និងបក្សីរួមចំណែកប្រហែល ១៦% ហើយព្រៃឈើ និងផលិតកម្មធ្វើពីឈើរួមចំណែកប្រហែល ៨%នៃទិន្នផលកសិកម្មសរុប។

## ២.២. ផលិតកម្ម និងតំបន់ប្រមូលផល

ទន្ទឹមគ្នានឹងកំណើនយ៉ាងលឿននៃឧស្សាហកម្មកម្មន្តសាលក្នុងទសវត្សរ៍កន្លងទៅ ផលិតកម្មស្រូវដែលជាអាហារមូលដ្ឋាននៅកម្ពុជា ក៏បានរីកចម្រើនខ្លាំងដែរ។ ផ្ទៃដីដាំស្រូវបានកើនឡើងពីប្រមាណ ២,៤លានហិកតា នៅឆ្នាំ២០០៤ ដល់ ២,៧លានហិកតា នៅឆ្នាំ២០០៩ ដោយសារជាចម្បងផែនការពង្រីករបស់រដ្ឋាភិបាល។ ផលិតកម្មក៏បានស្ទុះឡើងពី ៤,២លានតោន នៅឆ្នាំ២០០៤ ដល់ ៧,៦លានតោន នៅឆ្នាំ២០០៩ ដែរ ដោយសារផ្ទៃដីដាំដុះត្រូវខូចខាត (ផលដករវាង ផ្ទៃដីដាំដុះសរុប និងផ្ទៃដីប្រមូលផល) មានតិចតួចណាស់។ កំណើនផលិតកម្មយ៉ាងច្រើននេះ នាំឲ្យមានអតិរេកស្រូវធំសម្បើម (រូបភាព ២)។ គេប៉ាន់ថា អនុវិស័យនេះ ប្រើប្រាស់មនុស្សដល់ប្រហែល ២.៩៤០.០០០នាក់ ដែលបង្ហាញពីសក្តានុពលដ៏ធំក្នុងការកាត់បន្ថយភាពក្រីក្រនៅជនបទកម្ពុជា (UNDP 2007: 5)។

ភស្តុតាងនានាបង្ហាញថា ពីឆ្នាំ២០០២ ដល់ ២០០៩ ផលិតកម្មដំណាំចម្បងៗផ្សេងទៀត ដូចជា ដំឡូងឈើ ពោត សណ្តែកសៀង បានកើនឡើងយ៉ាងលឿននិងថេរ ហើយសណ្តែកបាយ ក៏កើនឡើងបន្តិចដែរ (រូបភាព ៣)។ កំណើននេះអាចដោយសារកំណើនតម្រូវការផលដំណាំទាំងនេះនៅប្រទេសថៃនិងវៀតណាមដែលជាអ្នកទិញវាជាប្រពៃណីបានរុញថ្លៃឡើង។ ចំពោះការងារវិញ ផលិតកម្មសណ្តែកសៀង ពោត និងដំឡូងឈើ ប្រើពលករដល់ប្រហែល ១៦.៥០០នាក់ ១២.៥០០នាក់ និង ៤០០០នាក់ រៀងគ្នា (UNDP 2007: 5)។ កម្ពុជា ក៏ផលិតដំណាំពិសេសជាច្រើនដែរ ដូចជា ដំឡូងជ្វា សណ្តែកដី ល្ង អំពៅ ថ្នាំជក់ ក្រចៅ និងបន្លែផ្សេងៗ។

ការស្ទុះឡើងថ្លៃកៅស៊ូយ៉ាងខ្លាំងនៅទីផ្សារអន្តរជាតិក្នុងទសវត្សរ៍កន្លងទៅនេះ បានបំផុសការយកចិត្តទុកដាក់ច្រើនណាស់របស់វិនិយោគិនទាំងក្នុងស្រុក និងបរទេស ចំពោះដំណាំនេះ ធ្វើឲ្យវាក្លាយជាដំណាំឧស្សាហកម្មចម្បងនៅកម្ពុជា។ ក្នុងប៉ុន្មានឆ្នាំថ្មីៗ វិនិយោគិនវៀតណាមបានចូលពាក់ព័ន្ធច្រើនណាស់ ប៉ុន្តែចំនួនប៉ុណ្ណា គេពិបាកនឹងស្មានដឹង។ ទិន្នន័យចុងក្រោយបានពី MAFF បង្ហាញថា ផ្ទៃដីដាំកៅស៊ូសរុប (ទាំងផ្តល់ផលហើយ និងមិនទាន់គ្រប់អាយុ) រួមទាំងចំការធំៗ វិនិយោគថ្មីក្នុងទម្រង់ជា ELC និងចំការតូចៗតាមគ្រួសារ មាន ១៣០.៩២១ហិកតា នៅឆ្នាំ២០០៩ ធៀបនឹង ៨២.០០០ហិកតានៅឆ្នាំ២០០៧។ រូបភាព ៤ បង្ហាញពីការថយចុះផ្ទៃដីចៀរជ័រ (កៅស៊ូគ្រប់អាយុ) ដែលហាក់ដូចជាផ្ទុយពីតួលេខខាងលើ ដោយសារដើមកៅស៊ូខ្លះចាស់ពេក មិនអាចយកជ័របាន ដូច្នេះត្រូវកាប់ចេញ។ តាមធម្មតាដើមកៅស៊ូគ្រប់អាយុអាចយកជ័របាន ក្រោយពេលដាំបានពីបីទៅប្រាំឆ្នាំ។ ទិន្នន័យ MAFF បង្ហាញថា មានដើមកៅស៊ូចាស់ (មិនផ្តល់ផល) ដែលគេបានកាប់ចេញពីឆ្នាំ១៩៩៦ ដល់ ២០០៦។

រូបភាព ២៖ ផ្ទៃដីដាំដុះ និងផលិតកម្មស្រូវ ពីឆ្នាំ២០០៤-០៩




ប្រភព៖ MAFF (2009, 2010)

រូបភាព ៣៖ផលិតកម្មដំណាំចម្បងៗ ពីឆ្នាំ២០០២-០៩ (ពាន់តោន)




ប្រភព: MAFF (2009, 2010)

សត្វចិញ្ចឹមបានរួមចំណែកប្រហែល មួយភាគប្រាំមួយ នៃ ផសស ក្នុងទសវត្សរ៍កន្លងទៅ និងប្រើប្រាស់ពលករប្រហែល ៤០០.០០០នាក់នៅឆ្នាំ២០០៦ (UNDP 2007: 5)។ បើគិតជាចំនួន មាន់ទាមានច្រើនជាងគេ ទោះបីបានថយចុះគួរឲ្យកត់សំគាល់ក្នុងឆ្នាំ២០០៤ ក្តី ប៉ុន្តែក្រោយមកបានស្ទុះឡើងវិញ ដោយសារមានឧបត្ថម្ភធនសម្រាប់ទប់ទល់ការធ្លាក់ចុះបង្កដោយគ្រុនផ្តាសាយបក្សី និងកំណើនការយល់ដឹងរបស់ផលិតករពីការគ្រប់គ្រង និងបង្ការជំងឺឆ្លង។ ផលិតកម្មគោ និងក្របី ក៏បានរីកលូតលាស់ក្នុងអំឡុងពេលនោះដែរ ដោយមានអត្រាកំណើនប្រចាំឆ្នាំមធ្យម ២,៩% និង ២,៥% រៀងគ្នា។ ផ្ទុយទៅវិញ ផលិតកម្មជ្រូកបានថយចុះគួរឲ្យកត់សំគាល់ពីឆ្នាំ២០០៦ដល់ ២០០៩ ដោយសារកំណើនការភ័យខ្លាចការឆ្លងជំងឺផ្តាសាយបក្សី (AH1N1) កំណើនការនាំចូលជ្រូកខុសច្បាប់ពីប្រទេសជិតខាង និងបន្ទុកចំណាយខ្ពស់នៃផលិតកម្មក្នុងស្រុក (MAFF 2010: 19)។

រូបភាព ៤៖ ចំការកៅស៊ូ ផលិតកម្ម និងថ្លៃ ពីឆ្នាំ២០០៤-១០




កំណត់សំគាល់៖ ថ្លៃសម្រាប់ឆ្នាំ២០១០ = មធ្យមភាគលើប្រាំបួនខែ
ប្រភព:  MAFF ( 2009, 2010 ); Malaysia Rubber Board ( 2010 )

រូបភាព ៥៖ ផលិតកម្មសត្វចិញ្ចឹម ឆ្នាំ២០០២-០៩ ( ពាន់ក្បាល )




ប្រភព: MAFF ( 2009, 2010 )

ត្រីទឹកសាបនៅតែមានចំណែកភាគច្រើនក្នុងចំនួនត្រីចាប់បានសរុប ដោយសារកម្ពុជាមានបឹងទន្លេសាបដ៏ធំ និងទន្លេមេគង្គហូរកាត់យ៉ាងវែងចុះពីប្រទេសឡាវ ( ខ្សែទឹកខាងលើ ) ទៅ វៀតណាម ( ខ្សែទឹកខាងក្រោម )។ ទោះបីចំនួនត្រីចាប់បានសរុបមិនប្រែប្រួលច្រើនទេពីឆ្នាំ២០០២ ដល់ ២០០៩ ប៉ុន្តែមានកំណើនការបារម្ភពីឥទ្ធិពលអវិជ្ជមាននៃកំណើនចំនួនគម្រោងវារីអគ្គិសនីនៅខ្សែទឹកខាងលើ ដូចជានៅចិន និងវៀតណាម ទៅលើបរិមាណត្រីចាប់បាននៅខ្សែទឹកខាងក្រោម ដូចជានៅកម្ពុជា។ ចំពោះត្រីទឹកប្រៃ និងវារីវប្បកម្មវិញ ផលិតកម្មកើនយឺតៗ ប៉ុន្តែជាទៀងទាត់។ ដូច្នេះការបង្កើនវិនិយោគក្នុងអនុវិស័យជលផល អាចជួយប៉ះប៉ូវការថយចុះថែមទៀតក្នុងចំនួនត្រីចាប់បានទៅអនាគត។ កត្តា

នេះសំខាន់ណាស់ ពីព្រោះវាជួយយ៉ាងច្រើនដល់អ្នករកចំណូលមានជំនាញទាប ដោយផ្ដល់បានប្រហែល ២៦០.០០០ ការងារ ( UNDP 2007: 5 )។

រូបភាព ៦៖ ផលិតកម្មត្រី ឆ្នាំ២០០២-០៩ ( ពាន់តោន )




ប្រភព៖ MAFF ( 2009, 2010 )

ក្នុងអនុវិស័យព្រៃឈើ មានការកាប់ឈើខុសច្បាប់ទ្រង់ទ្រាយធំ និងការថយចុះគម្របព្រៃឈើគួរឲ្យកត់សំគាល់នៅកម្ពុជាក្នុងទសវត្សរ៍១៩៩០។ ដោយមានការកាប់យកឈើច្រើនពាសពេញដូច្នេះរដ្ឋាភិបាលបានចេញសេចក្ដីសម្រេចផ្អាកសកម្មភាពកាប់ឈើ និងការនាំចេញឈើនៅដើមទសវត្សរ៍២០០០ ព្រមទាំងលុបចេញអស់ប្រហែល ៥០% នៃសម្បទានព្រៃឈើទាំងអស់ ដែលធ្វើឲ្យផលិតកម្ម និងការនាំចេញឈើធ្លាក់ចុះ ប៉ុន្តែជួយពង្រឹងការអភិរក្សបរិស្ថាន និងការការពារតំបន់ធម្មជាតិ។

យោងតាម MAFF ផ្ទៃគម្របព្រៃសរុបនៅឆ្នាំ២០០៦ មានទាំង ព្រៃស្រោង ព្រៃរបោះ ព្រៃគម្ពោត នៅលើដីគោក និងដីច្រើនប្រភេទទៀត មានចំនួន ១០.៨៦៤.១៨៦ហិកតា ឬប្រហែល ៦០% នៃផ្ទៃដីសរុប ( MAFF 2007:94 )។ កិច្ចប្រឹងប្រែងដាំព្រៃឈើឡើងវិញដោយរដ្ឋបាលព្រៃឈើ និងក្រុមហ៊ុនដាំដើមឈើឯកជន មិនបានចូលរួមចំណែកច្រើនបង្កើនគម្របព្រៃឈើនៅកម្ពុជាទេ ដោយផ្ទៃដីដាំឈើថ្មីមាន ១៨.៩២៤ហិកតា នៅឆ្នាំ២០០៩ ធៀបនឹង ១១.២៥០ ហិកតានៅឆ្នាំ២០០៥។

## ២.៣. ចំណូលរូបិយប័ណ្ណ

ក្រៅពីបង្កើតការងារ និងផលិតកម្មសម្រាប់ការប្រើប្រាស់ក្នុងស្រុក កសិកម្មក៏ផ្ដល់នូវទំនិញនាំចេញបានច្រើនដែរ។ តារាង ២ បង្ហាញតួលេខនៃទំនិញនាំចេញកសិកម្មសំខាន់ៗគិតតាមកម្រិតថ្លៃបច្ចុប្បន្ន។ ឈើ របស់ធ្វើពីឈើ និងកៅស៊ូធម្មជាតិ បាននាំមុខគេក្នុងការផ្ដល់ចំណូលជារូបិយប័ណ្ណ ពីឆ្នាំ២០០២ ដល់ ២០០៨ ហើយបន្ទាប់មកគឺ ផ្លែឈើ ហូបបាន បន្លែ និងមើមឈើ ធញ្ញជាតិ ត្រី និងសត្វរស់ ប៉ុន្តែចំណែកផលិតផលទាំងនេះនៅក្នុងការនាំចេញសរុប មានត្រឹម ៤,៤៨% ប៉ុណ្ណោះ ដោយការនាំចេញរបស់កម្ពុជាផ្ដោតជាសំខាន់លើវាយនភ័ណ្ឌ និងសម្លៀកបំពាក់ ដែលក្នុងប៉ុន្មានឆ្នាំថ្មីៗបានរីកលូតលាស់ជាខ្លាំង លើកលែងតែក្នុងឆ្នាំ២០០៨ និង ២០០៩ ដែលវាត្រូវប៉ះទង្គិចដោយវិបត្តិពីរគឺ វិបត្តិថ្លៃប្រេង និងវិបត្តិសេដ្ឋកិច្ចសាកល។

តារាង ២៖ ទំនិញនាំចេញកសិកម្មចម្បងៗរបស់កម្ពុជា ឆ្នាំ២០០២-០៩ (លានដុល្លារ)

| HS | **ឈ្មោះផលិតផល** | **2002** | **2003** | **2004** | **2005** | **2006** | **2007** | **2008** |
|---|---|---|---|---|---|---|---|---|
| 01 | សត្វរស់ | 2.38 | 2.21 | 2.42 | 0.51 | 5.51 | 1.61 | 6.13 |
| 03 | ត្រី និង សត្វវន្តជាតិ(ក្តាម គ្រុំកំពឹស) | 8.12 | 6.65 | 21.93 | 15.38 | 15.14 | 10.42 | 7.82 |
| 04 | ផលិតផលទឹកដោះគោ ស៊ុតបក្សី | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.05 | 0.57 |
| 06 | ដើមឈើរស់ និងរុក្ខជាតិផ្សេងទៀត | 0.01 | 0.01 | 0.04 | 0.01 | 0.11 | 0.03 | 0.05 |
| 07 | បន្លែ និងមើមឈើហូបបាន | 0.54 | 1.77 | 2.61 | 0.82 | 1.30 | 11.29 | 22.10 |
| 08 | ផ្លែឈើ និងគ្រាប់ឈើហូបបាន | 0.02 | 0.53 | 15.23 | 21.80 | 19.00 | 21.73 | 34.28 |
| 09 | កាហ្វេ តែ គ្រឿងទេស | 0.05 | 0.03 | 0.11 | 0.18 | 0.28 | 0.83 | 0.85 |
| 10 | ធញ្ញជាតិ | 4.57 | 2.61 | 6.97 | 4.09 | 5.94 | 10.66 | 36.73 |
| 14 | សម្ភារៈសម្រាប់វេញជារុក្ខជាតិ | 0.34 | 0.35 | 0.49 | 0.37 | 0.74 | 0.63 | 0.26 |
| 18 | កាកាវ និងរបស់កែច្នៃពីកាកាវ | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.001 |
| 40 | កៅស៊ូ និងរបស់ធ្វើពីកៅស៊ូ | 23.22 | 14.46 | 72.60 | 72.81 | 94.35 | 106.00 | 91.96 |
| 44 | ឈើ និងរបស់ធ្វើពីឈើ | 20.67 | 15.79 | 64.20 | 73.80 | 74.43 | 106.38 | 67.01 |
| 45 | ឈើស្នោ និងរបស់ធ្វើពីស្នោ | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |
| | ផលិតផលនាំចេញផ្សេងទៀត | 1875.3 | 2235.4 | 2758.0 | 3065.7 | 3796.9 | 4333.0 | 4694.4 |
| | **ទំនិញនាំចេញសរុប** | **1935.2** | **2279.8** | **2944.6** | **3255.5** | **4013.7** | **4602.6** | **4962.2** |

ប្រភព៖ UN Comtrade 2010 (mirror data), http://comtrade.un.org/

## ២.៤. ការប្រៀបធៀបក្នុងតំបន់៖ ឱកាសល្អ និងបញ្ហាប្រឈម

ក្នុងទសវត្សរ៍កន្លងទៅ ទិន្នផលស្រូវនៅកម្ពុជាមានកម្រិតទាប បើធៀបនឹងប្រទេសឯទៀតក្នុងតំបន់។ ទោះបីវានៅទាបត្រឹម ២,៩តោន/ហិកតាក្នុងឆ្នាំ២០០៩ក្តី ប៉ុន្តែមានការកើនឡើងខ្លះហើយ ពីឆ្នាំ២០០៥ ដល់ ២០០៩ ដោយសារការប្រើជី និងថ្នាំសម្លាប់សត្វចង្រៃបានកាន់តែប្រសើរ និងវិនិយោគបន្ថែមលើប្រព័ន្ធស្រោចស្រព (World Bank 2009: 8)។ ការប្រើធាតុចូលកាន់តែប្រសើរ និងគ្រាប់ពូជមានគុណភាពខ្ពស់ ក៏ដូចជា ការថយចុះការពឹងផ្អែកលើឧបករណ៍ និងសម្ភារៈបែបបុរាណ និងលើលក្ខខណ្ឌអាកាសធាតុតាមការវិនិយោគផ្នែកស្រោចស្រព (ជាលក្ខណៈសាធារណៈ ឯកជន ឬដោយកសិករខ្លួនឯង) អាចជួយឲ្យកម្ពុជាឡើងទាន់ប្រទេសឯទៀតក្នុងតំបន់)។ ដោយកសិករ ៨០% ជាអ្នកដាំស្រូវ ហើយភាពក្រីក្រមានកម្រិតខ្ពស់នៅជនបទ ដូច្នេះជំនួយគាំទ្ររបស់រដ្ឋាភិបាល និងវិស័យឯកជនតាមបែប កសាង-ដំណើរការ-ផ្ទេរ (Build-Operate-Transfer) នូវប្រព័ន្ធស្រោចស្រពជាដើម ព្រមទាំងជំនួយគាំទ្រពីដៃគូអភិវឌ្ឍន៍ និង NGOs ទាំងជាហេដ្ឋរចនាសម្ព័ន្ធរូបវ័ន្ត និងក្របខ័ណ្ឌច្បាប់ គឺសំខាន់បំផុតដើម្បីតាមទាន់ប្រទេសឯទៀតក្នុងតំបន់ និងជួយកសិករឲ្យចាកផុតពីភាពក្រីក្រ។ នៅខែមិថុនា ២០១០ រដ្ឋាភិបាលបានចេញគោលនយោបាយមួយសម្រាប់ជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។

រូបភាព ៧៖ ទិន្នផលស្រូវ ឆ្នាំ២០០០-០៩ (តោន/ហិកតា)




ប្រភព: FAO (2010)

រូបភាព ៨៖ ទិន្នផលផលិតផលកសិកម្មសំខាន់ៗមួយចំនួន ឆ្នាំ២០០៩ (តោន/ហិកតា)




ប្រភព៖ FAO (2010)

ដំណាំឯទៀតក៏មានសក្តានុពលរីកចម្រើនដែរ។ រូបភាព ៨ បង្ហាញថា កម្ពុជាជាជើងឯកមួយក្នុងផ្នែកទិន្នផលដំឡូងឈើនៅឆ្នាំ២០០៩ ហើយអាចប្រៀបផ្ទឹមជាមួយប្រទេសឯទៀតបានក្នុងទិន្នផលពោត និងសណ្តែកសៀង។ នៅឆ្នាំ២០០៩ ដំឡូងឈើនៅកម្ពុជាមានទិន្នផល ២២,៣តោន/ហិកតា គឺខ្ពស់ជាងមធ្យមភាគក្នុងតំបន់ (ក្រៅពីប្រទេសចិន) ត្រឹម ១៥,១តោន/ហិកតា។ ពោត និងសណ្តែកសៀង មានទិន្នផល ៤,៣តោន/ហិកតា និង ១,៥តោន/ហិកតា ឬខ្ពស់បន្តិចជាងមធ្យមភាគក្នុងតំបន់ត្រឹម ៤,១តោន/ហិកតា និង ១,៤តោន/ហិកតា។ ដូច្នេះ ដំឡូងឈើ ពោត និងសណ្តែកសៀង អាចមានសក្តានុពលសម្រាប់ផលិតកម្ម និងការនាំចេញ។ ទិន្នផលកៅស៊ូនៅកម្ពុជាត្រឹម ៩៤០គ.ក/ហិកតា វាទាបជាងមធ្យមភាគក្នុងតំបន់ (១,៣តោន/ហិកតា) ប៉ុន្តែខ្ពស់ជាងនៅម៉ាឡេស៊ី (៦៩៣គ.ក/ហិកតា) និងមីយ៉ាន់ម៉ា (៦១៦គ.ក/ហិកតា)។ ទោះមានទិន្នផលទាបក្តី ក៏ដំណាំកៅស៊ូបានកើនឡើងយ៉ាងខ្លាំងក្នុងប៉ុន្មានឆ្នាំថ្មីៗ ដោយសារតម្រូវការកៅស៊ូធម្មជាតិក្នុងពិភពលោកបានស្ទុះឡើងវិញហើយ បន្ទាប់ពីវិបត្តិសេដ្ឋកិច្ចសាកលលើកក្រោយនេះ។

ប៉ុន្តែការលំបាក និងឧបសគ្គរារាំងការរីកលូតលាស់នៅមានច្រើនទៀត ហើយខ្លះវាតឹងតែង និងអូសបន្លាយខ្លាំងជាងខ្លះទៀត និងត្រូវមានអន្តរាគមន៍ភ្លាមៗពីរដ្ឋាភិបាល (តារាង ៣)។

តារាង ៣៖ ឧបសគ្គទំនងកើតមានដល់ការអភិវឌ្ឍកសិកម្មនៅកម្ពុជា

| **បញ្ហាប្រឈមផ្ទៃក្នុង/ក្នុងស្រុក** | **ឧបសគ្គ/កត្តាខាងក្រៅ** |
|---|---|
| • បន្ទុកចំណាយក្រៅផ្លូវការខ្ពស់លើការនាំចេញ<br>• កង្វះហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព<br>• បច្ចេកវិទ្យាកម្រិតទាបក្នុងការដាំដុះ និងកែច្នៃ<br>• ចំណាយខ្ពស់លើធាតុចូល សមត្ថភាពនិងគុណភាពទាបនៃការកិននិងកែច្នៃ<br>• កន្លែងទុកដាក់ និងការស្តុកស្រូវមិនបានល្អ<br>• កង្វះឥណទានមានការប្រាក់ទាប<br>• កង្វះចំណាប់អារម្មណ៍លើបច្ចេកទេសដាំដុះថ្មីមានប្រសិទ្ធភាព និងកង្វះសន្ទុះចិត្តធ្វើពិពិធកម្មផលិតកម្ម<br>• សញ្ញាពាណិជ្ជកម្ម និងតំបន់ភូមិសាស្ត្រ មានចុះមិនគ្រប់គ្រាន់ ឬគ្មាន<br>• ចំណាយដឹកជញ្ជូនខ្ពស់ ដោយសារបញ្ហាហេដ្ឋារចនាសម្ព័ន្ធ<br>• កង្វះជំនាញម៉ាឃីតទីង និងប្រព័ន្ធព័ត៌មានទីផ្សារ<br>• គ្មានសញ្ញាសំគាល់<br>• បាត់បង់ព្រៃឈើដោយសារការពង្រីកដំណាំខ្លះ ដូចជាសណ្តែកសៀង | • ប្រទេសអ្នកប្រើប្រាស់ចម្បងៗជាច្រើនការពារទីផ្សារខ្លួន (ឧទាហរណ៍ ជប៉ុន កូរ៉េ ប្រទេសអាស៊ានខ្លះ)<br>• ប្រទេសតិចតួចផ្តល់លក្ខខណ្ឌអនុគ្រោះឲ្យកម្ពុជាចូលទីផ្សារគេ<br>• ការនាំចេញពឹងផ្អែកជាសំខាន់លើតម្រូវការ និងកន្លែងកិនស្រូវ នៅថៃ និងវៀតណាម<br>• ប្រទេសនាំចូលភាគច្រើន ទាមទារលិខិតពិសេសបញ្ជាក់សុវត្ថិភាពនាវា (Special Purpose Ship Safety Certificate) ដែលកម្ពុជាគ្មាន<br>• ទីផ្សារនាំចេញតូច (ថៃ និងវៀតណាម) និងភាគច្រើនសម្រាប់ការនាំចេញក្រៅផ្លូវការ |

ប្រភព៖ UNDP (2007)

# ៣
# ទំហំ និងលក្ខណៈនៃវិនិយោគបរទេសក្នុង វិស័យកសិកម្មនៅកម្ពុជា

បន្ទាប់ពីបានធ្វើអន្តរកាលទៅអនុវត្តរបបសេដ្ឋកិច្ចទីផ្សារសេរីនៅដើមទសវត្សរ៍១៩៩០មកកម្ពុជាបានចាត់វិធានការជំរុញវិនិយោគឯកជនទាំងក្នុងស្រុក និងពីបរទេស តាមរយៈការធ្វើឯកជននីយកម្មធនធានរបស់រដ្ឋ និងការអនុម័តច្បាប់ស្តីពីវិនិយោគក្នុងឆ្នាំ១៩៩៥ ដែលផ្តល់គ្រឿងលើកទឹកចិត្តខាងពន្ធដារនិងរដ្ឋបាល និងកិច្ចការពារដល់វិនិយោគិនក្នុងស្រុក និងបរទេស។ វិនិយោគបានចាប់ផ្តើមរីកដុះដាល និងកើនសន្ទុះនៅពេលកម្ពុជា ទទួលបានសន្តិភាពពិតប្រាកដ និងស្ថិរភាពនៅចុងទសវត្សរ៍១៩៩០ ក្រោយពេលពួកខ្មែរក្រហមបានដួលរលំ ហើយកងទ័ពខ្មែរក្រហមបានធ្វើសមាហរណកម្មចូលក្នុងកងទ័ពរបស់រដ្ឋាភិបាល។

ទិន្នន័យបានពីក្រុមប្រឹក្សាវិនិយោគកម្ពុជា (CIB) នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) សម្រាប់រយៈពេលពីឆ្នាំ២០០០ ដល់ មិថុនា ២០១០ បង្ហាញពីនិន្នាការកំណើនវិនិយោគ។ ចំណុចផ្លាស់ប្តូរចម្បងបំផុតក្នុងវិនិយោគសរុបកើតឡើងក្នុងឆ្នាំ២០០៥ ដោយសារជាសំខាន់វិនិយោគដ៏ច្រើនសម្បើមពីប្រទេសចិន ថៃ និងកូរ៉េ។ វិនិយោគសរុបបន្តរីកចម្រើនរហូតដល់ឆ្នាំ២០០៨ ប៉ុន្តែបានថយល្បឿននៅឆ្នាំ២០០៩ ដោយសារផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសាកលមកលើសេដ្ឋកិច្ចកម្ពុជា ពោលគឺនៅឆ្នាំនោះវាបានធ្លាក់ចុះទាបជាងឆ្នាំ២០០៨ ពីរដង។ Rostow (1960) និងអ្នកស្រាវជ្រាវជាច្រើនទៀតដែលមានចុះក្នុងឯកសាររបស់ Todaro and Smith (2003: 115) បានលើកថា ប្រទេសទាំងឡាយដែលអាចសន្សំប្រាក់ឬបង្កើតវិនិយោគបានប្រហែល ២០%នៃ ផសស អាចមានកំណើនលឿនជាងប្រទេសដែលសន្សំបានតិចជាងនេះ ហើយកំណើននេះនឹងមាននិរន្តរភាព។ ប៉ុន្តែការគន់គូរបែបនេះពិបាកអនុវត្តលើកម្ពុជា ពីព្រោះគ្មានទិន្នន័យពីការអនុវត្តជាក់ស្តែងនូវគម្រោងវិនិយោគបានទទួលការអនុម័តហើយ។

វិនិយោគឯកជនក្នុងស្រុក និងពីបរទេស មានទំហំប្រហាក់ប្រហែលគ្នាពីឆ្នាំ២០០០ ដល់ ២០១០ ហើយ FDI មានចំណែកជាមធ្យម ៥៨% ក្នុងវិនិយោគសរុប។ FDI មាននិន្នាការកើនឡើង ប៉ុន្តែបានធ្លាក់ចុះនៅឆ្នាំ២០០៩ ដោយសារវិបត្តិសេដ្ឋកិច្ចសាកល។ ក្នុងចំណោមវិនិយោគិនបរទេស ប្រទេសចិនឈានមុខគេ បន្ទាប់មកគឺ កូរ៉េ សហរដ្ឋអាមេរិក ថៃ វៀតណាម ម៉ាឡេស៊ី សិង្ហបុរី និង តៃវ៉ាន់។ វិនិយោគិនជាប្រពៃណី ដូចជា ចិន កូរ៉េ ម៉ាឡេស៊ីនិង ថៃ បានបណ្តាក់ទុននៅកម្ពុជា តាំងពីឆ្នាំ២០០០ មក ដែលបង្ហាញពីកំណើនទំនុកចិត្តលើបរិយាកាសវិនិយោគនៅកម្ពុជា។ ម្យ៉ាងទៀត ប្រទេសមួយចំនួនដូចជា វៀតណាម ជប៉ុន និង សហរដ្ឋអាមេរិក កាន់តែយកចិត្តទុកដាក់ខ្លាំងឡើងក្នុងពីរបីឆ្នាំកន្លងទៅ និងសញ្ញាល្អសម្រាប់កំណើនផលិតកម្មសរុបក្នុងរយៈពេលមធ្យម និងវែង ទោះបីមានការប៉ះទង្គិចខ្លះក្នុងឆ្នាំ២០០៨ និង ២០០៩ ក្តី។

## ៣.១. វិនិយោគទទួលការអនុម័ត គិតតាមវិស័យ

គិតតាមវិស័យ ទេសចរណ៍ និងឧស្សាហកម្ម ស្រូបយកវិនិយោគបានច្រើនជាងគេក្នុងមួយទសវត្សរ៍កន្លងទៅ ហើយបន្ទាប់មកគឺ សេវាកម្ម។ ទេសចរណ៍ដែលជាជើងឯក មានចំណែកជាមធ្យម ៣៥% ក្នុងវិនិយោគសរុបពីឆ្នាំ២០០០ ដល់ មិថុនា ២០១០ ហើយបន្ទាប់មកគឺ ឧស្សាហកម្ម (៣២%) និង សេវាកម្ម (២៥%)។ វិនិយោគក្នុងកសិកម្មមានល្បឿនយឺត។ តាមតួលេខវិនិយោគអនុម័តបង្គរទុក (accumulation of approved investment) ទេសចរណ៍ឈានមុខគេ ដោយមានចំណែក ៥៨% បន្ទាប់មកគឺ សេវាកម្ម(១៩%) និង ឧស្សាហកម្ម(១៧%) ហើយ កសិកម្មមានចំណែកតូចជាងគេ(៦%)។ លំហូរមូលធនច្រើនៗទៅក្នុងទេសចរណ៍ អាចជាលទ្ធផលនៃ គោលនយោបាយបើកចំហជើងមេឃរបស់រដ្ឋាភិបាលក្នុងឆ្នាំ១៩៩៧ ការសម្រេចបានសន្តិភាពនិងស្ថិរភាពនយោបាយក្នុងឆ្នាំ១៩៩៨ និងការកែលំអហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាបណ្តើរៗ ជាពិសេសការតភ្ជាប់ដោយផ្លូវថ្នល់ និងស្ពាន។

តារាង ៤៖ វិនិយោគអនុម័តដោយ CIB ឆ្នាំ២០០០-១០ (គិតជាទ្រព្យជាប់លាប់ ជាលានដុល្លារ)

| ប្រទេស | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | 2000 – មិថុនា 10 | ចំណែក |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្ពុជា | 57 | 65 | 93 | 185 | 76 | 366 | 2081 | 1323 | 3951 | 3764 | 151 | 12112 | 45.6 |
| ជប៉ុន | 0 | - | 2 | - | 2 | - | 2 | 113 | 7 | 5 | - | 132 | 0.5 |
| កូរ៉េ | 19 | 2 | 79 | 2 | 5 | 56 | 1010 | 148 | 1242 | 121 | 35 | 2720 | 10.2 |
| តៃវ៉ាន់ | 19 | 57 | 7 | 1 | 14 | 10 | 48 | 35 | 19 | 27 | 39 | 276 | 1.0 |
| ហុងកុង | 5 | 1 | 2 | 5 | - | 1 | 4 | 26 | - | 7 | 17 | 69 | 0.3 |
| ចិន | 28 | 5 | 24 | 34 | 83 | 454 | 757 | 180 | 4370 | 891 | 60 | 6887 | 25.9 |
| សិង្ហបុរី | 8 | - | 1 | 4 | 5 | 25 | 12 | 2 | 52 | 272 | 6 | 388 | 1.5 |
| ម៉ាឡេស៊ី | 2 | 51 | 1 | 5 | 33 | 26 | 28 | 241 | 3 | 7 | 110 | 507 | 1.9 |
| ថៃ | 26 | 15 |  | 7 | 1 | 81 | 100 | 108 | 26 | 178 | 2 | 544 | 2.0 |
| វៀតណាម | - | - | 24 | - | - | - | 31 | 156 | 21 | 210 | 83 | 525 | 2.0 |
| សហរដ្ឋអាមេរិក | 12 | 6 | - | - | 2 | 4 | 62 | 3 | 672 | 1 | 2 | 764 | 2.9 |
| បារាំង | 5 | - | - | 6 | 3 | 8 | - | 35 | 38 | 50 | - | 145 | 0.5 |
| អង់គ្លេស | - | - | - | - | - | - | - | - | - | 2 | 1 | 3 | 0.0 |
| ផ្សេងទៀត | 35 | 3 | 5 | 1 | 5 | 18 | 320 | 298 | 415 | 330 | 83 | 1514 | 5.7 |
| សរុប | 217 | 205 | 238 | 251 | 229 | 1050 | 4454 | 2667 | 10818 | 5865 | 591 | 26586 | 100 |
| FDI | 160 | 140 | 145 | 66 | 153 | 684 | 2373 | 1345 | 6866 | 2101 | 440 | 14474 |  |

កំណត់សំគាល់៖ ទិន្នន័យសម្រាប់ឆ្នាំ២០១០ = មករា ដល់ មិថុនា

ប្រភព៖ CDC (2010)

រូបភាព ៩៖ ចំណែកនៃវិនិយោគបានអនុម័ត គិតតាមវិស័យ ឆ្នាំ២០០០ ដល់ មិថុនា ២០១០ (លានដុល្លារ)




ប្រភព៖ CDC (2010)

រូបភាព ១០៖ ចំណែកនៃវិនិយោគបានអនុម័ត គិតតាមវិស័យ ឆ្នាំ២០០០ ដល់ មិថុនា ២០១០




ប្រភព៖ CDC (2010)

កំណើនយឺតនៃវិនិយោគខាងកសិកម្មពីឆ្នាំ២០០០ ដល់ ២០១០ អាចមកពីវិនិយោគផ្នែកនេះជាដំណើរការរយៈពេលវែង ហុចផលត្រឡប់តិច (weak appropriability of return) និងត្រូវប្រឈមនឹងបញ្ហាសិទ្ធិលើទ្រព្យសម្បត្តិកំណត់មិនច្បាស់ជាទូទៅ ដែលរារាំងសហគ្រាសក្នុងការប្រើប្រាស់ដី និងទ្រព្យសម្បត្តិជាវត្ថុបញ្ចាំ ដើម្បីទទួលបានឥណទាន (World Bank 2006: 74)។

### ៣.២. FDI ក្នុងកសិកម្ម បែងចែកតាមសញ្ជាតិ

តារាង ៥ បង្ហាញពីការចូលរួមយ៉ាងច្រើននៃ FDI ក្នុងកសិកម្មនៅកម្ពុជាពីឆ្នាំ២០០០ ដល់ ២០១០ ដោយមានចំណែកជាមធ្យមគិតជាទ្រព្យជាប់លាប់ ៧៨,៤% និងពីកំណើនយឺត ប៉ុន្តែទៀងទាត់នៃវិនិយោគឯកជនក្នុងស្រុក ដែលមានជាមធ្យម ២១,៦% ក្នុងរយៈពេលនោះដែរ។ កំណើនគួរឲ្យកត់សំគាល់នៃវិនិយោគឯកជនក្នុងស្រុក និងវិនិយោគបរទេស អាចមើលឃើញច្បាស់ក្នុងប៉ុន្មានឆ្នាំថ្មីៗ ដែលអាចផុសចេញពីកំណើនតម្រូវការក្នុងពិភពលោកជាខ្លាំងនូវកៅស៊ូធម្មជាតិជាពិសេសពី ចិន ឥណ្ឌា ជប៉ុន និងសហរដ្ឋអាមេរិក ដោយសារការឡើងថ្លៃកៅស៊ូសិប្បនិមិត្ត បន្ទាប់ពីប្រេងកាតបានស្ទុះឡើងថ្លៃនៅចុងឆ្នាំ២០០៧ និងឆ្នាំ២០០៨ តម្រូវការជីវឥន្ធនៈផលិតចេញពីដំណាំធម្មតាដូចជាដូងប្រេង ឬពោត និងតម្រូវការស្បៀងដូចជាអង្ករ ពីប្រទេសនាំចូលស្បៀងអាហារក្នុងតំបន់ និងពិភពលោក។

ថ្វីបើគម្រោងរបស់បរទេស វាមានតម្លៃជាទឹកប្រាក់តិច បើធៀបនឹង FDI សរុបក្នុងវិស័យចម្បងទាំងបី ពោលគឺទេសចរណ៍ ឧស្សាហកម្ម និងសេវាកម្មក្តី ក៏ផ្ទៃដីសរុប ទុកធ្វើកសិកម្ម វាធំគួរសមអាចប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសន្តិសុខស្បៀងនៅកម្ពុជា។

តាមទិន្នន័យសម្រាប់អំឡុងឆ្នាំ២០០០ ដល់ ២០១០ ដូចមានចុះក្នុងតារាង ៥ ប្រទេសចិនជាវិនិយោគិនធំបំផុតទី២ ក្នុងកសិកម្ម ដោយមានចំណែកជាទ្រព្យជាប់លាប់ ១៧,៦% បន្ទាប់ពីថៃ ដែលមាន ២១,៧%។ ការយកចិត្តទុកដាក់លើកសិកម្មនៅកម្ពុជា ក៏ឃើញកើនឡើងដែរពីប្រទេស ដូចជា វៀតណាម (១៤,៨%) កូរ៉េ (៦,៥%) សិង្ហបុរី (៤,៨%) ឥណ្ឌា (៤,៤%) សហរដ្ឋអាមេរិក (៣,៦%) និងជប៉ុន (១,៨%)។ ប្រទេសទាំងអស់នេះចូលរួមជាសំខាន់ក្នុងដំណាំ និងព្រៃឈើ ដូចមានពិភាក្សានៅខាងក្រោម។

ថ្វីបើការចូលរួមរបស់បរទេសដែលស្ទុះឡើង ដូច្នេះអាចអំណោយផលល្អនៅកម្រិតម៉ាក្រូ ប៉ុន្តែនៅកម្រិតមីក្រូអាចមាននិន្នាការអវិជ្ជមាន បើពុំមានយន្តការសម្របសម្រួលវិនិយោគល្អ និងប្រយ័ត្នប្រយែង ការវាយតម្លៃពីផលប៉ះពាល់លើបរិស្ថាន និងការស្រាវជ្រាវដល់កន្លែងជាទៀងទាត់ដែលគិតគូរដល់ជនក្រីក្រ បរិស្ថាន និងផ្តល់អាទិភាពដល់បញ្ហាសន្តិសុខស្បៀង។

### ៣.៣. វិនិយោគក្នុងកសិកម្ម បែងចែកតាមអនុវិស័យ

នៅCDCពុំមានទម្រង់សម្រាប់ផ្តល់ទិន្នន័យកសិកម្មដោយបែងចែកតាមអនុវិស័យនោះទេ ដូច្នេះការបែងចែកជាប្រភេទត្រូវធ្វើឡើងដោយប្រើប្រភពទិន្នន័យផ្សេងៗទៀត។ ការសិក្សានេះបានបែងចែកកសិកម្ម ទៅជាដំណាំ សត្វចិញ្ចឹម ជលផលព្រៃឈើផ្លែឈើការកែច្នៃស្បៀងអាហារ ។ល។នេះជាការព្យាយាមលើកទី១ហើយលទ្ធផលអាចខុសគ្នានៅក្នុងការងារទៅអនាគត យោងតាមឧបសគ្គជាច្រើនចំពោះការធ្វើចំណាត់ថ្នាក់តាមអនុវិស័យ។ ឧទាហរណ៍ ចំការកៅស៊ូ និងអាកាស្យា ដែលអាចដាក់ចូលអនុវិស័យដំណាំ ឬអនុវិស័យព្រៃឈើ ក្នុងការសិក្សានេះគឺបានដាក់ចូលជាមួយដំណាំ។

ដូចមានបញ្ជាក់ក្នុង ផ្នែក ៣.២ ថៃស្ថិតនៅលំដាប់ទី១ សម្រាប់វិនិយោគក្នុងកសិកម្មនៅកម្ពុជា ហើយបន្ទាប់មកមាន ចិន វៀតណាម និង កូរ៉េ។ តាមការបែងចែកកសិកម្មជាប្រាំអនុវិស័យ យើងឃើញថា វិនិយោគិនបរទេសចូលរួមជាសំខាន់ក្នុង ដំណាំ ព្រៃឈើ និងផ្សេងទៀត។

ក្នុងអនុវិស័យដំណាំ ថៃ វៀតណាម និង ចិន មានវិនិយោគជាទ្រព្យជាប់លាប់ច្រើនជាងគេ។ វិនិយោគិនថៃច្រើនយកចិត្តទុកដាក់ខ្លាំងលើអំពៅ ដែលគេប៉ាន់ថា បង្កើតការងារប្រហែល ១៣.៥០០ និងក្នុងកម្រិតទាបជាងលើកៅស៊ូ ដូងប្រេង និងដំឡូងឈើ។ សហគ្រាសភាគច្រើនចូលមកក្នុងទម្រង់ជាកម្មសិទ្ធិថៃសុទ្ធ ឬធ្វើដៃគូជាមួយសហគ្រាសកម្ពុជា។

ពួកវិនិយោគិនវៀតណាមហាក់ដូចផ្តោតខ្លាំងជាងលើចំការកៅស៊ូក្នុងប៉ុន្មានឆ្នាំថ្មីៗ ដែលគេប៉ាន់ស្មានថាបង្កើតការងារបានប្រហែល ១១.០០០ បន្ទាប់មកលើស្វាយចន្ទី ដូងប្រេង ដំឡូងឈើ និងអំពៅ និងមានរចនាសម្ព័ន្ធកម្មសិទ្ធិស្រដៀងគ្នានឹងវិនិយោគិនថៃដែរ។ ចិនផ្តោតជាសំខាន់លើកៅស៊ូ និងស្វាយចន្ទី ហើយក្នុងកម្រិតទាបជាងលើដូងប្រេង អំពៅ និងដំឡូងឈើ ហើយវិនិយោគចិនភាគច្រើន មានលក្ខណៈជាកម្មសិទ្ធិចិនសុទ្ធសាធ។

តារាង ៥៖ វិនិយោគខាងកសិកម្មអនុម័តដោយ CIB ឆ្នាំ២០០០-១០ (ជាលានដុល្លារនៃទ្រព្យជាប់លាប់)

| **ប្រទេស** | **2000** | **2001** | **2002** | **2003** | **2004** | **2005** | **2006** | **2007** | **2008** | **2009** | **2010** | **2000–មិថុនា 10** | **ចំណែក** |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្ពុជា | 3.6 | 0.4 | 0.6 | 0.0 | 4.1 | 10.4 | 141 | 96.0 | 38.3 | 41.9 | 35.5 | 371.9 | 21.6 |
| ជប៉ុន | - | - | - | - | - | - | - | 31.2 | - | - | - | 31.2 | 1.8 |
| កូរ៉េ | - | - | 11.4 | - | - | - | - | 59.4 | 5.8 | 3.4 | 32.7 | 112.7 | 6.5 |
| តៃវ៉ាន់ | - | - | - | - | - | - | - | - | - | - | 3.0 | 3.0 | 0.2 |
| ឥណ្ឌា | - | - | - | - | - | - | - | - | - | 75.0 | | 75.0 | 4.4 |
| ចិន | - | - | - | - | - | 3.7 | 72.8 | 33.2 | 18.6 | 134 | 41.9 | 303.9 | 17.6 |
| សិង្ហបុរី | - | - | - | - | - | - | - | - | - | 82.1 | - | 82.1 | 4.8 |
| ម៉ាឡេស៊ី | - | - | - | - | 8.2 | - | - | - | - | - | - | 8.2 | 0.5 |
| ថៃ | - | - | - | - | - | - | 73.1 | 104 | 22.8 | 173 | - | 373.1 | 21.7 |
| វៀតណាម | - | - | - | - | - | - | 27.4 | 43.1 | 20.9 | 104 | 59.8 | 254.8 | 14.8 |
| សហរដ្ឋអាមេរិក | 1.3 | - | - | - | - | - | 58.5 | - | - | - | 1.7 | 61.5 | 3.6 |
| អ៊ីស្រាអែល | - | - | - | - | - | - | - | 1.7 | - | - | - | 1.7 | 0.1 |
| កាណាដា | - | - | - | - | - | 5.5 | - | - | - | - | - | 5.5 | 0.3 |
| បារាំង | - | - | - | - | - | - | - | - | 6.2 | - | - | 6.2 | 0.4 |
| អង់គ្លេស | - | - | - | - | - | - | - | - | - | 2.1 | - | 2.1 | 0.1 |
| ដាណឺម៉ាក | - | - | - | - | - | - | - | - | - | - | 29.5 | 29.5 | 1.7 |
| សរុប | 4.9 | 0.4 | 12.0 | 0.0 | 12.3 | 19.6 | 373 | 369 | 113 | 615 | 204 | 1722.4 | |
| FDI | 1.3 | 0.0 | 11.4 | 0.0 | 8.2 | 9.1 | 232 | 273 | 74 | 573 | 169 | 1350.5 | |
| ចំណែកក្នុង FDI | 25.5 | 0.0 | 95.0 | 0.0 | 66.6 | 46.6 | 62.2 | 74.0 | 66.0 | 93.2 | 82.6 | 78.4 | |

ប្រភព៖ CDC (2010)

តារាង ៦៖ វិនិយោគបង្គរទុកតាមអនុវិស័យកសិកម្មពីឆ្នាំ២០០០ ដល់ មិថុនា ២០១០ (លានដុល្លារនៃទ្រព្យជាប់លាប់)

| ប្រទេស | ដំណាំ | សត្វចិញ្ចឹម | ជលផល | ព្រៃឈើ | ផ្សេងៗ | សរុប | ចំណែក |
|---|---|---|---|---|---|---|---|
| កម្ពុជា | 174.0 | 3.6 | 0.4 | 72.2 | 121.8 | 371.9 | 21.6 |
| កាណាដា | - | - | - | 5.5 | - | 5.5 | 0.3 |
| ចិន | 194.6 | - | - | 77.3 | 32.1 | 303.9 | 17.6 |
| បារាំង | 6.2 | - | - | - | - | 6.2 | 0.4 |
| អ៊ីស្រាអែល | 1.7 | - | - | - | - | 1.7 | 0.1 |
| ជប៉ុន | 31.2 | - | - | - | - | 31.2 | 1.8 |
| កូរ៉េ | 90.1 | - | - | - | 22.6 | 112.7 | 6.5 |
| ម៉ាឡេស៊ី | 2.6 | - | - | - | 5.6 | 8.2 | 0.5 |
| សិង្ហបុរី | 82.1 | - | - | - | - | 82.1 | 4.8 |
| តៃវ៉ាន់ | - | - | - | - | 3.0 | 3.0 | 0.2 |
| ថៃ | 327.0 | - | - | 46.0 | - | 373.1 | 21.7 |
| សហរដ្ឋអាមេរិក | 1.3 | - | - | 18.3 | 41.9 | 61.5 | 3.6 |
| វៀតណាម | 236.6 | - | - | 18.2 | - | 254.8 | 14.8 |
| ឥណ្ឌា | - | - | - | - | 75.0 | 75.0 | 4.4 |
| អង់គ្លេស | - | - | - | - | 2.1 | 2.1 | 0.1 |
| ដាណឺម៉ាក | - | - | - | 29.5 | - | 29.5 | 1.7 |
| សរុប | 1147.4 | 3.6 | 0.4 | 266.9 | 304.1 | 1722.4 | 100.0 |
| FDI | 973.4 | 0.0 | 0.0 | 194.8 | 182.3 | 1350.5 | |
| ចំណែកក្នុង FDI | 84.8 | 0.0 | 0.0 | 73.0 | 60.0 | 78.4 | |

ប្រភព៖ CDC (2010)

ក្រៅពីតួអង្គចម្បងៗខាងលើ ជប៉ុន កូរ៉េ និង សិង្ហបុរី ក៏ចូលរួមចំណែកគួរឲ្យកត់សំគាល់ក្នុងវិនិយោគលើដំណាំដែរ។ វិនិយោគិនជប៉ុនម្នាក់បានរួមដៃគូជាមួយ ថៃ(៥០%) កម្ពុជា(២០%) និង ចិន(១៥%) ធ្វើចំការអំពៅក្នុងខេត្តកោះកុង នៅភាគនិរតីប្រទេសកម្ពុជា ជិតព្រំដែនថៃ។ គម្រោងនេះ CIB បានអនុម័តយល់ព្រមនៅខែវិច្ឆិកា ២០០៧។ វិនិយោគិនកូរ៉េចូលចិត្តធ្វើដំណាំកៅស៊ូ ដំឡូងឈើ និងស្វាយចន្ទី ហើយគម្រោងពួកគេច្រើនជាកម្មសិទ្ធិរបស់កូរ៉េសុទ្ធ ឬចូលដៃគូជាមួយកម្ពុជា។ សិង្ហបុរីមានគម្រោងពីរ ដែល CIB បានអនុម័តនៅខែកក្កដា ២០០៩ និងសុទ្ធតែខាងកៅស៊ូ និងដំឡូងឈើ និងជាកម្មសិទ្ធិរបស់សិង្ហបុរី។

បារាំង ម៉ាឡេស៊ី អ៊ីស្រាអែល និង សហរដ្ឋអាមេរិក ក៏មានចូលមកវិនិយោគខាងកសិកម្មដែរ។ បារាំងចូលរួមក្នុងដំណាំស្រូវ និងរោងចក្រកិនស្រូវ នៅខែវិច្ឆិកា ២០០៨ ក្នុងលក្ខណៈជាក្រុមហ៊ុនចម្រុះទុន (joint venture)។ ម៉ាឡេស៊ីធ្វើសហគ្រាសចម្រុះទុនមួយជាមួយ កម្ពុជា(១២,៥%) ដើម្បីដាំដូងប្រេង កៅស៊ូ និងស្វាយចន្ទី នៅខែកក្កដា ២០០៤។ អ៊ីស្រាអែលក្នុងលក្ខណៈជាសហគ្រាសចម្រុះទុន បានចាប់ផ្តើមធ្វើចំការដំឡូងឈើនៅខែមីនា ២០០៧ ហើយសហរដ្ឋអាមេរិក (ទ្រព្យជាប់លាប់អាមេរិក ១០០%) បានចូលមកធ្វើចំការស្វាយចន្ទី និងដំឡូងឈើ នៅខែកុម្ភៈ ២០០០។

ខាងផ្នែកព្រៃឈើ ចិន និងថៃ ជាវិនិយោគិនចម្បងគេ។ វិនិយោគិនចិនផ្តោតលើផលិតកម្មគ្រាប់ឈើ pistachio និងដើមអាកាស្យា ដោយធ្វើវិនិយោគទ្រព្យជាប់លាប់របស់ខ្លួនផ្ទាល់នៅក្នុង ELCs ។ ចំពោះវិនិយោគិនថៃវិញ គេមិនច្បាស់ទេថា តើដាំដើមឈើប្រភេទណា។ វៀតណាមក៏ដូចជាដាណឺម៉ាក និងកាណាដា ក៏មានចូលរួមដែរ។ វិនិយោគវៀតណាមមានទម្រង់ជាក្រុមហ៊ុនចម្រុះទុនជាមួយ កម្ពុជា(៣០%) ធ្វើចំការអាកាស្យា ដែល CIB បានអនុម័តយល់ព្រមនៅខែមីនា ២០១០។ កាណាដាចូលមកដាំចំការម៉ៃសាក់ ដោយធ្វើជាដៃគូជាមួយ ចិន(៤០%) ក្នុងក្រុមហ៊ុនមួយឈ្មោះ GG World Group Development[២] ដែល CIB បានអនុម័តយល់ព្រមនៅខែធ្នូ ២០០៥។ ដាណឺម៉ាកក៏មានចូលរួមធ្វើចំការម៉ៃសាក់ដែរ ដោយប្រើទ្រព្យជាប់លាប់របស់ខ្លួនផ្ទាល់ ១០០% ហើយគម្រោងនេះ CIB បានអនុម័ត នៅខែ មេសា ២០១០។

ក្រៅពីដំណាំ និងព្រៃឈើ ក៏មានវិនិយោគបរទេសមួយចំនួនដែរក្នុងអនុវិស័យផ្សេងទៀត មានជាអាទិ៍ កសិ-ឧស្សាហកម្មជាទូទៅ ចំណីសត្វ សម្ងួតពោត កែច្នៃកៅស៊ូក្រេប រោងចក្រចម្រាញ់ប្រេងឆានិងការអភិវឌ្ឍ ផលិតកម្មតែថ្នាំ ចំការនិងការកែច្នៃផ្កា hollyhock ចំការអំពៅ និងការចម្រាញ់ស្ករ។ វិនិយោគិនមកពីចិន និងសហរដ្ឋអាមេរិក បានចូលរួមក្នុងកសិ-ឧស្សាហកម្មទូទៅ រីឯកូរ៉េធ្វើវិនិយោគក្នុងការដាំដុះនិងសម្ងួត ចំការនិងការកែច្នៃផ្កា hollyhock និង ចំណីសត្វ។ ម៉ាឡេស៊ីមានគម្រោងអភិវឌ្ឍន៍ និងចម្រាញ់ប្រេងឆាមួយដែល CIB បានអនុម័តកាលពីខែមិថុនា ២០០៤ ក្នុងទម្រង់ជាក្រុមហ៊ុនចម្រុះទុនជាមួយ កម្ពុជា(៤០%) ហើយ តៃវ៉ាន់បានវិនិយោគជាទ្រព្យជាប់លាប់របស់ខ្លួនក្នុងរោងចក្រធ្វើតែថ្នាំមួយ នៅខែមីនា ២០១០។ សហរដ្ឋអាមេរិកមានគម្រោងមួយធ្វើចំការនិងកែច្នៃផ្កា hollyhock ហើយឥណ្ឌាមានគម្រោងចម្រុះមួយ (ធ្វើចំការអំពៅនិងចម្រាញ់ស្ករ ផលិតអេតាណុលនិងថាមពល) គឺ ក្រុមហ៊ុនមានអាជ្ញាប័ណ្ណឈ្មោះ Kamadhenu Venture[៣] នៅខេត្តក្រចេះ។

### ៣.៤. FDI **ផ្នែកកែច្នៃស្បៀងអាហារ**

ក្នុងទសវត្សរ៍កន្លងទៅនេះ វិនិយោគិនបរទេសមិនបានចូលរួមច្រើនទេក្នុងផ្នែកកែច្នៃស្បៀងអាហារ ព្រោះមានចំណែកតែ ២៨,៧% ក្នុងទ្រព្យជាប់លាប់សរុបនៃអនុវិស័យនេះ។ តាមនេះ កម្ពុជាក៏ត្រូវនាំមុខដោយចូលជាដៃគូជាមួយវិនិយោគិនបរទេសដូចជាពី វៀតណាម សិង្ហបុរី និង ថៃ។ អូស្ត្រាលី បានតម្លើងរោងចក្រផលិតទឹកសណ្តែកសៀងដោយប្រើទ្រព្យជាប់លាប់ផ្ទាល់របស់ខ្លួននៅឆ្នាំ២០០៣ និងបានចូលជាដៃគូជាមួយ កម្ពុជា(មានហ៊ុន ៥១%) ក្នុងការផលិតស្រាបៀរ។

កាណាដា បានចាប់ផ្តើមគម្រោងផលិតស្រាបៀរមួយ នៅឆ្នាំ២០១០ ដោយប្រើទ្រព្យជាប់លាប់ ១០០% របស់ខ្លួន ហើយសិង្ហបុរីបានរួមដៃគូជាមួយ កម្ពុជា(១០%) ដើម្បីផលិតទឹកសុទ្ធដាក់ដប។ ថៃបានរួមដៃគូជាមួយ កម្ពុជា(៤០%) ដើម្បីផលិតមីកញ្ចប់ និងម្ហូបអាហារឆាប់ឆ្អិនផ្សេងទៀត ហើយ វៀតណាមក៏រួមដៃគូជាមួយ កម្ពុជា(៣០%) ដើម្បីផលិតស្រាបៀរ ភេសជ្ជៈគ្មានជាតិស្រា និងទឹកសុទ្ធ។ ចិនវិនិយោគមូលធនផ្ទាល់ ១០០% ក្នុងការកែច្នៃម្ហូបសមុទ្រនៅឆ្នាំ២០០៤។ សរុបមក ក្រៅពីអូស្ត្រាលី និងកាណាដា មានតែប្រទេសក្នុងតំបន់ទេ ដែលហាក់យកចិត្តទុកដាក់លើការកែច្នៃស្បៀងអាហារ។

---

[២] www.elc.maff.gov.kh/comprofiles/stgg.html ( accessed 10th November 2010 ).

[៣] MAFF has a different name for this: www.elc.maff.gov.kh/comprofiles/krtcarmad.html. ( accessed 10th November 2010 )

តារាង ៧៖ វិនិយោគជាទ្រព្យជាប់លាប់ក្នុងការកែច្នៃស្បៀងអាហារ ឆ្នាំ២០០០ ដល់ មិថុនា ២០១០(លានដុល្លារ)

| **ប្រទេស** | 2000 | 2001 | 2003 | 2004 | 2007 | 2008 | 2009 | 2010 | 2000–មិថុនា 10 | **ចំណែក** |
|---|---|---|---|---|---|---|---|---|---|---|
| អូស្ត្រាលី | - | | 0.7 | | 9.0 | | | | 9.7 | 13.0 |
| កម្ពុជា | - | 0.8 | | | 10.1 | 3.7 | 8.5 | 30.2 | 53.3 | 71.3 |
| កាណាដា | - | | | | | | | 4.3 | 4.3 | 5.7 |
| ចិន | - | | | 0.7 | | | | | 0.7 | 0.9 |
| សិង្ហបុរី | - | | | | | | | 3.8 | 3.8 | 5.1 |
| ថៃ | - | 1.2 | | | | | | | 1.2 | 1.6 |
| វៀតណាម | - | | | | 1.7 | | | | 1.7 | 2.3 |
| សរុប | - | 2.0 | 0.7 | 0.7 | 20.9 | 3.7 | 8.5 | 38.3 | 74.7 | |
| FDI | - | 1.2 | 0.7 | 0.7 | 10.8 | 0.0 | 0.0 | 8.1 | 21.5 | |
| ចំណែកក្នុង FDI | | 60.0 | 100.0 | 100.0 | 51.5 | 0.0 | 0.0 | 21.2 | 28.7 | |

ប្រភព: CDC (2010)

សរុបមក ក្នុងទសវត្សរ៍កន្លងទៅ វិនិយោគជាទ្រព្យជាប់លាប់ក្នុងកសិកម្មមានចំណែកតូចត្រឹម ៦% តែមានស្ថិរភាព។ ចំណូលត្រឡប់ទាបលើវិនិយោគ គួបផ្សំនឹងសិទ្ធិលើទ្រព្យកំណត់មិនច្បាស់ អាចរាំងស្ទះដល់វិនិយោគឯកជន និងបរទេស ក្នុងអនុវិស័យកែច្នៃស្បៀងអាហារ។

## ៣.៥. ការចូលរួមរបស់វិនិយោគិនបរទេសក្នុង ELCs

ដោយសារពុំមានទិន្នន័យ CDC ស្តីពី ទំហំដី/ចំការរបស់គម្រោងវិនិយោគបរទេស និងការខុសគ្នាខ្លះរវាងទិន្នន័យ CDC និង វេបសាយ MAFF[៤] ការសិក្សានេះបានស្រាវជ្រាវលំអិតលើទិន្នន័យកត់ត្រាដោយ MAFF ដើម្បីស្វែងយល់ពីទំហំ FDI ក្នុងកសិកម្ម ជាពិសេសក្នុងទម្រង់ជា ELCs ដើម្បីកំណត់ពីឥទ្ធិពលនៃ FDI ទៅលើស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច បរិស្ថាន និងសន្តិសុខស្បៀងនៅកម្ពុជា។

វិនិយោគសាធារណៈតាមរយៈ ការជួលដីឯកជនរបស់រដ្ឋក្នុងទម្រង់ជា ELCs ទៅឲ្យវិនិយោគិនក្នុងស្រុក និងបរទេស អាចឃើញច្បាស់តាំងពីឆ្នាំ១៩៩៥ គឺមុនការប្រកាសឲ្យប្រើច្បាប់ភូមិបាលឆ្នាំ២០០១ ផង។ យោងតាមអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី២៧ ធ្នូ ២០០៥[៥] ELCs សំដៅដល់យន្តការមួយដើម្បីផ្តល់ដីឯកជនរបស់រដ្ឋតាមរយៈកិច្ចសន្យាជាក់លាក់មួយ ទៅឲ្យ សម្បទានិកសម្រាប់ធ្វើអាជីវកម្មខាងកសិកម្ម និងកសិកម្ម-ឧស្សាហកម្ម ពោលគឺ ដាំដំណាំស្បៀងឬឧស្សាហកម្ម ការចិញ្ចឹមសត្វ វារីវប្បកម្ម ការកសាងរោងចក្រនិងកន្លែងផ្សេងៗសម្រាប់ធ្វើការកែច្នៃវត្ថុធាតុដើមកសិកម្មក្នុងស្រុក ឬការគួបផ្សំគ្នាខ្លះឬទាំងអស់នូវសកម្មភាពទាំងនេះ។

គំនិតផ្តួចផ្តើមទាំងឡាយនៅខាងលើ មានគោលដៅចម្បងធ្វើការអភិវឌ្ឍសកម្មភាពប្រពលវប្បកម្ម ខាងកសិកម្ម និងកសិឧស្សាហកម្ម ដើម្បីបង្កើតការងារ និងធ្វើពិពិធកម្មឱកាសរកចិញ្ចឹមជីវិតនៅតំបន់ជនបទ និងបង្កើនចំណូលរដ្ឋ (១-១០ដុល្លារ/ហិកតា/ឆ្នាំ ផ្អែកលើដីចំនួនបួនប្រភេទ)។

---

[៤] គួរកត់សំគាល់ថា កម្រងទិន្នន័យ CDC ពុំមានកំណត់ត្រាលើ ELCs ជាច្រើនដែលមានចុះក្នុងវេបសាយ MAFF ទេ។

[៥] www.elc.maff.gov.kh/laws/subdecree.html.

តារាង ៨ បង្ហាញថាវិនិយោគឯកជនក្នុងស្រុក និងបរទេស លើ ELCs ពីពាក់កណ្ដាលទសវត្សរ៍ ១៩៩០ ដល់ដើមទសវត្សរ៍ ២០០០ ពុំមានច្រើនដូចពី ដើមទសវត្សរ៍ ២០០០ ដល់សព្វថ្ងៃទេ។ សន្តិភាព និងស្ថិរភាពនៅកម្ពុជា ព្រមទាំងបរិយាកាសវិនិយោគកាន់តែប្រសើរនិងកំណើនតម្រូវការសាកលនូវដំណាំឧស្សាហកម្មដូចជា កៅស៊ូ និងដំឡូងឈើ អាចជាកត្តាជំរុញវាឡើង។

គួរកត់សំគាល់ថា សម្បទានអនុម័តពីឆ្នាំ១៩៩៥ ដល់ ២០០៣ មានច្រើនខ្លាំងណាស់ ក្នុងនេះ មានអនុម័ត ២០.០០០ហិកតា នៅឆ្នាំ១៩៩៩ ៣១៥.០២៨ហិកតា នៅឆ្នាំ២០០០ និង ១០០.៨៥២ហិកតា នៅឆ្នាំ២០០៣។ ការអនុញ្ញាតនូវ គំរូវិនិយោគខ្នាតធំបែបនេះមុនការអនុម័តច្បាប់ភូមិបាលឆ្នាំ២០០១ និងអនុស្ដីពីសម្បទានដីសេដ្ឋកិច្ចឆ្នាំ២០០៥ មានន័យថា សម្បទានទាំងនោះ បានអនុវត្តឡើងដោយគ្មានច្បាប់ និងយន្តការគ្រប់គ្រងត្រឹមត្រូវទេ នាំឲ្យធនធាន និងអ្នកពាក់ព័ន្ធនៅតាមមូលដ្ឋានត្រូវជួបហានិភ័យ។

តារាង ៨៖ ELCs បានអនុម័ត និងបានលុបចេញ ឆ្នាំ១៩៩៥-២០០៩

| ឆ្នាំ | គម្រោងបានអនុញ្ញាត និងកំពុងដំណើរការ | | | | គម្រោងបានអនុញ្ញាត ប៉ុន្តែក្រោយមកលុបវិញ | | | |
|---|---|---|---|---|---|---|---|---|
| | ទំហំ (ហ.ត) | ទំហំអប្បបរមា (ហ.ត) | ទំហំអតិបរមា (ហ.ត) | ចំនួនគម្រោង | ទំហំ (ហ.ត) | ទំហំអប្បបរមា (ហ.ត) | ទំហំអតិបរមា (ហ.ត) | ចំនួនគម្រោង |
| 1995 | 11000 | - | - | 1 | - | - | - | - |
| 1996 | 2400 | - | - | 1 | - | - | - | - |
| 1998 | 60200 | - | - | 1 | 51500 | 23,000 | 28500 | 2 |
| 1999 | 33400 | 3000 | 20000 | 4 | 4100 | - | - | 1 |
| 2000 | 341898 | 1070 | 315028 | 5 | 11200 | 3200 | 8000 | 2 |
| 2001 | 128275 | 5000 | 100852 | 4 | - | - | - | - |
| 2004 | 6100 | 1200 | 4900 | 2 | - | - | - | - |
| 2005 | 67043 | 3000 | 10000 | 8 | 10000 | - | - | 1 |
| 2006 | 168256 | 4400 | 10000 | 20 | 40393 | 7172 | 9214 | 5 |
| 2007 | 29001 | 6436 | 8100 | 4 | 8692 | - | - | 1 |
| 2008 | 40936 | 6523 | 7200 | 6 | - | - | - | - |
| 2009 | 136130 | 807 | 9820 | 21 | - | - | - | - |
| សរុប | 1024639 | 807 | 315028 | 77 | 125885 | 3200 | 28500 | 12 |
| គម្រោងគ្មានរាយការណ៍ពីកាលបរិច្ឆេទ និងទំហំដី | | | | 9 | | | | |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យក្នុង MAFF website, www.elc.maff.gov.kh/profiles.html ( retrieved Oct. 2010 )

ត្រឹមចុងឆ្នាំ២០០៩ MAFF បានផ្ដល់ការយល់ព្រមលើ ៨៦គម្រោង ELC ( មិនបូក ១២ គម្រោងដែលលុបចេញវិញទេ ) ក្នុងនេះ ៩គម្រោង គ្មានចុះក្នុងវេបសាយ MAFF ទេ ( ចំពោះព័ត៌មានលំអិតលើ ELCs ទាំងអស់ សូមមើល តារាង ១ ក្នុងឧបសម្ព័ន្ធ ១។ មាត្រា៥៩ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ចែងថា ផ្ទៃដីគម្រោងសម្បទានមិនត្រូវធំជាង ១០.០០០ហិកតាទេ។ ជាដំណោះស្រាយ MAFF បានចរចាជាមួយក្រុមហ៊ុននានាដែលមានផ្ទៃដីធំជាង ១០០.០០០ហិកតា និងបានយឺតយ៉ាវក្នុងការអនុវត្តផែនការធ្វើអាជីវកម្មរបស់ខ្លួន។ សរុបមក មានការលុបចេញវិញ ១២គម្រោង ក្នុងនេះ ២គម្រោងមានផ្ទៃដីធំជាង ១០.០០០ហិកតា។ ដោយឡែក គម្រោងយក្សទាំងបីដែលបានលើកពីខាងដើម នៅតែកំពុងដំណើការ។

ចំណុចសំខាន់បំផុតមួយគឺ ដើម្បីទទួលបានដីឯកជនរបស់រដ្ឋកាន់តែធំ ក្រុមហ៊ុនខ្លះបានប្រើឈ្មោះពីរខុសគ្នា ដើម្បីស្នើសុំ ELCs ។ ឧទាហរណ៍ ក្រុមហ៊ុន Koh Kong Plantation Limited និង Koh Kong Sugar Company Limited នៅខេត្តកោះកុង ទទួលបានផ្ទៃដី ៩.៤០០ហិកតា និង ៩.៧០០ហិកតា រៀងគ្នា ដែលបង្កើតបានជាទំហំដីសរុបជិតដល់ ២០.០០០ហិកតា។

ត្រឹមចុងឆ្នាំ២០០៩ បណ្តាគម្រោង ELCs ដែលបានរាយការណ៍ មានផ្ទៃដីសរុប ១.០២៤.៦៣៩ហិកតា ។ Ngo និង Chan (2010: 6) បានបញ្ជាក់ថា មានគម្រោង ELCs ប្រហែល ៥០០.០០០ហិកតា ដែលទទួលបានការយល់ព្រម និងស្ថិតក្រោមការគ្រប់គ្រងពីក្រសួងបរិស្ថាន (MoE) ពុំឃើញមានចុះក្នុងទិន្នន័យ MAFF ទេ។ តាមនេះទំហំគម្រោង ElCs សរុប ត្រូវឡើងដល់ប្រហែល ១,៥លានហិកតា គឺជិតស្មើនឹងផ្ទៃដីដាំស្រូវសរុប ២,៧លានហិកតា នៅឆ្នាំ២០០៩ (MAFF 2010: 16)។

តារាង ៩៖ របាយ ELCs បែងចែកតាមសញ្ជាតិ ឆ្នាំ១៩៩៥-២០០៩

| ប្រភេទ | ទំហំ (ហ.ត) | % សរុប | ទំហំមធ្យម (ហ.ត) | ទំហំអប្បបរមា (ហ.ត) | ទំហំអតិបរមា (ហ.ត) | ចំនួនគម្រោង | ចំនួនគម្រោង >១០,០០០ (ហ.ត) |
|---|---|---|---|---|---|---|---|
| គម្រោងមានសកម្មភាព | | | | | | | |
| គ្មានរាយការណ៍ | - | - | - | - | - | 9 | - |
| កម្ពុជា | 668725 | 65 | 18576 | 807 | 315028 | 36 | 6 |
| ចិន | 186935 | 18 | 10996 | 5000 | 60200 | 17 | 1 |
| ឥណ្ឌា | 7635 | 1 | 7635 | 7635 | 7635 | 1 | 0 |
| កូរ៉េ | 27622 | 3 | 5524 | 3000 | 7500 | 5 | 0 |
| ម៉ាឡេស៊ី | 7955 | 1 | 7955 | 7955 | 7955 | 1 | 0 |
| តៃវ៉ាន់ | 4900 | 0 | 4900 | 4900 | 4900 | 1 | 0 |
| ថៃ | 37436 | 4 | 7487 | 6523 | 9700 | 5 | 0 |
| សហរដ្ឋអាមេរិក | 36203 | 4 | 9051 | 7000 | 9820 | 4 | 0 |
| វៀតណាម | 47228 | 5 | 6747 | 2361 | 9380 | 7 | 0 |
| សរុប | 1024639 | 100 | 13307 | 807 | 315028 | 86 | 7 |
| FDI | 355914 | 35 | | | | 41* | 1 |
| គម្រោងលុបចេញ | | | | | | | |
| កម្ពុជា | 34711 | 28 | 8678 | 7172 | 10000 | 4 | 0 |
| ចិន | 66800 | 53 | 13360 | 3200 | 28500 | 5 | 2 |
| សហរដ្ឋអាមេរិក | 9214 | 7 | 9214 | 9214 | 9214 | 1 | 0 |
| វៀតណាម | 15160 | 12 | 7580 | 7560 | 7600 | 2 | 0 |
| សរុប | 125885 | 100 | 10490 | 3200 | 28500 | 12 | 2 |
| FDI | 91174 | 72 | - | - | - | 8 | 2 |

កំណត់សំគាល់៖ * គ្មានបូកចំនួនគម្រោងមិនរាយការណ៍។

ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យក្នុង MAFF website, www.elc.maff.gov.kh/profiles.html (retrieved Oct. 2010)

ដូចមានចុះក្នុងតារាង ៩ គម្រោង ELCs ភាគច្រើនស្ថិតក្រោមកម្មសិទ្ធិឯកជនក្នុងស្រុក យោងតាមទិន្នន័យក្នុងវេបសាយ MAFF ។ មកដល់ឆ្នាំ២០០៩ វិនិយោគិនបរទេសទទួលបាន ELCs ទំហំ ៣៥៥.៩១៤ហិកតា គឺប្រហែល ៣៥% នៃទំហំដីសម្បទានសរុប ឬ ១៣% នៃផ្ទៃដីដាំស្រូវសរុបនៅកម្ពុជា។ ចិនជាតួអង្គចម្បងគេក្នុងចំណោមវិនិយោគិនបរទេសដោយមាន ១៧គម្រោង មានផ្ទៃដីសរុប ១៨៦.៩៣៥ហិកតា (១៨%) ក្នុងនេះមានគម្រោងយក្សមួយទំហំ ៦០.២០០ហិកតាក្នុងខេត្តកោះកុង ដែលទទួលបានការយល់ព្រមក្នុងឆ្នាំ១៩៩៨ ។ ចិនយកចិត្តទុកដាក់ខ្លាំងលើចំការកៅស៊ូ អាកាស្យា ចំការគ្រាប់ឈើ (pistachio)។

វៀតណាមមានគម្រោងចំនួនប្រាំពីរ និងផ្តោតលើចំការកៅស៊ូនៅខេត្តក្រចេះ រតនគិរី មណ្ឌលគិរី កំពង់ធំ និង ព្រះវិហារ ហើយ ថៃមានគម្រោងចំនួនប្រាំ និងផ្តោតលើដំណាំអំពៅនៅខេត្តឧត្តរមានជ័យ និង កោះកុង។ សហរដ្ឋអាមេរិក មានគម្រោងចំនួនបួន ដាំដើមម៉ៃសាក់នៅខេត្តក្រចេះ និង កំពង់ស្ពឺ។ ហើយ កូរ៉េមានគម្រោងចំនួនប្រាំ ធ្វើវិនិយោគ ជាសំខាន់លើចំការកៅស៊ូ និងដំឡូងឈើ នៅខេត្តកំពង់ធំ រតនគិរី ក្រចេះ និង កំពង់ស្ពឺ។ ឥណ្ឌាមានវិនិយោគលើអំពៅ ហើយ ម៉ាឡេស៊ីមានវិនិយោគលើចំការដូងប្រេង។

ដូចបានបង្ហាញរួចហើយ វិនិយោគិនបរទេសតែងយកចិត្តទុកដាក់ខ្លាំងលើដំណាំដូចជា កៅស៊ូ ដំឡូងឈើ អំពៅ ម៉ៃសាក់ អាកាស្យា និងគ្រាប់ឈើដែលកម្ពុជាមានជំនាញឯកទេស និងមានដីសមស្របល្អ។ ពិនិត្យតាមចំនួនគម្រោង ពួកគេចូល រួមជាសំខាន់ក្នុងខេត្តយុទ្ធសាស្ត្រសម្រាប់ដំណាំដូចជា ក្រចេះ(១៣គម្រោង) មណ្ឌលគិរី(៥គម្រោង) កំពង់ស្ពឺ(៥) រតនគិរី(៤) ស្ទឹងត្រែង(៤) ឧត្តរមានជ័យ(៤) និង កំពង់ធំ(៣) (ចំពោះរបាយទំហំដី និងគម្រោង ELCs បែងចែកតាម ខេត្ត និងសញ្ជាតិ ពីឆ្នាំ១៩៩៥-២០០៩ សូមមើល តារាង A2 ក្នុង ឧបសម្ព័ន្ធ ១)។

ដោយគ្មានទិន្នន័យស្តីពីការអនុវត្តគម្រោងវិនិយោគបរទេសជាក់ស្តែង គេពិបាកសន្និដ្ឋានបានពី អត្ថប្រយោជន៍ នៃការបង្កើតការងារ និងប្រាក់ចំណូលនៅកម្ពុជា។ បើសិនគម្រោងទាំងអស់អនុវត្តបានពេញលេញ គឺអាចបង្កើតប្រាក់ ចំណូល និងការងារ បានយ៉ាងច្រើន។ ប៉ុន្តែវិនិយោគខ្នាតធំក្នុងកសិកម្ម តាមរយៈ ELCs យ៉ាងហោចណាស់ក៏មានការ កាប់រានខ្លះដែរនូវ ព្រៃឈើដែលជាប្រភពប្រាក់ចំណូលយ៉ាងធំមួយរបស់គ្រួសារជាច្រើននៅជនបទ។ ការប្រមូលផ្តុំ គម្រោងនៅតាមខេត្ត ដូចជា មណ្ឌលគិរី និង រតនគិរី ដែលមានប្រជាជនភាគច្រើនជាជនជាតិភាគតិច និងត្រូវពឹងផ្អែកលើ អនុផលព្រៃឈើជាប្រភពចំណូលចម្បងរបស់ខ្លួន វាអាចញាំងឲ្យជីវភាពពួកគេជួបគ្រោះថ្នាក់។ ឥទ្ធិពលអវិជ្ជមានលើ ជីវភាពរស់នៅក្នុងសហគមន៍ អាចពិនិត្យឃើញជាពិសេសក្នុងខេត្ត ដូចជា ក្រចេះ និង ស្ទឹងត្រែង ដែលប្រជាជនទូទៅ ពឹងផ្អែកលើអនុផលព្រៃឈើ គួបផ្សំនឹងការនេសាទ។

កម្ពុជាសព្វថ្ងៃផលិតស្រូវបានលើសតម្រូវការក៏ពិតមែន ប៉ុន្តែការប្រជែងប្រើប្រាស់ដីក្នុងរយៈពេលវែង រវាង ការដាំស្រូវ នឹង ដំណាំផ្សេងទៀតដាំដុះដោយវិនិយោគិនឯកជនក្នុងស្រុក និងបរទេស អាចបង្កក្តីបារម្ភពីសន្តិសុខស្បៀង ក្នុងប្រទេស។

ឥទ្ធិពលនៃវិនិយោគ ជាពិសេស ELCs ត្រូវបូកសរុបដោយប្រើសូចនាករដូចលើកបង្ហាញខាងលើ ពោលគឺ ប្រាក់ចំណូលនិងការងារបង្កើតបាន ការបាត់បង់ប្រភពចំណូលចម្បងៗរបស់សហគមន៍ពីផលិតផលព្រៃឈើ ការប្រជែង ប្រើប្រាស់ទឹកនិងដី រវាងស្រូវ និងដំណាំផ្សេងទៀតក្នុងគម្រោងវិនិយោគបរទេស និងការរួមចំណែករបស់ក្រុមហ៊ុនក្នុង ការអភិវឌ្ឍផ្លូវថ្នល់ និងប្រព័ន្ធស្រោចស្រពផ្សេងៗ។ ផ្នែកទី៥ ផ្តល់ការវាយតម្លៃជាដំបូងៗពីផលប៉ះពាល់នៃ FDI ទៅលើ កសិកម្មនៅកម្ពុជា។

## ៣.៦. របាំងរារាំង FDI នៅកម្ពុជា

អង្កេតលើសហគ្រាសដើម្បីពិនិត្យពីការលើកទឹកចិត្ត និងរបាំងរារាំងដល់វិនិយោគក្នុងកសិកម្មនៅកម្ពុជា បានធ្វើ ឡើងនៅខែវិច្ឆិកា ២០១០ ដោយបានប្រើ បញ្ជីសំណួរពាក់កណ្តាលរៀបរយមួយ (ឧបសម្ព័ន្ធ ២) ដើម្បីប្រមូលព័ត៌មាន ពីការចូលរួមចំណែករបស់សហគ្រាសក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងពីការយល់ឃើញចំពោះយន្តការសម្រាប់បន្ធូរ បន្ថយរបាំងចំពោះវិនិយោគ។ ទិន្នន័យ CDC សម្រាប់រយៈពេលពីឆ្នាំ២០០០ ដល់ មិថុនា ២០១០ បង្ហាញថា មានសរុប ៥៩សហគ្រាស បានចូលរួមក្នុងកសិកម្ម និងការកែច្នៃស្បៀងអាហារ (ចំពោះព័ត៌មានលំអិត សូមមើល តារាង A3 ក្នុង ឧបសម្ព័ន្ធ ១)។ CDC គ្មានផ្តល់ព័ត៌មានសម្រាប់ធ្វើការទាក់ទងទៅសហគ្រាសទាំងនេះទេ ហើយក្នុងនេះភាគច្រើនក៏គ្មាន ចុះក្នុងសៀវភៅទូរស័ព្ទ (Yellow Pages) ដែរ ដូច្នេះគឺពិបាករកជួបខ្លាំងណាស់។

សហគ្រាសខ្លះនៅក្នុងបញ្ជីរបស់ CDC ក៏ឃើញមានចុះក្នុងវេបសាយ MAFF ដែរ ព្រមទាំងព័ត៌មានសម្រាប់ទាក់ទងផង។ ដោយប្រើសៀវភៅទូរស័ព្ទ និងព័ត៌មានបានពី MAFF ក្រុមស្រាវជ្រាវចងក្រងបានបញ្ជីមួយមាន ៣១សហគ្រាសដែលមានព័ត៌មានសម្រាប់ទាក់ទង (សូមមើល តារាង A4 ក្នុង ឧបសម្ព័ន្ធ ១)។ ដោយសារអាសយដ្ឋានភាគច្រើនដែលបានពីវេបសាយរបស់ MAFF ចាស់ហួសពេក ហើយសហគ្រាសខ្លះមិនព្រមសហការផង ក្រុមស្រាវជ្រាវអាចទាក់ទងបានតែសហគ្រាសពីរប៉ុណ្ណោះ គឺ HLH Agriculture (ដាំ និងសម្ងួតពោត) និង Kogid (សម្ងួតពោត និងកិនស្រូវ)។ ដូច្នេះការស្វែងរកចម្លើយលើសំណួរអំពីរបាំងចំពោះវិនិយោគ ជាការងារមួយពិបាកខ្លាំងណាស់។

ផ្អែកលើចម្លើយបានពីក្រុមហ៊ុនទាំងពីរ[៦] គឺមានកត្តាប្រាំ ដែលបង្កឧបសគ្គចម្បងដល់ការស្នើសុំធ្វើវិនិយោគ និងដំណើរការវិនិយោគក្នុងកសិកម្មនៅកម្ពុជា។ ទី១ ការកាន់កាប់ដី និងការទទួលបានការព្រមព្រៀងឲ្យជួលដី នៅតែជាបញ្ហាប្រឈម។ ក្រុមហ៊ុនមួយបានអះអាងថា ត្រូវធ្វើប្រតិបត្តិការយ៉ាងច្រើនដើម្បីបំពេញបែបបទជួល។ នៅពេលខ្លះទៀត ពួកឈ្មួញជេដីជាមូលហេតុនៃវិវាទដីធ្លី រវាងសហគមន៍មូលដ្ឋាន និងក្រុមហ៊ុន។ ទី២ គឺ បញ្ហាសេចក្ដីណែនាំមិនច្បាស់ថា ក្រុមហ៊ុនត្រូវទៅទាក់ទងស្ថាប័នណាដើម្បីទទួលបានអាជ្ញាប័ណ្ណធ្វើអាជីវកម្ម។ សហគ្រាសមួយត្រូវចំណាយពេលអស់ពីរខែ ដើម្បីបានការយល់ព្រមពី MAFF លើ ELC របស់ខ្លួន ដោយប្រើឈ្មួញជេត្រូវល្អផង បើសិនគ្មានគាត់ទេ ប្រហែលត្រូវយូរដល់ជាងពីរឆ្នាំ។ ទី៣ ការពង្រឹងអនុវត្តច្បាប់នៅតែទន់ខ្សោយ។ ទី៤ នីតិវិធីរដ្ឋបាលនៅតែវែងអន្លាយ ប៉ុន្តែអាចទទួលយកបាន។ ទី៥ ការដោះស្រាយវិវាទ និងយន្តការដោះស្រាយបញ្ហា មានតិចតួចពេក។ ឧទាហរណ៍ ពុំមាននាយកដ្ឋានក្នុងក្រសួងជាក់លាក់ណាមួយ សម្រាប់ជួយវិនិយោគិនដោះស្រាយបញ្ហា ដែលផុសឡើងក្នុងពេលដាក់ពាក្យសុំធ្វើអាជីវកម្មនោះទេ។ គួរកត់សំគាល់ថា សហគ្រាសមិនយល់ថា ការបង់ប្រាក់សាគុណទៅឲ្យមន្ត្រីរាជការ ជារឿងអាក្រក់ ឬជាបញ្ហាធំនោះទេ ពីព្រោះវាជួយពន្លឿនដំណើរការដាក់ពាក្យសុំ ហើយសហគ្រាសក៏ទទួលស្គាល់ថា មន្ត្រីរាជការមានបៀវត្សរ៍ទាបដែរ។

ដើម្បីដោះស្រាយឧបសគ្គខាងលើ ខាងសហគ្រាសបានស្នើឡើងថា រដ្ឋាភិបាលគួរពិចារណាប្រើបែបបទដាក់ពាក្យសុំធ្វើវិនិយោគ សុំអាជ្ញាប័ណ្ណធ្វើអាជីវកម្ម និងបំពេញបែបបទរដ្ឋបាលផ្សេងទៀត តាមប្រព័ន្ធកុំព្យូទ័រ ដើម្បីកាត់បន្ថយចំនួនក្រដាសស្នាម ពេលវេលា ការចំណាយ ជួយឲ្យសហគ្រាសងាយស្រួលដោះស្រាយបញ្ហាក្នុងពេលកំពុងដាក់ពាក្យសុំ។ ខាងសហគ្រាសក៏ស្នើឲ្យបង្កើតនាយកដ្ឋានសម្រាប់ផ្ដល់ព័ត៌មានត្រឡប់ក្នុងក្រសួងពាក់ព័ន្ធនីមួយៗ ដើម្បីជួយវិនិយោគិនដោះស្រាយបញ្ហាផុសឡើងក្នុងពេលដាក់ពាក្យសុំ ឬកំពុងដំណើរការ។

កន្លងមកពុំទាន់មានបង្កើតគំរូជំនួញ ឬរបៀបរបបកិច្ចសន្យា រវាងសហគ្រាស និងកសិករទេ។ ក្នុងការអនុវត្តជាក់ស្ដែង សហគ្រាសប្រមូលទិញពោតពីកសិករតាមថ្លៃទីផ្សារ ដោយគ្មានចុះកិច្ចសន្យានៃការទិញដូរក្នុងពេលអនាគតទេ។ ពួកកសិករ ឬមួយយកផលិតផលទៅលក់ដល់រោងចក្រ ឬមួយលក់ឲ្យពួកឈ្មួញជេដែលបន្ទាប់មកលក់បន្តទៅឲ្យរោងចក្រ ឬសហគ្រាស។ ការលក់ឲ្យពួកឈ្មួញជេឃើញមានជាទូទៅ ជាពិសេសនៅពេលកសិករជាកូនបំណុលរបស់ឈ្មួញជេ។

សរុបមក ទោះបីមានឧបសគ្គរាំងខ្ទះក្តី ក៏វិនិយោគិនទាំងពីរនាក់ដែលឆ្លើយសម្ភាសន៍ ហាក់ដូចគាំទ្រចំពោះបរិយាកាសវិនិយោគនៅកម្ពុជា។ ពួកគេនិយាយថា កម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍមួយ ត្រូវមានអនុវត្តវិធានការជាច្រើនទៀតដើម្បីកែលំអបរិយាកាសវិនិយោគ ក្នុងនេះមានខ្លះបានគូសបញ្ជាក់នៅខាងលើ។

[៦] គួរចៀសវាងធ្វើការសន្និដ្ឋានជាទូទៅដោយប្រើលទ្ធផលនៃការពិភាក្សាទាំងនេះ ពីព្រោះគំរូតាងតែពីរ ក្នុងចំណោម ៥៩ក្រុមហ៊ុន មិនអាចផ្ដល់រូបភាពពិតក្នុងអនុវិស័យទាំងមូលទេ។ ដូច្នេះរឿងនេះគួរចាត់ទុកជាដំណឹងមួយប៉ុណ្ណោះ។

# ៤

# គោលនយោបាយវិនិយោគ និងបទបញ្ញាច្បាប់ តាមអនុវិស័យនៅកម្ពុជា

រដ្ឋាភិបាលកម្ពុជា បានបង្កើតយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយមួយចំនួន ដើម្បីជំរុញវិនិយោគក្នុងវិស័យកសិកម្ម។ កម្ពុជាមានសក្តានុពលខ្លាំងខាងកសិកម្ម ព្រោះសម្បូរដីផ្លីអាចដាំដុះបាន ប៉ុន្តែវិស័យនេះមិនទាន់បានអភិវឌ្ឍគ្រប់គ្រាន់ទេ ដោយសារមួយផ្នែកមកពី មានវិនិយោគមូលធនតិចនៅក្នុងបណ្តាញធារាសាស្ត្រ បច្ចេកវិទ្យា ជី និង ថាមពល។

វិបត្តិសេដ្ឋកិច្ចពិភពលោកនៅចុងឆ្នាំ២០០៨ បានជះឥទ្ធិពលលើវិស័យសំខាន់ៗនៅកម្ពុជា ពោលគឺ វិស័យកាត់ដេរ ទេសចរណ៍ និង សំណង់។ ទោះបីជា តួលេខរបស់ MAFF បង្ហាញនូវនិន្នាការថេរក្នុងផលិតកម្មកសិកម្មក្តី ក៏វិនិយោគក្នុងវិស័យនេះបានធ្លាក់ចុះ ដោយសារ វិនិយោគមូលធនទាប និងលទ្ធភាពទទួលបានចំណូលទាបពីគម្រោងវិនិយោគខាងកសិកម្ម។

ការជំរុញវិស័យកសិកម្មមានតួនាទីសំខាន់ណាស់ ក្នុងការពង្រឹងសេដ្ឋកិច្ចកម្ពុជាដែលមានមូលដ្ឋានកំណើនតូចចង្អៀត ហើយយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល ក៏បានផ្តល់អាទិភាពខ្ពស់ និងកំណត់វាថាជាសសរទ្រូងមួយជួយទ្រទ្រង់ឲ្យប្រទេសកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ច ការងារ សមធម៌ និង ប្រសិទ្ធភាព ដោយក្នុងនេះ គោលនយោបាយកសិកម្មត្រូវដើរតួនាទីកាន់តែសំខាន់ឡើង។

យុទ្ធសាស្ត្រចតុកោណបានសង្កត់ធ្ងន់ថា ដើម្បីលើកកម្ពស់ផលិតភាព ពិពិធកម្ម និងប្រពលវប្បកម្មក្នុងវិស័យកសិកម្ម ត្រូវធ្វើសុខដុមនីយកម្មកំណែទម្រង់ការគ្រប់គ្រងដីធ្លី ជលផល និងព្រៃឈើ និងត្រូវធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ ថាមពល ឥណទាន ទីផ្សារ និង បច្ចេកវិទ្យា។ កំណែទម្រង់ដីធ្លី សំខាន់បំផុតក្នុងការជំរុញវិនិយោគផ្នែកកសិកម្ម និងលើកកម្ពស់ផលិតភាព។ រដ្ឋាភិបាលបានប្តេជ្ញាចិត្តដាក់អនុវត្ត ច្បាប់ភូមិបាល ច្បាប់ស្តីពីការរឹបអូសទ្រព្យសម្បត្តិ ច្បាប់ស្តីពីសិទ្ធិទិញមុន និងការអភិវឌ្ឍដីធ្លី ច្បាប់ស្តីពីការៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ និង ស្តង់ដារជាតិសម្រាប់សំណង់។ ដោយឡែក ការអនុវត្តច្បាប់ភូមិបាល និង ច្បាប់ស្តីពីការរឹបអូសទ្រព្យសម្បត្តិ បានបង្កជាការជជែកត៉វ៉ា ដោយសារម្ចាស់ដី ឬកសិដ្ឋានខ្លះ មិនមានសិទ្ធិទទួលបានសំណងប៉ះប៉ូវទេ ពីព្រោះយោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ ផ្លូវថ្នល់ និងសិទ្ធិឆ្លងកាត់ខ្លះត្រូវបានចាត់ទុកជាទ្រព្យសាធារណៈរបស់រដ្ឋ។ ម្ចាស់ដីថែមទាំងមិនមានសិទ្ធិកែប្រែទ្រព្យប្រភេទនោះផង ក្នុងពេលដែលខ្លួនកំពុងកាន់កាប់។ ការកសាងផ្លូវជាតិលេខ១ ឡើងវិញ គឺជាឧទាហរណ៍ដ៏ល្អមួយ (ADB 2007)។

ដើម្បីគាំទ្រដល់កសិកម្ម រដ្ឋាភិបាលក៏បានលើកលែងពន្ធលើការនាំចូលសម្ភារៈទាក់ទងនឹងវិស័យនេះ និងបានពន្យាពេលការយកពន្ធដីកសិកម្ម។ ទោះបីមានការគាំទ្របែបនេះក្តី ក៏កសិករកម្ពុជា នៅតែជួបការលំបាកក្នុងការធ្វើផលិតកម្ម ពីព្រោះដំណាំរបស់គាត់ ត្រូវពឹងផ្អែកលើទឹកភ្លៀង និងងាយរងគ្រោះដោយគ្រោះធម្មជាតិ។

ជាទូទៅ តាមច្បាប់ស្តីពីវិនិយោគរបស់កម្ពុជា ដែលបានប្រកាសឲ្យប្រើជាផ្លូវការនៅឆ្នាំ១៩៩៤ និងធ្វើវិសោធនកម្មនៅឆ្នាំ២០០៤ ព្រមទាំងអនុក្រឹត្យលេខ ១១១ ស្តីពី ការអនុវត្តច្បាប់វិនិយោគក្រោយវិសោធនកម្ម ចុះថ្ងៃទី ២៧ កញ្ញា ២០០៥ នោះ CIB នៃ CDC ត្រូវទទួលខុសត្រូវត្រួតពិនិត្យការលូតលាស់នៃសកម្មភាពវិនិយោគ (ក្នុងស្រុក និង បរទេស)។ យន្តការចុះបញ្ជីនៅឯ CIB ត្រូវអនុវត្តសម្រាប់គម្រោងវិនិយោគលើសពី ២លានដុល្លារ ដែលមានទីតាំងក្នុង ២ ខេត្ត/ក្រុង និង តំបន់សេដ្ឋកិច្ចពិសេស ហើយ អនុគណៈកម្មាធិការ ស្តីពីការវិនិយោគ ទទួលខុសត្រូវលើការផ្តល់លិខិតអនុញ្ញាតដល់ គម្រោងមានទឹកប្រាក់តិចជា ២លានដុល្លារ។ ផ្អែកលើ អនុក្រឹត្យលេខ ១៧ ចុះថ្ងៃទី ៩ កុម្ភៈ ២០០៥ សមាសភាពអនុគណៈកម្មាធិការនេះ មាន៖

- អភិបាលខេត្តជាប្រធាន
- តំណាងមកពី CDC/CIB ជាអនុប្រធានអចិន្ត្រៃយ៍
- អភិបាលខេត្តរងទី១ និង ទី២ ជាអនុប្រធាន
- ប្រធាននាយកដ្ឋាននៃក្រសួងពាក់ព័ន្ធ ដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងផែនការ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងទេសចរណ៍ ក្រសួងប្រៃសនីយ៍ និង ទូរគមនាគមន៍ និង សភាពាណិជ្ជកម្ម។

## ៤.១. ជលផល

នៅកម្ពុជា ត្រីជាអាហារមូលដ្ឋានទី២ បន្ទាប់ពីបាយ។ ត្រីដើរតួនាទីសំខាន់បំផុតក្នុងជីវភាពរស់នៅរបស់ប្រជាជន និងជាប្រភពចម្បងនៃប្រាក់ចំណូល និងសន្តិសុខស្បៀង។ ការគ្រប់គ្រងជលផលនៅកម្ពុជា ចែកជាពីរកម្រិត គឺ អាជ្ញាធរមូលដ្ឋាន និង រដ្ឋាភិបាលមជ្ឈឹម។ នៅកម្រិតមជ្ឈឹម នាយកដ្ឋានកិច្ចការជលផលនៃ MAFF ទទួលខុសត្រូវលើការបង្កើតគោលនយោបាយ ការស្រាវជ្រាវ និងអធិការកិច្ច រីឯនៅកម្រិតមូលដ្ឋាន ផ្នែកនេះ ស្ថិតនៅក្រោមការត្រួតត្រារបស់អាជ្ញាធរជលផលខេត្ត-ក្រុង ដែលមានសិទ្ធិអំណាចក្នុងការពង្រឹងអនុវត្តច្បាប់នៅតាមតំបន់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

វិស័យជលផលត្រូវបានគ្រប់គ្រងដោយច្បាប់ជាច្រើន ដូចជា ច្បាប់រដ្ឋបាល និងការគ្រប់គ្រងជលផល (១៩៨៧) សេចក្តីប្រកាសស្តីពីអាជ្ញាធរមានសមត្ថកិច្ចចេញលិខិតអនុញ្ញាតឲ្យធ្វើនេសាទ វារីវប្បកម្ម កែច្នៃត្រី និង លិខិតអនុញ្ញាតពិសេស (១៩៨៩) និង ច្បាប់ស្តីពីការដឹកជញ្ជូនផលិតផលជលផល (១៩៨៨)។ គួរកត់សម្គាល់ថា ផែនការមេរបស់កម្ពុជាសម្រាប់វិស័យជលផលឆ្នាំ២០០១-២០១១ ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០១ រីឯច្បាប់ស្តីពីជលផលដែលបានប្រកាសឲ្យប្រើជាសាធារណៈនៅឆ្នាំ២០០៦ គឺ ដើម្បីលើកកម្ពស់ការគ្រប់គ្រងលើវិស័យនេះ។ ទោះបីមានការបង្កើតនូវបទបញ្ញត្តិច្បាប់ដ៏ចាំបាច់ជាច្រើនក្តី ក៏ការនេសាទខុសច្បាប់ និងការបំផ្លាញជម្រកត្រីតាមដងទន្លេមេគង្គ និងក្នុងបឹងទន្លេសាប នៅតែបន្តកើតមានឥតស្រាកស្រាន្ត ហើយជម្លោះលើសិទ្ធិនេសាទរវាងសហគមន៍ និងម្ចាស់ឡូត៍នេសាទពាណិជ្ជកម្មដែលមានអំណាចខ្លាំងជាង ខាងនយោបាយ និងធនធាន ឃើញកើតមានជាទូទៅ (FAO 2011: 6, 10)។ ការពង្រឹងអនុវត្តច្បាប់ ហាក់មានលក្ខណៈចំពោះកិច្ច។ តួយ៉ាង ចំណាត់ការតឹងរឹងនាពេលថ្មីៗរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃទី ១ កក្កដា ២០១១ ដាក់បញ្ជាឲ្យរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដកហូតតំណែងប្រធានមន្ទីរជលផលក្នុងប្រាំខេត្តជុំវិញបឹងទន្លេសាប ដែលជាប់សង្ស័យបានល្មើសច្បាប់ជលផល ដោយបានលក់ឡូត៍នេសាទក្នុងលក្ខណៈមិនប្រក្រតីនោះ គឺជាកិច្ចប្រឹងប្រែងមួយរបស់រដ្ឋាភិបាល ដើម្បីឈានទៅធ្វើកំណែទម្រង់ជលផល (Yang 2011)។

ទាក់ទងនឹងបទបញ្ញត្តិច្បាប់ផ្នែកវិនិយោគ មិនទាន់មានការកំណត់គោលនយោបាយជាក់លាក់ណាមួយទេ ប៉ុន្តែមានគ្រឿងលើកទឹកចិត្តវិនិយោគមួយចំនួន ដូចជា ការលើកលែងពន្ធអាករ ជាដើម នៅក្នុងច្បាប់ស្តីពីវិនិយោគរបស់កម្ពុជា។ វិនិយោគត្រូវបានលើកលែងពន្ធទាំងនោះ រួមមាន កន្លែងភ្ញាស់ត្រីមានទំហំធំជាងពីរហិកតា កសិដ្ឋានចិញ្ចឹមបង្គា និងផលិតកម្មវារីវប្បកម្មដទៃទៀតដែលមានទំហំលើសពី ១០ហិកតា។ បែបបទធ្វើវិនិយោគក្នុងវិស័យនេះ មានលក្ខណៈស្រដៀងនឹងការបង្ហាញខាងលើដែរ។

ដើម្បីអភិវឌ្ឍអនុវិស័យជលផល រដ្ឋាភិបាលបានបែងចែកឡូត៍នេសាទទឹកសាប និងទឹកប្រៃទៅឲ្យប្រជាជនសម្រាប់ទាំងការហូបចុក និងលក់ដូរ ក្នុងគោលដៅជួយសម្រួលដល់ដំណើរការនេសាទ ការរក្សាស្តុកត្រី និង អភិរក្សធនធានធម្មជាតិ។ ម្យ៉ាងទៀត ដោយតម្រូវការត្រីកាន់តែកើនឡើងដោយសារកំណើនប្រជាជន រដ្ឋាភិបាលបានជំរុញឲ្យមានការផ្លាស់ប្តូរពីការនេសាទបែបធម្មជាតិ ទៅធ្វើវារីវប្បកម្ម។

ដើម្បីកែលំអការគ្រប់គ្រងធនធានជលផល រដ្ឋាភិបាល កំពុងកសាងយន្តការកំណត់ថ្លៃដ៏មានប្រសិទ្ធភាពមួយតាមរយៈការកំណត់ព្រំដែនឡូត៍នេសាទឲ្យបានត្រឹមត្រូវ និងការធ្វើឲ្យដំណើរការដេញថ្លៃឡូត៍នេសាទកាន់តែមានតម្លាភាព។ សកម្មភាពនេះ នឹងជួយបង្កើនចំណូលពីផ្នែកជលផល។ វិធានការតឹងរឹងមួយចំនួនក៏កំពុងតែដាក់អនុវត្តដែរ ដើម្បីបំបាត់សកម្មភាពនេសាទខុសច្បាប់ និងការទន្រ្ទានយកព្រៃលិចទឹក។ សហគមន៍ និងកសិករចិញ្ចឹមត្រី ទទួលបានជំនួយផ្នែកបច្ចេកទេស ឥណទាន និង ការសម្រួលផ្នែកទីផ្សារ ដើម្បីលើកកម្ពស់សមត្ថភាព និងបង្កើនប្រាក់ចំណូលរបស់ពួកគេ។ ដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែង និងលទ្ធភាពចូលទៅកាន់ទីផ្សារ រដ្ឋាភិបាលបានជំរុញវិនិយោគផ្នែកជលផលទ្រង់ទ្រាយធំ តាមរយៈការកែលំអហេដ្ឋារចនាសម្ព័ន្ធ។

### ៤.២. ព្រៃឈើ

ជាធម្មតា រដ្ឋបាលព្រៃឈើ (នៅក្រោម MAFF) ទទួលខុសត្រូវលើអភិបាលកិច្ចទូទៅនៃព្រៃឈើ និងធនធានព្រៃឈើនៅកម្ពុជា ដោយអនុលោមតាម ច្បាប់ស្តីពីព្រៃឈើ និងគោលនយោបាយវិស័យព្រៃឈើជាតិ (២០០២)។ វិស័យនេះ ស្ថិតក្រោមការគ្រប់គ្រងពីរកម្រិត គឺរដ្ឋាភិបាលថ្នាក់មជ្ឈិម និងអាជ្ញាធរមូលដ្ឋាន[៧]។ នៅមុនឆ្នាំ២០០០ ការប្រមូលផលព្រៃឈើ កើតមានឥតឈប់ឈរ មានច្រើនពាសពេញ និងរីករាលដាលឆាប់រហ័ស។ នៅដើមទសវត្សរ៍ ២០០០ រដ្ឋាភិបាលបានលុបចេញព្រៃសម្បទាន ៤0% ដែលស្មើនឹងជិតពាក់កណ្តាលនៃផ្ទៃដីដើមដែលបានផ្តល់ជាសម្បទាន។ វិធានការនេះ គួបផ្សំនឹងសេចក្តីសម្រេចនៅឆ្នាំ២០០២ ឲ្យផ្អាកការកាប់ឈើក្នុងតំបន់ដីសម្បទាន និងការដឹកជញ្ជូនឈើហ៊ុប បានកាត់បន្ថយយ៉ាងច្រើននូវការរីករាលដាលការកាប់ឈើ (World Bank 2004a: 19, 76)។

វិធានការមួយទៀតដែលបានដាក់ចេញ ដើម្បីបង្ក្រាបការនាំចេញផលិតផលព្រៃឈើធម្មជាតិខុសច្បាប់ គឺអនុក្រឹត្យស្តីពីផល និងអនុផលព្រៃឈើអនុញ្ញាតសម្រាប់ការនាំចេញ និងនាំចូល ចុះថ្ងៃទី២០ វិច្ឆិកា ២០០៦។ អនុក្រឹត្យនេះបានអនុញ្ញាតដល់ការនាំចេញរាល់ផល និងអនុផលព្រៃឈើបានកែច្នៃឬមិនទាន់កែច្នៃ ដែលបានពីចំការដាំដើមឈើមានចីរភាព ពោលគឺ ផ្តល់ឱកាសឲ្យវិនិយោគិនចូលប្រឡូកក្នុងវិស័យនេះ តាមរយៈ ELCs ក្រោមការត្រួតពិនិត្យរបស់ MAFF (មើលការពិភាក្សាពី ELC ក្នុងផ្នែក ៤.៥)។

មួយវិញទៀត រដ្ឋាភិបាលបានផ្តោតកិច្ចប្រឹងប្រែងធ្វើកំណែទម្រង់ព្រៃឈើ តាមរយៈការបង្កើតគោលនយោបាយព្រៃឈើ (ដូចជា ច្បាប់ស្តីពីសម្បទាន និង អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច និងការគ្រប់គ្រងសម្បទានព្រៃឈើ) សហគមន៍ព្រៃឈើ និង បទបញ្ញត្តិផ្សេងៗទាក់ទងនឹងការការពារបរិស្ថាន ដូចជា ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងអនុក្រឹត្យស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន។ កិច្ចប្រឹងប្រែងទាំងនេះ មានគោលដៅធានាដល់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងជួយដល់ ប្រជាជននៅសហគមន៍ជនបទមួយចំនួនធំដែលរស់នៅពឹងផ្អែកលើព្រៃឈើ។ ដោយមានការជួយជ្រោមជ្រែងពីសហគមន៍អន្តរជាតិ ប្រជាជន ទទួលបានការអប់រំពីរបៀបប្រើប្រាស់ និងការពារព្រៃឈើឲ្យបានល្អ ហើយតាមនេះ ប្រទេសកម្ពុជានឹងអាចសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាព និងការការពារជីវៈចម្រុះ។ នៅពេលព្រៃឈើមានការការពារល្អ សហគមន៍មូលដ្ឋានក៏អាចទទួលអត្ថប្រយោជន៍ទាំងផ្នែកសេដ្ឋកិច្ច និងមិនមែនសេដ្ឋកិច្ច[៨] ពីព្រៃសហគមន៍ ព្រោះពួកគេមានលទ្ធភាពប្រើប្រាស់ដី និងមានសិទ្ធិស្របច្បាប់ក្នុងការប្រើប្រាស់ព្រៃឈើ[៩]។ សហគមន៍ព្រៃឈើនៅទូទាំងប្រទេស បានរាយការណ៍ពីការថយចុះច្រើននៃសកម្មភាពខុសច្បាប់ផ្សេងៗក្នុងតំបន់ព្រៃឈើនៅក្រោមការគ្រប់គ្រងរបស់ពួកគេ។ ការការពារព្រៃឈើ វាជះឥទ្ធិពលផ្ទាល់ទៅលើសត្វព្រៃ និងជីវៈចម្រុះ ដែលជួយជំរុញការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ។

---

[៧] សម្រាប់ព័ត៌មានលំអិត ស្តីពី មុខងារ និងរចនាសម្ព័ន្ធនៃរដ្ឋបាលព្រៃឈើ សូមមើល http://www/forestry.gov.kh/AboutFA/MandateEng.html

[៨] អត្ថប្រយោជន៍មិនមែនសេដ្ឋកិច្ច មានដូចជា តម្លៃខាងប្រពៃណី/ផ្លូវចិត្ត (សម្រាប់ក្រុមជនជាតិភាគតិច) និង ការបណ្តុះបណ្តាលមូលធនសង្គម និង ការភ្ជាប់ទំនាក់ទំនង។

[៩] Ministry of Foreign Affairs of Denmark, Community-based Natural Resources Management: Lessons Learned from Cambodia, Technical Advisory Services, December 2010

ដោយមានហេតុផលដូចខាងលើ រដ្ឋាភិបាល បានផ្តោតកាន់តែខ្លាំងទៅលើការបង្កើនចំណេះដឹងខាងបរិស្ថាន តាមរយៈការអប់រំប្រជាជន និងសិស្សានុសិស្សពី ការអភិរក្ស ការការពារ និង ការគ្រប់គ្រងធនធានធម្មជាតិ។ មួយចំណែកទៀត ច្បាប់ផ្តន្ទាទោសធ្ងន់ធ្ងរចំពោះអ្នកពាក់ព័ន្ធនឹងការកាប់ឈើខុសច្បាប់ ត្រូវបានផ្សព្វផ្សាយយ៉ាងខ្លាំងតាមបណ្តាញផ្សព្វផ្សាយនានា ហើយក៏មានការដាក់ទោសជនល្មើសជាច្រើននាក់ឲ្យជាប់ពន្ធនាគារដែរ។ ប៉ុន្តែតាមរបាយការណ៍ទទួលបាន ទោះបីមានការពង្រឹងអនុវត្តច្បាប់ដូច្នេះក្តី ក៏នៅតែមានសកម្មភាពកាប់ឈើខុសច្បាប់ជាច្រើនទៀតដែរ។

## ៤.៣. សត្វចិញ្ចឹម

ការចិញ្ចឹមសត្វ មានជ្រូក គោក្របី មាន់ទា ជាដើម ត្រូវតែពង្រីកថែម ព្រោះតម្រូវការអាហារវាកើនឡើង ហើយរដ្ឋាភិបាលកំពុងផ្តោតលើការកែលំអគុណភាព និងសុវត្ថិភាពអាហារ។ ដើម្បីសម្រេចគោលដៅនេះ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលរបស់ MAFF ដែលមានការិយាល័យនៅតាមខេត្តនានាដែរ បានអនុវត្តមុខងារស្របតាមគោលនយោបាយស្តីពីបសុព្យាបាល និងផលិតកម្មសត្វចិញ្ចឹម ការកែលំអសេវាបសុព្យាបាល និងការពង្រីកការផ្តត់ផ្គង់ឥណទានដល់អ្នកប្រកបរបរចិញ្ចឹមសត្វ។ នាយកដ្ឋាននេះ ក៏ទទួលខុសត្រូវផងដែរលើការអនុវត្តច្បាប់ និងបទបញ្ញត្តិស្តីពីគុណភាពនៃផលិតផលជាសត្វ ការត្រួតពិនិត្យការនាំចូល និងនាំចេញសត្វចិញ្ចឹមនៅច្រកព្រំដែន និង ការត្រួតពិនិត្យពីអនាម័យ និងស្តង់ដារភូតគាមអនាម័យ នៅតាមសត្តឃាតដ្ឋាន ។

សេចក្តីព្រាងច្បាប់ស្តីពីផលិតកម្ម និងបសុព្យាបាល ដែលគ្របដណ្តប់លើបញ្ហាខាងសុខភាពសាធារណៈ និងបសុព្យាបាលនោះ បានផ្តួចផ្តើមធ្វើឡើងនៅដើមឆ្នាំ២០០៩ ដោយមានជំនួយគាំទ្រពី USAID និង FAO។ ច្បាប់នេះសំខាន់បំផុត ព្រោះកម្ពុជា គឺជាចំណុចឆ្លងកាត់មួយសម្រាប់ការនាំយកសត្វគោក្របីពីប្រទេសថៃ ទៅប្រទេសវៀតណាម។ ក្រុមហ៊ុនពាណិជ្ជកម្មជ្រូក និងគោក្របីទ្រង់ទ្រាយធំ ហាក់មានឥទ្ធិពលខ្លាំងលើពាណិជ្ជកម្មសត្វចិញ្ចឹម ទាំងនៅកម្ពុជា និងរវាងប្រទេសជិតខាង។ ក្រុមហ៊ុនទាំងនោះទទួលបានការការពារល្អ តាមរយៈទំនាក់ទំនងកម្រិតខ្ពស់នៅថ្នាក់ក្រសួង ដែលធ្វើឲ្យពួកគេបញ្ចុះបញ្ចូលប្រើប្រាស់បានទាំង ពាណិជ្ជករសត្វចិញ្ចឹម នគរបាល យោធា និង មន្ត្រីពេទ្យសត្វ ( FAO *et al*. 2009: 21-22 )។

បច្ចុប្បន្នមិនទាន់មានវិធានជាក់លាក់ណាសម្រាប់ជំរុញវិនិយោគផ្នែកសត្វចិញ្ចឹមទេ ប៉ុន្តែច្បាប់ស្តីពីវិនិយោគបានចែងថា វិនិយោគិនមានសិទ្ធិទទួលបានការលើកលែងពន្ធគយ ប្រសិនបើមានដំណើរការផលិតកម្មសត្វចិញ្ចឹមច្រើនជាង ១000ក្បាល ឬ មានបក្សីនិងស៊ុត លើសពី ១0000ក្បាល ឬ គ្រប់គ្រងហ្វូងសត្វចិញ្ចឹមយកទឹកដោះ លើសពី ១00 ក្បាល។ ទោះបីមិនទាន់មានគោលនយោបាយជាក់លាក់ក្តី ក៏នីតិវិធីសម្រាប់ការវិនិយោគជារួម គឺ ស្របគ្នានឹងការលើកឡើងនៅខាងលើ។ បញ្ហាផុសឡើងក្នុងវិស័យនេះ តែងមានលើកឡើងជារឿយៗនៅក្នុងវេទិការដ្ឋាភិបាល-ផ្នែកឯកជន ( យន្តការសម្រាប់ដោះស្រាយបញ្ហា ) ដោយក្រុមការងារផ្នែកបច្ចេកទេស លើផ្នែកកសិកម្ម និង កសិឧស្សាហកម្ម។ តួយ៉ាងបញ្ហាការរត់ពន្ធជ្រូកដែលបានរីករាលដាលប៉ះពាល់ដល់ផលិតករក្នុងស្រុក ត្រូវបានដោះស្រាយតាមរយៈ សេចក្តីណែនាំលេខ ០០១ ចុះថ្ងៃទី ១៣ សីហា ២០០៧ ស្តីពីការហាមឃាត់ការនាំចូលសាច់ជ្រូក និងជ្រូករស់។

## ៤.៤. ធនធានទឹក និងបច្ចេកវិទ្យា

ការគ្រប់គ្រងធនធានទឹក សំខាន់ខ្លាំងណាស់សម្រាប់ការអភិវឌ្ឍកសិកម្ម។ បច្ចុប្បន្ន ប្រព័ន្ធធារាសាស្ត្រកម្ពុជាមិនបានអភិវឌ្ឍគ្រប់គ្រាន់ទេ។ ការដាំដុះមួយភាគធំពឹងផ្អែកលើទឹកភ្លៀង ដូច្នេះត្រូវងាយរងគ្រោះខ្លាំងពីបម្រែបម្រួលអាកាសធាតុ។ រដ្ឋាភិបាលបានបង្កើតសហគមន៍អ្នកប្រើប្រាស់ទឹកនៅទូទាំងប្រទេស តាមរយៈការពង្រីកចំណុះអាងទឹកដើម្បីបំពេញតាមតម្រូវការ។ តាមការកំណត់ក្នុង NSDP នោះ MAFF និង ក្រសួងធនធានទឹក និងឧតុនិយម ( MoWRAM ) បានរៀបចំយុទ្ធសាស្ត្រមួយសម្រាប់វិស័យកសិកម្ម និងទឹក តាមរយៈក្រុមការងារបច្ចេកទេសខាងវិស័យកសិកម្ម និងទឹក ដែលទើបបានបង្កើតថ្មី។

ដើម្បីបង្កើនផលិតភាពកសិកម្មសម្រាប់ការប្រើប្រាស់ក្នុងស្រុក និងពាណិជ្ជកម្ម រដ្ឋាភិបាលបានធ្វើអន្តរាគមន៍បន្ថែមទៀត ដូចជាតាមរយៈ ការផ្តល់គ្រាប់ពូជគុណភាពខ្ពស់ហុចផលល្អ ការជួយសម្រួលឲ្យកសិករទទួលយកមកប្រើនូវបច្ចេកវិទ្យាកាន់តែប្រសើរ ការកាត់បន្ថយការខាតបង់ក្នុងពេល និងក្រោយពេលប្រមូលផល និង ការលើកកម្ពស់របៀបរបបធ្វើកសិកម្មបែបច្នៃប្រឌិតថ្មី ដូចជា ការគ្រប់គ្រងដំណាំចម្រុះជាដើម។ ការកាត់បន្ថយថ្លៃអគ្គិសនី ក៏នឹងជួយកាត់បន្ថយបន្ទុកចំណាយផលិតកម្មផងដែរ។

## ៤.៥. ដីសម្បទានសេដ្ឋកិច្ច និង ផលិតកម្មបែបពាណិជ្ជកម្ម

ស្របគ្នានឹងកំណើនសក្តានុពលរបស់កម្ពុជា ក្នុងការនាំចេញផលិតផលកសិកម្ម ទៅទីផ្សារពិភពលោក រដ្ឋាភិបាលបានផ្តោតអាទិភាពកាន់តែខ្លាំងលើ ផលិតកម្មកសិកម្មបែបពាណិជ្ជកម្ម ជាពិសេស ដំណាំស្រូវ និង ដំណាំកសិពាណិជ្ជកម្មផ្សេងៗ ដូចជា កៅស៊ូ និង ដំឡូងឈើ ជាដើម។ ផ្ទុយពីកសិកម្មជីវព្រឹត្តិ កសិកម្មបែបពាណិជ្ជកម្មអាចបង្កើនប្រាក់ចំណូលរបស់ប្រជាជន និងជួយលើកស្ទួយពួកគេឲ្យចាកផុតពីភាពក្រីក្រ។ កសិកម្មបែបពាណិជ្ជកម្មក៏ផ្តល់ជាឱកាសថ្មីៗសម្រាប់ឲ្យកុមារនៅជនបទបានចូលសាលារៀន ហើយនឹងជួយលើកកម្ពស់ជីវភាពរបស់ប្រជាជននៅជនបទ។ ដើម្បីសម្រេចគោលដៅនេះ រដ្ឋាភិបាល បានធ្វើអន្តរាគមន៍ជាច្រើនទាក់ទងនឹង ព័ត៌មានទីផ្សារ ឱកាសបង្កើតផលិតផលថ្មីៗឲ្យស៊ីគ្នានឹងតម្រូវការអតិថិជន កន្លែងកែច្នៃបង្កើតតម្លៃបន្ថែម ការធានាគុណភាពនិងសុវត្ថិភាពអាហារ ការជំរុញអាជីវកម្មមានផលចំណេញ និង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។

ក្រោមជំនួយគាំទ្រពី ADB តាមរយៈ កម្ចីសម្រាប់កម្មវិធីវិស័យកសិកម្ម រដ្ឋាភិបាលកម្ពុជាបានស្នើធ្វើអន្តរាគមន៍ក្នុងវិស័យកសិកម្ម នៅឆ្នាំ២០០៣ ដោយផ្តោតលើកំណែទម្រង់រចនាសម្ព័ន្ធ ហើយក្នុងនោះរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកផ្សព្វផ្សាយព័ត៌មានទាក់ទងនឹង បច្ចេកវិទ្យានិងទីផ្សារកសិកម្ម សេរីភាវូបនីយកម្មទីផ្សារនិងថ្លៃជី ការបង្កើតគោលនយោបាយឥណទានជនបទ ការដកទុនពីអនុវិស័យដំណាំកៅស៊ូ ការបង្កើតគណៈកម្មាធិការអភិវឌ្ឍជនបទនៅតាមមូលដ្ឋាន និង ការកែលំអកម្មសិទ្ធិបញ្ញា។ លើសពីនេះទៀត រដ្ឋាភិបាល បានបន្តកែលំអលទ្ធភាពប្រើប្រាស់ដីធ្លីប្រកបដោយផលិតភាព តាមការផ្តល់ប័ណ្ណកាន់កាប់ដីមានសុវត្ថិភាពដល់ប្រជាជនក្រីក្រនៅជនបទ និងការអភិវឌ្ឍពាណិជ្ជកម្មនៅតំបន់ទីក្រុង ដោយមានការគាំទ្រពីទីភ្នាក់ងារផ្តល់ជំនួយជាច្រើន ដូចជា AusAID លើផ្នែកសំអាតគ្រាប់មីន និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និង ធនាគារពិភពលោក លើផ្នែកការចុះបញ្ជីដីធ្លី។

ដូចមានពិភាក្សាពីខាងដើម ELCs ជាយន្តការមួយដើម្បីផ្តល់ដីឯកជនរបស់រដ្ឋ[១០] ទៅឲ្យអ្នកទទួលសម្បទានសម្រាប់ការងារកសិឧស្សាហកម្ម ដូចជា ចំការដើមឈើ ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ក៏ដូចជា រោងចក្រសម្រាប់កែច្នៃវត្ថុធាតុដើមកសិកម្មផងដែរ។ ព្រមគ្នានឹងការផ្តល់ដីទំនេរធំៗ និង/ឬ ដីគ្មានការអនុញ្ញាត ក្នុងរូបភាពជា ELC ទៅឲ្យវិនិយោគិនកម្ពុជានិងបរទេសនោះ រដ្ឋាភិបាល និងវិនិយោគិនឯកជន ក៏កំពុងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទផ្សេងៗ ដូចជា ផ្លូវថ្នល់ ស្ពាន ទីផ្សារ និង មន្ទីរពេទ្យជាដើម។ ប្រាក់ចំណូលបានពីការងារ ដែលក្រុមហ៊ុនទាំងនេះបានបង្កើតឡើងអាចជួយលើកកម្ពស់កម្រិតជីវភាពរបស់សហគមន៍មូលដ្ឋាន។

អនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច បានដាក់អនុវត្តនៅថ្ងៃទី ២៧ ធ្នូ ២០០៥ ដើម្បីចាប់ឱកាសទាញយកផលប្រយោជន៍ពីសកម្មភាពអភិវឌ្ឍន៍កសិកម្មអតិផលនិងកសិឧស្សាហកម្ម បង្កើនចំនួនការងារនៅតំបន់ជនបទ និងបង្កើតប្រាក់ចំណូលសម្រាប់រដ្ឋ និងខេត្តនានា។ មាត្រា២៩ នៃអនុក្រឹត្យនេះ ចែងថា MAFF ក្នុងឋានៈជាប្រធាននៃលេខាធិការដ្ឋានបច្ចេកទេស និងជាអង្គភាពអន្តរក្រសួងមួយ មានសិទ្ធិនិងទំនួលខុសត្រូវលើការផ្តល់ ELCs ដែលមានទំហំធំជាង ១០០០ហិកតា រីឯអភិបាលខេត្ត/ក្រុង មានសិទ្ធិនិងទំនួលខុសត្រូវលើការផ្តល់ ELCs ទំហំតូចជាង ១០០០ហិកតា។ ទោះយ៉ាងនេះក្តី MAFF តែងសុំការយល់ព្រមពីទីស្តីការគណៈរដ្ឋមន្ត្រី ជានិច្ច មុននឹងសម្រេចផ្តល់ដីសម្បទានទៅឲ្យក្រុមហ៊ុនវិនិយោគណាមួយ។

---

[១០] ផ្អែកតាមអនុក្រឹត្យ ELC អាចប្រើជាឧបករណ៍ផ្លូវច្បាប់មួយដើម្បីបំប្លែងដីសាធារណៈរបស់រដ្ឋ ទៅជា ដីឯកជនរបស់រដ្ឋ (មាត្រា ១៤ និង ១៥ នៃច្បាប់ភូមិបាល ឆ្នាំ២០០១)

ច្បាប់បានតម្រូវឲ្យធ្វើការសិក្សាពីសមិទ្ធិលទ្ធភាព និងវាយតម្លៃពីផលប៉ះពាល់ខាងសង្គម និងបរិស្ថាន មុនពេលយល់ព្រមចុះកិច្ចសន្យា។ សម្ភាសន៍ជាមួយក្រុមហ៊ុន ELC មួយ បានឲ្យដឹងថា ដើម្បីឆាប់បានការអនុម័តលើគម្រោងវិនិយោគ ក្រុមហ៊ុនត្រូវជួលប្រើទីប្រឹក្សាក្នុងស្រុកដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយមន្ត្រី MAFF ដើម្បីឲ្យធ្វើការសិក្សាពីសមិទ្ធិលទ្ធភាព និងវាយតម្លៃពីផលប៉ះពាល់ខាងបរិស្ថាន។ ដំណើរការនេះអាចអូសបន្លាយ ប្រសិនបើក្រុមហ៊ុនប្រើប្រាស់តែទីប្រឹក្សាអន្តរជាតិ។ ទោះបីមានការសិក្សាពីសមិទ្ធិលទ្ធភាព និងការកំណត់ព្រំដែនគម្រោងមុននឹងទទួលបានការអនុម័តក្តី ក៏បញ្ហាទាមទារកម្មសិទ្ធិត្រួតគ្នានៅតែកើតមានរវាងអ្នកភូមិ និងក្រុមហ៊ុន ELC ។ អភិបាលខេត្ត និងក្រុមប្រឹក្សាឃុំ តែងដើរតួនាទីជាអ្នកសម្របសម្រួលនៅពេលមានជម្លោះកើតឡើង។ ទោះយ៉ាងនេះក្តី អ្នកភូមិតែងត្រូវខកចិត្តជារឿយៗចំពោះដំណោះស្រាយដែលក្រុមហ៊ុនផ្តល់ឲ្យ ហើយខាងអាជ្ញាធរមូលដ្ឋានក៏មានអារម្មណ៍ដូច្នេះដែរ (សូមមើលផ្នែកទី៥ សម្រាប់ការវិភាគបន្ថែម)។

NSDP ឆ្នាំ២០០៩-១៣ មានចែងពីវិធានការគោលនយោបាយជាច្រើនទៀត ដើម្បីជំរុញវិស័យកសិកម្ម ដូចជាកំណែទម្រង់ដីធ្លី ការសំអាតមីន ការពង្រឹងការគ្រប់គ្រង ការបែងចែក និងការប្រើប្រាស់ដីធ្លី ការធានាកម្មសិទ្ធិដីធ្លី ការទប់ស្កាត់ការកាន់កាប់ដីខុសច្បាប់ និង ការទប់ស្កាត់ការប្រមូលផ្តុំដីមិនប្រើប្រាស់ក្នុងដៃបុគ្គលមួយចំនួនតូច។ ម្យ៉ាងទៀតមានការផ្តល់ដីសម្បទានសង្គមកិច្ច(SLC)[១១] ទៅឲ្យកសិករមានដីតូចៗដើម្បីជំរុញផលិតកម្មនិងពិពិធកម្ម។ ការសំអាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ដើម្បីយកដីបម្រើកសិកម្ម គឺជាអាទិភាពខ្ពស់បំផុតមួយរបស់រដ្ឋាភិបាល ដើម្បីឲ្យកសិករ និងវិនិយោគិន អាចទទួលបានដីធំៗ និងពង្រីកផលិតកម្មនៅតំបន់ឆ្ងាយៗ ។

## ៤.៦. ស្រូវ

កម្ពុជាព្យាយាមចាប់យកឱកាសថ្មីៗនៅក្នុងអនុវិស័យស្រូវ ជាពិសេសចាប់ពីពេលមានការឡើងថ្លៃអាហារក្នុងឆ្នាំ ២០០៧ និង ២០០៨ មក។ អង្ករមិនត្រឹមតែជាអាហារមូលដ្ឋានសម្រាប់ប្រជាជនកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែក៏ជាប្រភពចំណូលប្រកបដោយសក្តានុពលខ្ពស់របស់ប្រទេសជាតិដែរ។ រដ្ឋាភិបាលបានជំរុញវិនិយោគក្នុងអនុវិស័យស្រូវ ក្នុងនោះមានទាំងការលើកលែងពន្ធលើគ្រាប់ពូជ ជី និង ថ្នាំសម្លាប់សត្វចង្រៃដើម្បីជំរុញផលិតកម្មផង។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានអំពាវនាវឲ្យមានវិនិយោគកាន់តែច្រើនអំពីវិនិយោគិនក្នុងស្រុក និងបរទេស ខាងផ្នែកម៉ាស៊ីនកិនស្រូវដែរ។[១២] ការជំរុញការកែច្នៃស្រូវ ជាពិសេស ការកិន និងវេចខ្ចប់ នឹងជួយកែលំអគុណភាពអង្ករ កាត់បន្ថយបន្ទុកចំណាយផលិតកម្ម បង្កើនតម្លៃបន្ថែម និង តម្រង់រកទីផ្សារនាំចេញ។ ក្នុងអំឡុងពេលសិក្សា ផលិតកម្មស្រូវរំពឹងថានឹងឡើងដល់ប្រហែល ៧លានតោន ក្នុងឆ្នាំ២០១០/១១ ក្នុងនេះ ការប្រើប្រាស់ក្នុងស្រុកមានប្រហែល ៣លានតោន។ កំណើនផលិតកម្មនេះ បណ្តាលជាចំបងមកពីវិនិយោគខាងផ្នែកធារាសាស្ត្រ ការពង្រីកនិងប្រពលវប្បកម្មដីដាំដុះ និងការប្រើបច្ចេកទេសដាំដុះ និងគ្រាប់ពូជកាន់តែល្អ។

ដោយទទួលស្គាល់ពីតួនាទីសំខាន់នៃអនុវិស័យស្រូវ ក្នុងការពង្រីកកំណើន និងកាត់បន្ថយភាពក្រីក្រ រដ្ឋាភិបាលបានបង្កើតគោលនយោបាយ ស្តីពី "ផលិតកម្មស្រូវ និងការជំរុញការនាំចេញអង្ករ" នៅពាក់កណ្តាលឆ្នាំ២០០០ សំដៅសម្រេចឲ្យបានអតិរេកផលិតកម្មស្រូវ ៤លានតោន និង ការនាំចេញអង្ករយ៉ាងហោចណាស់ ១លានតោន នៅត្រឹមឆ្នាំ២០១៥ តាមរយៈការបន្តវិនិយោគក្នុងប្រព័ន្ធធារាសាស្ត្រ ការលើកទឹកចិត្តដល់វិនិយោគឯកជនក្នុងការកែច្នៃ និងនាំចេញអង្ករ និង ការកែលំអនីតិវិធីដើម្បីសម្រួលដល់ការនាំចេញ និងដឹកជញ្ជូន។ ទោះយ៉ាងនេះក្តី អនុវិស័យស្រូវនៅជួបបញ្ហាប្រឈម ដោយសារការទ្រទ្រង់ផ្នែកស្ថាប័ន និងអភិបាលកិច្ចនៅទន់ខ្សោយ។ តាមការសិក្សាពីឌីណាមិកនៃអភិបាលកិច្ច និងកំណើនឧស្សាហកម្មស្រូវនៅកម្ពុជា Ear (2009) បានរកឃើញថា ការនាំចេញអង្ករនៅមានចំណុច

---

១១ លក្ខណៈវិនិច្ឆ័យ សម្រាប់ SLC មិនមានការកម្រិតពេលវេលាទេ ហើយផ្តល់ផ្ទៃដីអតិបរមា ១.២៥០ម២ សម្រាប់លំនៅដ្ឋាន និង ២ហិកតា សម្រាប់ការងារកសិកម្ម។ ដីនេះអាចផ្ទេរទៅជាកម្មសិទ្ធិឯកជនបាន។

១២ វិទ្យុអាស៊ីសេរី ថ្ងៃទី២២ មីនា ២០១១

ខ្វះខាតសំខាន់មួយ ដោយសារស្ថាប័នពីរ គឺ ក្រុមហ៊ុនពាណិជ្ជកម្មបៃតង (GTC) ដែលជាកម្មសិទ្ធិរបស់រដ្ឋ និង សមាគមជាតិម៉ាស៊ីនកិនស្រូវកម្ពុជា (NCRMA) ដែលដឹកនាំដោយប្រធាន GTC នោះ ទទួលបានការអនុញ្ញាតឲ្យនាំចេញអង្ករលើសពី ១០០តោន ដោយមិនបាច់មានអាជ្ញាប័ណ្ណនាំចេញ។ អ្នកនាំចេញធំមួយទៀត គឺ អង្គរកសិកម្មរុងរឿង ទទួលបានអាជ្ញាប័ណ្ណនាំចេញ តាមរយៈបណ្តាញរបស់ខ្លួនក្នុងរដ្ឋាភិបាល។

### ៤.៧. កៅស៊ូ

ដើម្បីកសាងអនុវិស័យកៅស៊ូឡើងវិញ រដ្ឋាភិបាលបានចាប់ផ្តើមធ្វើវិនិយោគក្នុងផលិតកម្មសម្រាប់ការប្រើប្រាស់ក្នុងស្រុក។ ក្រោយមកទៀត កៅស៊ូកម្ពុជាក៏ចាប់ផ្តើមឈានចូលទីផ្សារអន្តរជាតិ ជាពិសេស ទីផ្សារវៀតណាម និង ចិន។ បន្ទាប់មក រដ្ឋាភិបាលបានធ្វើកំណែទម្រង់គោលនយោបាយ និងស្ថាប័នសំខាន់ៗជាច្រើន ដើម្បីជំរុញកំណើនកសិកម្មផ្អែកលើទីផ្សារ ដោយមានជំនួយមូលនិធិពីទីភ្នាក់ងារខាងក្រៅ ជាពិសេស ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ រដ្ឋាភិបាល បានចាប់ដកខ្លួនចេញពីការធ្វើអន្តរាគមន៍ផ្ទាល់នៅក្នុងផលិតកម្ម និងការធ្វើម៉ាឃីទីងផលិតផលកសិកម្ម និង កសិឧស្សាហកម្ម បើទោះជាដីដាំកៅស៊ូរបស់រដ្ឋ នៅបន្តគ្របដណ្តប់លើ ៨០% នៃផ្ទៃដីដាំកៅស៊ូសរុបនៅកម្ពុជា រហូតដល់ឆ្នាំ២០០៤ ដែលនៅពេលនោះមានការឡើងថ្លៃកៅស៊ូក្នុងពិភពលោក (ADB 2003)។

ការបន្តកម្មសិទ្ធិរដ្ឋដូចខាងលើ បានបង្កជាឧបសគ្គដល់កំណើននៃអនុវិស័យទាំងមូល ដោយរារាំងដល់ការអភិវឌ្ឍផលិតកម្មកៅស៊ូជាលក្ខណៈគ្រួសារ និងជាចំការតូចៗ ព្រមទាំងសកម្មភាពកែច្នៃ និងធ្វើម៉ាឃីតទីងខ្នាតតូច (ADB 2003)។ គុណភាពក៏ចោទបញ្ហាដែរ ដែលនាំឲ្យកៅស៊ូកម្ពុជាលក់បានថោក កៅស៊ូរបស់ប្រទេសដទៃទៀតដល់ទៅ ១៥-២០% នៅលើទីផ្សារពិភពលោក ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ និង បំពេញតាមលក្ខខណ្ឌរបស់ ADB រដ្ឋាភិបាលបានផ្តួចផ្តើមធ្វើការពិនិត្យឡើងវិញជាទូទៅលើអនុវិស័យកៅស៊ូ និង បានពិនិត្យពីវិធាន និងបទបញ្ញត្តិនានាសម្រាប់ការផ្សព្វផ្សាយលក់ផលិតផលកៅស៊ូ។ ពីឆ្នាំ២០០០ ដល់ ២០០៦ មានការធ្វើកំណែទម្រង់គោលនយោបាយ និង បទបញ្ញត្តិជាច្រើន ដើម្បីជំរុញការដាំកៅស៊ូទ្រង់ទ្រាយតូច និង រោងចក្រកែច្នៃកៅស៊ូឯកជន ក៏ដូចជា បង្កើនកន្លែងប្រមូលទិញផលកៅស៊ូផងដែរ។ កំណែទម្រង់ទាំងនេះ បានជួយសម្រួលដល់ការផ្សព្វផ្សាយលក់ និងផលិតកម្មកៅស៊ូឯកជន (សារាចរលេខ ២៨២៦ SCN.KSK ស្តីពី "ការប្រកាសពីការជួញដូរ និងស្ថានីយ៍ទិញកៅស៊ូពីចំការជាលក្ខណៈគ្រួសារ" ចុះថ្ងៃទី ១៣ មិថុនា ២០០៥) និង បានផ្តល់នូវយន្តការផ្សេងៗសម្រាប់ស្តង់ដារូបនីយកម្មគុណភាពកៅស៊ូ ដែលអាចធ្វើឲ្យកៅស៊ូកម្ពុជាលក់បានថ្លៃជាងមុននៅលើទីផ្សារពិភពលោក (ប្រកាសលេខ 086 RBK.KSK ស្តីពី "ការអនុវត្តបទបញ្ញត្តិស្តីពីចំណាត់ថ្នាក់គុណភាពកៅស៊ូនៅកម្ពុជា" ចុះថ្ងៃទី ១៧ មីនា ២០០៤)។

ឧបសគ្គខាងបទបញ្ញត្តិចម្បងៗ ចំពោះការផ្សព្វផ្សាយលក់ផលិតផលកៅស៊ូ (ADB 2009; SOFRECO & CEDAC 2005; Tasker 2003) មានដូចតទៅ៖

១. ភាពផ្ទុយគ្នារវាង បទបញ្ញត្តិគាំទ្រផលិតកម្មកៅស៊ូទ្រង់ទ្រាយតូច និងបទបញ្ញត្តិដាក់កំហិតលើការជួញដូរផលិតកម្មប្រភេទនោះ
២. ការដាក់កំហិតលើការនាំចេញកៅស៊ូមិនទាន់កែច្នៃ និងឈើកៅស៊ូ
៣. ការដាក់កំហិតលើការនាំចេញកៅស៊ូកែច្នៃរួច លើកលែងតែមានការយល់ព្រម
៤. កង្វះការបញ្ជាក់ជាលិខិតស្នាមលើផលិតផលកៅស៊ូ
៥. របបពន្ធនាំចេញខ្ពស់ពេក
៦. ការបញ្ចុះថ្លៃលើកៅស៊ូកម្ពុជា
៧. តម្រូវការបំពេញសំណុំបែបបទច្រើនពេក សម្រាប់ការដឹកជញ្ជូន និងការនាំចេញ
៨. ការយកប្រាក់កម្រៃក្រៅផ្លូវការ លើការដឹកជញ្ជូន។

# ៥

# ការវាយតម្លៃជាដំបូងៗពីផលប៉ះពាល់នៃ វិនិយោគផ្ទាល់ពីបរទេសនៅលើវិស័យកសិកម្ម

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ មានកំណើនចំណាប់អារម្មណ៍ធ្វើវិនិយោគក្នុងវិស័យកសិកម្ម និងដីធ្លី នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស នៅកម្ពុជា។ ប៉ុន្តែក្រុមចំណាប់អារម្មណ៍ផ្សេងៗ ក៏បានលើកឡើងនូវក្តីបារម្ភពីហានិភ័យនៃការធ្វើវិនិយោគប្រភេទនេះដែរ។ ការសិក្សាមួយធ្វើឡើងដោយ German Technical Cooperation (GTZ) ក្នុងឆ្នាំ២០០៩ បានកំណត់ទាំងឱកាស និង ហានិភ័យផ្សេងៗផុសចេញពីវិនិយោគបរទេស ក្នុងវិស័យដីធ្លីនៅកម្ពុជា ដូចមានគូសបញ្ជាក់នៅខាងក្រោម។

*ទិដ្ឋភាពផ្នែកសេដ្ឋកិច្ច-សង្គមកិច្ច៖* នៅកម្រិតម៉ាក្រូ គេមានភស្តុតាងបញ្ជាក់ពី (១) ការបង្កើតការងារក្នុងផ្នែកផលិតកម្មជីវតន្ទនៈ ដែលផ្តល់បៀវត្សរ៍ជាមធ្យម ១០០ដុល្លារ/ខែ (២) ការកែលំអផ្លូវថ្នល់មូលដ្ឋាន ប៉ុន្តែក៏មានការខូចខាត ផ្លូវថ្នល់សហគមន៍ដែរ ដោយសាររថយន្តធំៗរបស់ក្រុមហ៊ុនវិនិយោគដឹកទំនិញធ្ងន់ឆ្លងកាត់ (៣) ការបង្កើតចំណូលរូបិយប័ណ្ណ តាមរយៈការនាំចេញឈើនិងផលិតផលធ្វើពីឈើ កៅស៊ូ កប្បាស ប្រេងសំខាន់ៗ ត្រី និងសត្វរស់ និង (៤) ការរួមចំណែកក្នុងថវិការដ្ឋាភិបាល តាមរយៈការបង់ថ្លៃដីសម្បទាន ក្នុងចន្លោះពី 0-១០ដុល្លារ/ហិកតា រាល់ឆ្នាំ។ នៅកម្រិតមីក្រូ ក៏មានហានិភ័យខ្លះដែរ ជាអាទិ៍ គេឃើញមានភស្តុតាងបញ្ជាក់ពី (១) ឥទ្ធិពលអវិជ្ជមានលើលទ្ធភាពប្រើប្រាស់ដីរបស់ប្រជាជនដើម (២) ការបាត់បង់ឱកាសរបស់សហគមន៍ក្នុងការប្រមូលអនុផលព្រៃឈើ (៣) អវត្តមានឬកង្វះការផ្ទេរជំនាញបច្ចេកទេសពីសហគ្រាសបរទេស ទៅឲ្យកសិករ ដូចជា ការបង្កាត់ពូជ ការប្រើប្រាស់គ្រាប់ពូជប្រភេទថ្មីៗ ការកែលំអគុណភាពដី ឬ ការប្រើជី ជាដើម។ ឱកាសផ្សេងៗ ក៏បានផុសឡើងដែរ មានតាំងពីការរកចំណូលបានទ្វេដងសម្រាប់ពលករក្នុងវិស័យកសិកម្ម និងពលករសំណង់គ្មានជំនាញ រហូតដល់ ការកសាងសាលារៀន និងមណ្ឌលសុខភាពនៅជនបទ។

*សន្តិសុខស្បៀង៖* សន្តិសុខស្បៀងសហគមន៍ អាចរងការប៉ះពាល់តាមរយៈការបាត់បង់លទ្ធភាពរបស់សហគមន៍ក្នុងការបេះប្រមូលអនុផលព្រៃឈើ។ Hansen *et al.* (2006) បង្ហាញថា អនុផលព្រៃឈើរួមចំណែកប្រហែល ៤២% នៃចំណូលរបស់គ្រួសារក្រីក្រ និង ៣០% នៃចំណូលរបស់គ្រួសារមធ្យមនៅតាមសហគមន៍ជនបទនៅកម្ពុជា។ ការសិក្សានេះរកឃើញដែរថា វិនិយោគបរទេសក្នុងវិស័យដីធ្លី ហាក់មិនមានឥទ្ធិពលអវិជ្ជមាន ទៅលើសន្តិសុខស្បៀងសហគមន៍នៅក្នុងរយៈពេលខ្លីនោះទេ។

*បរិស្ថាន៖* វិនិយោគបរទេសក្នុងវិស័យដីធ្លីបង្កើតទាំងផលចំណេញ និងហានិភ័យចំពោះបរិស្ថាន។ ប្រទេសម្ចាស់ផ្ទះអាចទទួលបានផលចំណេញពីការនាំចូលបច្ចេកវិទ្យាថ្មីៗ និងវិធីធ្វើផលិតកម្មកសិកម្មមិនសូវខូចខាតដល់បរិស្ថានព្រមទាំង ការកាត់បន្ថយសំណឹកដីតាមរយៈផលិតកម្មកសិកម្មលើដីធ្លីដែលទុកចោលទំនេរពីមុន។ ប៉ុន្តែអត្ថប្រយោជន៍ក៏នាំមកនូវហានិភ័យតាមក្រោយដែរ។ ក្តីបារម្ភខាងបរិស្ថានទាក់ទងនឹងវិនិយោគបរទេសទ្រង់ទ្រាយធំ រួមមាន បម្រែបម្រួលអាកាសធាតុ និងសំណឹកដី គុណភាពនិងសន្តិសុខជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីនៅមូលដ្ឋាន។

ដោយមានក្តីបារម្ភដូចបានគូសបញ្ជាក់ខាងលើ និងការផ្តោតជាក់លាក់លើវិនិយោគបរទេសក្នុងវិស័យកសិកម្ម (មិនផ្តោតលើដីធ្លីជាទូទៅទេ) ការសិក្សានេះព្យាយាមបំភ្លឺពីផលប៉ះពាល់ដែលអាចកើតចេញពីវិនិយោគបរទេសក្នុងវិស័យកសិកម្ម ទៅលើជីវភាពសហគមន៍មូលដ្ឋាន បរិស្ថាន សន្តិសុខស្បៀង និង ការប្រើប្រាស់ទឹកនិងដីធ្លី។

ផ្អែកលើទិន្នន័យរបស់ CDC ពីឆ្នាំ២០០០ ដល់ ខែមិថុនា ២០១០ ការសិក្សានេះរកឃើញថា វិនិយោគិនបរទេសក្នុងវិស័យកសិកម្ម ផ្តោតជាចម្បងលើដំណាំ និងព្រៃឈើ ក្នុងទម្រង់ជា ELCs រីឯខាងផ្នែកកែច្នៃស្បៀងអាហារវិញ ពួកគេ

ផ្តោតជាសំខាន់លើ ផលិតកម្មទឹកបរិសុទ្ធ ទឹកសណ្តែក និង មីកញ្ចប់/កំប៉ុង។ ដោយឡែក ផ្នែកនេះ ផ្តោតលើ វិនិយោគបរទេសទាក់ទងនឹង ដំណាំ (អំពៅ កៅស៊ូ ពោត) និង ព្រៃឈើ ដើម្បីកំណត់ពីផលប៉ះពាល់អាចកើតចេញពីវិនិយោគប្រភេទនេះ។

ការវាយតម្លៃនៅខាងក្រោម ផ្អែកលើលទ្ធផលបានពី ការពិភាក្សាតាមក្រុមស្នូល (FGDs) ដែលអនុវត្តដោយក្រុមស្រាវជ្រាវនៅខែធ្នូ ២០១០ ក្នុងខេត្តកំពង់ធំ សម្រាប់ករណីសិក្សាពីកៅស៊ូ ដោយមានការពិគ្រោះយោបល់ជាមួយក្រុមហ៊ុនដាំនិងសម្ងួតពោតឈ្មោះ HLH Agriculture និង ការពិភាក្សាតាមក្រុមស្នូល (FGDs) ដែល CDRI បានធ្វើកន្លងមកក្នុងការសិក្សាពីផលប៉ះពាល់នៃវិនិយោគទុនចិនខាងផ្នែកធនធានធម្មជាតិ ទៅលើសហគមន៍ក្នុងខេត្តក្រចេះ និង ស្ទឹងត្រែង (Hem & Tong 2010) ព្រមទាំង ករណីសិក្សាពីកៅស៊ូក្នុងខេត្តមណ្ឌលគិរី និង អំពៅក្នុងខេត្តកោះកុង ដែលសមាគមសេដ្ឋកិច្ចកម្ពុជា (Ngo & Chan 2010) បានធ្វើឡើងកាលពីខែឧសភា និង មិថុនា ២០១០ (តារាង ១០)។

តារាង ១០៖ សង្ខេបពីការចុះសិក្សាដល់កន្លែង អនុវត្តដោយ CDRI និង សមាគមសេដ្ឋកិច្ចកម្ពុជា (CEA) ក្នុងឆ្នាំ២០១០

| ល.រ | ក្រុមហ៊ុន | ទំហំ (ហិកតា) | ទីតាំង | អនុវិស័យ | ប្រភព |
|---|---|---|---|---|---|
| 1 | Koh Kong Plantation Ltd (Thailand, Japan, China, Cambodia) | 9400 | ស្រុកបុទមសាគរ ខេត្តកោះកុង | ចំការអំពៅ | CEA ខែមិថុនា 2010 |
| | Koh Kong Sugar Company Ltd (Thai) | 9700 | ឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង | កែច្នៃអំពៅ | CEA ខែមិថុនា 2010 |
| 2 | Socfin KCD (Belgium-Cambodia) | 10000 | ឃុំប៊ូស្រា ខេត្តមណ្ឌលគិរី | ចំការកៅស៊ូ | CEA ខែឧសភា 2010 |
| | DAK LAK (Vietnam) | 4000 | ឃុំប៊ូស្រា ខេត្តមណ្ឌលគិរី | ចំការកៅស៊ូ | |
| 3 | Tong Ming Group Engineering (China) | 7465 | ឃុំក្បាលដំរី ខេត្តក្រចេះ | ដាំដើមឈើ (អាកាស្យា) | CDRI ខែមេសា 2010 |
| 4 | Tan Bien-Kompong Thom Rubber Development (Vietnam) | 8100 | ឃុំក្រយា ខេត្តកំពង់ធំ | ចំការកៅស៊ូ | CDRI ខែធ្នូ 2010 |
| 5 | HLH Agriculture (Singapore) | 9800 (ឱរ៉ាល់)<br>4500(អមលាំង) | ស្រុកឱរ៉ាល់ និង ឃុំអមលាំង ខេត្តកំពង់ស្ពឺ | ចំការពោត និងសម្ងួត | CDRI ខែវិច្ឆិកា 2010 |

ប្រភព៖ Ngo & Chan (2010: Nos. 1, 2); Hem & Tong (2010: Nos. 3, 4)

ជាទូទៅគម្រោង FDI នីមួយៗមានទាំងឥទ្ធិពលវិជ្ជមាន និងអវិជ្ជមាន ទៅលើបរិស្ថាន និងជីវភាពរបស់សហគមន៍មូលដ្ឋាន ហើយទំហំឥទ្ធិពលនោះ ប្រែប្រួលខុសគ្នាទៅតាមអនុវិស័យនីមួយៗ។ ការសិក្សានេះ មិនប្រើប្រាស់ការវាយតម្លៃពីផលប៉ះពាល់លើអនុវិស័យមួយទាំងមូលទេ ប៉ុន្តែប្រើប្រាស់ករណីសិក្សាដើម្បីបង្កើតជាគំនិត និងលើកកម្ពស់ចំណាប់អារម្មណ៍ក្នុងចំណោមអ្នកពាក់ព័ន្ធនានា ជាពិសេស អ្នកធ្វើគោលនយោបាយ។ ដូច្នេះ មិនគួរយកលទ្ធផលទាំងនេះ ទៅធ្វើការសន្និដ្ឋានជារួមលើអនុវិស័យទាំងមូលទេ។

### ៥.១ ដំណាំ

ករណីសិក្សាពីដំណាំ គ្របដណ្ដប់លើគម្រោងផ្សេងៗ មាន ផលិតកម្មអំពៅមួយកន្លែង ចំការកៅស៊ូពីរកន្លែង និងចំការពោតមួយកន្លែង។ គម្រោងទាំងនេះ មិនមែនជ្រើសរើសដោយចៃដន្យ ដោយប្រើកត្តាមួយចំនួន ដូចជា ទំហំដី ទីតាំងភូមិសាស្ត្រ ប្រភេទដំណាំ ឬ សញ្ជាតិក្រុមហ៊ុននោះទេ ប៉ុន្តែតាមរយៈការគិតគូរពីសារៈសំខាន់នៃគម្រោងទាំងនោះ និងកម្រិតឱកាសសម្រាប់ការសិក្សា។

#### *៥.១.១ ចំការអំពៅនៅខេត្តកោះកុង*

*ក្រុមហ៊ុន Koh Kong Plantation Ltd និង Koh Kong Sugar Company Ltd*

ផ្អែកលើអង្កេតធ្វើឡើងដោយ CEA ក្រុមហ៊ុន ELC ពីរ នៅក្រោមឈ្មោះអ្នកតំណាងមួយរូបគឺ លោក លី យ៉ុងផាត់ បានទទួលអាជ្ញាប័ណ្ណចំការអំពៅពីរដ្ឋាភិបាលកម្ពុជា (Ngo & Chan 2010)។ ផ្ទៃដីដាំដុះមានប្រហែល ២០.០០០ហិកតា ដែលក្នុងនោះ ៩៤០០ហិកតា ជារបស់ក្រុមហ៊ុន Koh Kong Plantation Ltd ក្នុងស្រុកបុទុមសាគរ និង ៩៧០០ហិកតា ជារបស់ក្រុមហ៊ុន Koh Kong Sugar Company Ltd ក្នុងស្រុកស្រែអំបិល។ អំពៅ ត្រូវយកទៅកែច្នៃនៅរោងចក្ររបស់ Koh Kong Sugar ដែលមានសមត្ថភាពផលិតកម្ម ៦០០០តោន/ថ្ងៃ ហើយការវេចខ្ចប់សម្រាប់នាំចេញទៅទីផ្សារសហភាពអឺរ៉ុប។ CEA បានធ្វើអង្កេតក្នុងភូមិត្រពាំងកណ្ដាល និង ជីខលើ ដោយបានសម្ភាសជាមួយ ១៤៣គ្រួសារ ដើម្បីវាយតម្លៃពីផលប៉ះពាល់នៃចំការអំពៅទៅលើ ភាពមានការងារធ្វើ ការផ្លាស់ប្ដូរជីវភាព និង ការជួញដូរដីធ្លី។

***ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច-សង្គមកិច្ច៖*** ក្រុមហ៊ុនបានបង្កើត ការងារជំនាញ ការងារពាក់កណ្ដាលជំនាញ និងការងារគ្មានជំនាញ ជាច្រើន សម្រាប់ប្រជាជនមូលដ្ឋាន និងអ្នករស់នៅក្នុងតំបន់ជុំវិញនោះ និងក្នុងខេត្តផ្សេងៗទៀត។ ទៅតាមរដូវកាល ការងារទាំងនេះ រួមមាន ការរៀបចំដី ការដាំអំពៅ ការដាក់ជី ការកម្ចាត់សត្វចង្រៃ ការជម្រះស្មៅ ការប្រមូលផល ការប្រមូលនិងដឹកជញ្ជូន។ អំឡុងពេលដាំដុះ និងប្រមូលផល ពីខែវិច្ឆិកា ដល់ ឧសភា ជារដូវសម្បូរការងារបំផុត។ ក្នុងឆ្នាំ២០០៩ ក្រុមហ៊ុនបានជួលពលករស៊ីប្រាក់ថ្ងៃ ២៤០០នាក់ (៣០% មកពីខេត្តកោះកុង) នៅរដូវមមាញឹកបំផុត ធៀបនឹង ប្រហែលតែ ១៣០០នាក់ ប៉ុណ្ណោះ ពីខែមិថុនា ដល់ តុលា។ ពលករទាំងនេះទទួលបានប្រាក់ឈ្នួលប្រចាំថ្ងៃ ប្រហែល ២,៥ដុល្លារ។ ក្រៅពីនេះ ក្រុមហ៊ុនបានផ្ដល់កន្លែងស្នាក់នៅ និងការដឹកជញ្ជូន ដល់ពលករចំណាកស្រុកមកពីខេត្តមួយចំនួន ដូចជា បន្ទាយមានជ័យ កំពត និង កំពង់ធំ។ ក្រុមហ៊ុនធំទាំងពីរនេះ ក៏បានផ្ដល់ការងារសរុប ៥១១កន្លែង ដល់បុគ្គលិកការិយាល័យកម្ពុជា និងថៃផងដែរ ដោយផ្ដល់ប្រាក់ថ្ងៃជាមធ្យម ៦ដុល្លារ/ថ្ងៃ។ គួរកត់សម្គាល់ថា មានប្រជាជនមូលដ្ឋានភាគតិចនាក់ណាស់ ដែលទទួលបានការងារនៅការិយាល័យ។

មុនពេលក្រុមហ៊ុនចូលមកដល់ ប្រជាជនមូលដ្ឋានចិញ្ចឹមជីវិតដោយការធ្វើស្រែវស្សា ដាំដំណាំលក់យកប្រាក់ និងចិញ្ចឹមគោក្របី។ នៅពេលក្រុមហ៊ុនចូលមកដល់ គេបានព័ទ្ធយកដីដាំដំណាំខ្លះរបស់អ្នកភូមិ ធ្វើជាចំការអំពៅ។ បញ្ហានេះបានបង្កជាជម្លោះធ្ងន់ធ្ងររវាងប្រជាជនមូលដ្ឋាន និងក្រុមហ៊ុន ដោយសារការដកយកប្រភពចំណូលរបស់កសិករនេះ។ ម្យ៉ាងទៀត គោក្របីរបស់ប្រជាជនមូលដ្ឋាន មិនអាចដើររកស៊ីដោយសេរីទៀតទេនៅលើដីកសិដ្ឋាន និងដីព្រៃ ដែលបានក្លាយជាចំណែកមួយនៃតំបន់វិនិយោគរបស់ក្រុមហ៊ុន។ ប្រសិនបើអ្នកយាមរបស់ក្រុមហ៊ុនឃើញសត្វចិញ្ចឹមរបស់អ្នកស្រុកនៅលើដីចំការ គេចាប់វាបង្ខាំងទុក ហើយជួនកាលបាញ់ទៅលើវាទៀតផង។

បន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណ ELC ក្នុងឆ្នាំ២០០៦ ក្រុមហ៊ុនបានចាប់ផ្ដើមសំអាតដីដោយគ្មានការជូនដំណឹងជាមុនដល់សហគមន៍មូលដ្ឋានទេ។ សកម្មភាពនេះបានបង្កឲ្យមានការប្រឆាំងតវ៉ាជាខ្លាំងពីប្រជាជនមូលដ្ឋាន៖ ៤៤៩ គ្រួសារ បានដាក់ពាក្យប្ដឹងពីការបាត់បង់ដីស្រែចំការ និងទ្រព្យសម្បត្តិផ្សេងៗរបស់ខ្លួន។ ទោះបីក្រុមហ៊ុនបានផ្ដល់សំណងដល់គ្រួសារដែលរងផលប៉ះពាល់ក្ដី ក៏មានការត្អូញត្អែរជាច្រើនថា សំណងនោះមិនគ្រប់គ្រាន់ និងមិនយុត្តិធម៌ទេ។ អ្នកស្រុកដែលមានសាច់ញាតិធ្វើការឲ្យក្រុមហ៊ុន ហាក់ទទួលបានសំណងច្រើនជាង គឺមានចាប់ពី ២៥ដុល្លារ ដល់ ៣៥០

ដុល្លារ។ មូលហេតុសំខាន់មួយដែលអ្នកស្រុក មិនអាចធ្វើការប្រកែកតវ៉ាខ្លាំងលើបញ្ហាដីធ្លីរបស់ខ្លួន គឺ ពួកគេភាគច្រើនមិនមានលិខិតបញ្ជាក់កម្មសិទ្ធិលើដីធ្លីដែលខ្លួនបង្កបង្កើនផលនោះទេ។

បញ្ហាចោទចម្បងនៅក្នុងជម្លោះខាងលើ រួមមាន (១) អវត្តមាននីតិវិធី ឬគោលការណ៍ណែនាំជាក់លាក់សម្រាប់ដោះស្រាយបញ្ហា (២) ដំណោះស្រាយផ្សេងៗមិនយុត្តិធម៌ដែលក្រុមហ៊ុនបានផ្តល់ទៅឲ្យគ្រួសាររងផលប៉ះពាល់ ដើម្បីសងប៉ះប៉ូវលើការខូចខាត (៣) ការជំនួសឲ្យយន្តការធម្មតាសម្រាប់ដោះស្រាយជម្លោះ ដោយប្រើនីតិវិធីដោះស្រាយតាមករណីនីមួយៗដាច់ៗពីគ្នា ដែលគ្មានតម្លាភាព និងមិនយុត្តិធម៌ (៤) ការដោះស្រាយតាមគ្រួសារដាច់ៗពីគ្នា និង (៥) ជំនួយគាំទ្រតិចតួច ឬគ្មានសោះពីអាជ្ញាធរមូលដ្ឋាន។ តំណាងសហគមន៍ម្នាក់បានលើកថា អាជ្ញាធរមូលដ្ឋានគ្មានជួយអ្វីសោះ ហេតុនេះ សហគមន៍មានការគាំទ្រតិចតួចក្នុងការស្វែងរកមធ្យោបាយដោះស្រាយជាមួយក្រុមហ៊ុន។

***ផលប៉ះពាល់ខាងបរិស្ថាន៖*** តាមសេចក្តីរាយការណ៍ ចំការអំពៅ និងរោងចក្រកែច្នៃអំពៅ បង្កើតការបំពុលពីរប្រភេទ។ ទី១ ការបំពុលទឹកប៉ះពាល់ធ្ងន់ធ្ងរដល់ការរស់នៅប្រចាំថ្ងៃរបស់សហគមន៍មូលដ្ឋាន ព្រោះសំណល់សារធាតុគីមីបានធ្វើឲ្យទឹកនៅខ្សែទឹកខាងលើកខ្វក់ ហើយប៉ះពាល់ដល់ការផ្គត់ផ្គង់ទឹកទៅសហគមន៍នៅខ្សែទឹកខាងក្រោម។ ប្រភពទឹកនេះសំខាន់បំផុតចំពោះអ្នកស្រុក ដូច្នេះ ការបំពុលនេះធ្វើឲ្យអន្តរាយទាំងចំពោះមនុស្ស និងសត្វ។ ទី២ ផ្សែងចេញពីរោងចក្រ វាបង្កជាការបំពុលខ្យល់ ដែលប៉ះពាល់មិនល្អលើដំណាំកដង្ហើមរបស់អ្នកស្រុក។

***ផលប៉ះពាល់ផ្នែកហេដ្ឋារចនាសម្ព័ន្ធ៖*** របាយការណ៍របស់ CEA មិនបានផ្តល់ព័ត៌មានពី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដោយក្រុមហ៊ុនវិនិយោគទេ។ ទោះយ៉ាងនេះក្តី ផ្លូវថ្នល់មួយចំនួនទំនងបានកសាងឡើង ដើម្បីដឹកជញ្ជូនសម្ភារៈ និងពលករ។

### *៥.១.២ ចំការកៅស៊ូក្នុងខេត្តមណ្ឌលគិរី និង កំពង់ធំ*

*ក្រុមហ៊ុន Socfin KCD និង ក្រុមហ៊ុន DAK LAK (ខេត្តមណ្ឌលគិរី)*

នៅខែឧសភា ២០១០ CEA បានធ្វើអង្កេតមួយលើចំការកៅស៊ូ ក្នុងឃុំប៊ូស្រា និង ឃុំក្រេងតេះ ក្នុងស្រុកពេជ្រចិន្តា ខេត្តមណ្ឌលគិរី (Ngo & Chan 2010)។ ក្រុមហ៊ុន ELC ចំនួន៨ ទទួលបានអាជ្ញាប័ណ្ណចំការកៅស៊ូ ហើយដីសម្បទាននីមួយៗមានទំហំពី ៣០០០ ទៅ ៥០០០ហិកតា។ ក្រុមហ៊ុនទាំងនោះ ភាគច្រើន បានសំអាតដី និងដាំដើមកៅស៊ូ។ តាមរបាយការណ៍ ELCs ទាំងអស់សុទ្ធតែមានសកម្មភាព លើកលែងតែក្រុមហ៊ុន Sarmala មួយចេញ ប៉ុន្តែ CEA បានសិក្សាជាសំខាន់តែអំពីឥទ្ធិពលជាសក្តានុពលនៃក្រុមហ៊ុន Socfin KCD និង DAKLAK ប៉ុណ្ណោះ។

***ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គមកិច្ច៖*** នៅពេលចាប់ផ្តើមដំណើរការក្នុងឆ្នាំ២០០៨ ក្រុមហ៊ុន Socfin KCD បានផ្តល់ការងារដល់ប្រជាជនប្រហែល ១០.០០០នាក់ ក្នុងនោះមានប្រហែល ២០០០នាក់ ក្នុងចន្លោះពេលពីខែឧសភា ដល់ សីហា និងប្រហែល ៨០០០នាក់ទៀត សម្រាប់ខែនានាក្រៅពីនោះក្នុងឆ្នាំនីមួយៗ។ ប្រហែល ២០-២៥% នៃកម្លាំងពលកម្មសរុប ជាប្រជាជនមូលដ្ឋាន ក្នុងនោះមាន ៦០% ជានារី។ ក្រុមហ៊ុន ត្រូវប្រើពលករយ៉ាងហោចណាស់ ១៥០០នាក់ នៅពេលដែលចំការកៅស៊ូបានដាំដុះពេញលេញ។ ពលករគ្មានជំនាញ ក៏អាចរកចំណូលបានប្រហែល ៥ដុល្លារ/ថ្ងៃដែរ។ ការងាររបស់ពួកគេ រួមមាន ការជម្រះស្មៅ និងដាក់ជី ហើយត្រូវធ្វើការពី ១០-១៥ថ្ងៃ/ខែ។ ពលករមានជំនាញ អាចរកចំណូលបានប្រហែល ៦,៥-៨ដុល្លារ/ថ្ងៃ។ បុគ្គលិកមានជំនាញទាំងអស់សុទ្ធតែជាជនចំណាកស្រុកភាគច្រើន មកពីខេត្តកំពង់ចាម និងមានបទពិសោធន៍ខាងផ្នែកកៅស៊ូ។ ពួកគេពេញចិត្តនឹងការងាររបស់ខ្លួន ទោះបីត្រូវរស់នៅឆ្ងាយពីគ្រួសារក្តី។

ការអះអាងកម្មសិទ្ធិដីត្រួតគ្នារវាងអ្នកស្រុក នឹងក្រុមហ៊ុន ឃើញមានច្រើនពាសពេញ ព្រោះអ្នកស្រុក មានទម្លាប់ផ្លាស់កន្លែងដាំដុះរបស់ខ្លួនពីកន្លែងមួយទៅកន្លែងមួយទៀត រៀងរាល់ពីរបីឆ្នាំម្តង ហើយពួកគេមិនមានប័ណ្ណបញ្ជាក់អំពីកម្មសិទ្ធិដីអ្វីទេ។ អ្នកស្រុកទាំងអស់ក្នុងឃុំប៊ូស្រា រងផលប៉ះពាល់ពីគម្រោងវិនិយោគរបស់ក្រុមហ៊ុន Socfin KCD និង DAK

LAK។ អ្នកស្រុកភ្ញាក់ផ្អើលជាខ្លាំងនៅពេលដែលក្រុមហ៊ុន Socfin KCD ចាប់សំអាតដីរបស់ពួកគេ ដោយគ្មានជូនដំណឹងជាមុន។ ទំនាស់បានផ្ទុះឡើង ហើយអ្នកស្រុកបានដុតបំផ្លាញត្រាក់ទ័ររបស់ក្រុមហ៊ុន។ គណៈកម្មាធិការដោះស្រាយទំនាស់ដីធ្លីដែលមានអភិបាលខេត្តរងជាប្រធាន និង មានអាជ្ញាធរស្រុក និងឃុំជាសមាជិក ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហា។ រដ្ឋាភិបាលមានបញ្ជីទទួលស្គាល់ ១៧២គ្រួសារបានរងការប៉ះពាល់ រីឯ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) បានអះអាងថា មាន ៤៦២គ្រួសារ ក្នុងឃុំប៊ូស្រា បានរងការប៉ះពាល់តាំងពីដំបូង ក្នុងឆ្នាំ២០០៨។ នៅទីបំផុត ក្រុមហ៊ុន បានផ្តល់ជម្រើសសំណងប៉ះប៉ូវផ្សេងៗ ដូចជា ការផ្តល់ប្រាក់ប្រហែល ២០០-២៥០ដុល្លារ/ហិកតា ការដោះដូរដី និង ការអភិវឌ្ឍ។ អ្នកស្រុកច្រើនតែជ្រើសយកសំណងជាសាច់ប្រាក់ ព្រោះដីដែលផ្តល់ជាថ្នូរ នៅឆ្ងាយពីភូមិពេក និងមិនមានជីជាតិគ្រប់គ្រាន់សម្រាប់ការដាំដុះទេ។ ពីដំបូង អ្នកស្រុកខ្លះបានជ្រើសយកជម្រើសទី៣ ប៉ុន្តែក្រោយមកបានប្តូរយកសំណងជាសាច់ប្រាក់វិញ ព្រោះនីតិវិធីយឺតយ៉ាវពេក។ ជារួម សំណងជាសាច់ប្រាក់ ជាជម្រើសល្អជាងគេ។

ផ្ទៃដីសម្បទានប្រហែល ៤០-៥០% ក្នុងគម្រោងរបស់ក្រុមហ៊ុន DAK LAK ជារបស់អ្នកស្រុក ហើយក្រុមហ៊ុនបានធ្វើការចរចាជាមុន។ ប្រហែលពាក់កណ្តាលនៃដីធ្លីរបស់អ្នកស្រុកដែលស្ថិតក្រោមដីសម្បទាន វាស្ថិតនៅជិតភូមិ ហើយងាយស្រួលសម្រាប់ការចិញ្ចឹមគោក្របី។ ក្រុមហ៊ុនបានផ្តល់ឲ្យអ្នកស្រុក នូវប្រាក់កម្ចីមានរយៈពេលសងសមរម្យដល់ទៅ ១០ឆ្នាំ ដើម្បីឲ្យពួកគេអាចដាំកៅស៊ូលើផ្ទៃដីដែលបានបែងចែកឲ្យ ហើយក្រុមហ៊ុនបានសន្យាទិញជ័រកៅស៊ូពីពួកគេក្នុងតម្លៃ ៨០% នៃថ្លៃទីផ្សារអន្តរជាតិ។ ក្រុមហ៊ុន ថែមទាំងអនុញ្ញាតឲ្យកសិករដែលគ្មានដីធ្លី ទៅដាំដំណាំនៅចន្លោះកូនដើមកៅស៊ូ នៅលើផ្ទៃដីសម្បទានរបស់ក្រុមហ៊ុន រហូតដល់ពេលដើមកៅស៊ូគ្រប់អាយុសម្រាប់ការចៀរយកជ័រទៀតផង។ អ្នកស្រុកមានការពេញចិត្តនឹង ដំណោះស្រាយរបស់ក្រុមហ៊ុន។

មុនពេលក្រុមហ៊ុនចូលមកដល់ អ្នកស្រុកក្នុងឃុំប៊ូស្រា ចិញ្ចឹមជីវិតដោយ ការធ្វើស្រែចំការនៅតំបន់ដីខ្ពស់ និងទំនាប ការប្រមូលអនុផលព្រៃឈើ ការចិញ្ចឹមសត្វ ការនេសាទ ការបរបាញ់ ការជីកមាស និង ការធ្វើអាជីវកម្មតូចតាច។ ELCs បានប៉ះពាល់ធ្ងន់ធ្ងរដល់ការដាំដុះនៅតំបន់ដីខ្ពស់ ហើយអ្នកស្រុកមួយចំនួន បានបាត់បង់ដីធ្លីដោយសារក្រុមហ៊ុនព័ទ្ធយក។ បញ្ហានេះធ្វើឲ្យជីវភាពអ្នកស្រុកលំបាកតឹងតែង ព្រោះគាត់ក៏លែងរកចំណូលបានពីការប្រមូលអនុផលព្រៃឈើដែលកាលពីមុនគាត់ធ្លាប់រកបាន ១០-១៥ដុល្លារ ពីប្រភពនោះ។ នាបច្ចុប្បន្ន អ្នកស្រុកត្រូវទៅឆ្ងាយពីផ្ទះ រកបរបាញ់សត្វ និងប្រមូលអនុផលព្រៃឈើ ដើម្បីចិញ្ចឹមជីវិត។ អ្នកខ្លះ បានបាត់បង់ទាំងចំណូលពីការចិញ្ចឹមសត្វទៀតផង ដោយសារតំបន់វាលស្មៅស្ថិតក្នុង ELCs។

***ផលប៉ះពាល់ផ្នែកបរិស្ថាន៖*** ការសិក្សានេះមិនបានរកឃើញពី ផលប៉ះពាល់ធ្ងន់ធ្ងរលើបរិស្ថាននៅមូលដ្ឋានទេ។ ទោះបីជាយ៉ាងនេះក្តី គេអាចសន្មតថា ការវិនិយោគបានបង្កជាអតុល្យភាពធម្មជាតិមួយ ដោយសារការដាំដើមកៅស៊ូទ្រង់ទ្រាយធំភ្លាមៗនេះ។ ដើមកៅស៊ូផ្ទុកជាតិកាបូន ប៉ុន្តែវាក៏ត្រូវការទឹកច្រើន ដែលអាចនាំឲ្យមានការប្រជែងប្រើប្រាស់ទឹកជាមួយសហគមន៍ជនជាតិភាគតិចនៅតាមមូលដ្ឋាន។ ការដាំកៅស៊ូ ក៏អាចនាំឲ្យបាត់បង់ជម្រកធម្មជាតិដែរ ព្រោះដីព្រៃបានប្រែក្លាយជាទ្រព្យសម្បត្តិឯកជន។

***ផលប៉ះពាល់ផ្នែកហេដ្ឋារចនាសម្ព័ន្ធ៖*** ក្រុមហ៊ុនបានស្តារជួសជុលផ្លូវថ្នល់ឡើងវិញ និងចូលរួមកសាងសាលារៀន។ តួយ៉ាង ក្រុមហ៊ុន DAK LAK បានធ្វើអំណោយនូវអាគារសិក្សាមួយខ្នងដល់សហគមន៍នៅស្រុកកោះញែក។ ប៉ុន្តែក្រោយពីក្រុមហ៊ុនចូលមកដល់ មានការត៌វ៉ាពីការខូចខាតផ្លូវថ្នល់ដែលកសាងឡើងដោយមូលនិធិរបស់សហគមន៍។

*Tan Bien (ខេត្តកំពង់ធំ)*

កាលពីខែធ្នូ ២០១០ CDRI បានចុះអង្កេតដល់កន្លែងនៅឃុំក្រយា ដោយបានជួបជាមួយសមាជិកក្រុមប្រឹក្សាឃុំម្នាក់ដើម្បីស្វែងយល់ពីផលប៉ះពាល់ជារួមនៃ ELCs ទៅលើសហគមន៍ និងបានធ្វើការប្រជុំក្រុមស្នូលមួយ (FDG) នៅភូមិថ្មសំលៀងដើម្បីពិនិត្យពីឥទ្ធិពលនៃគម្រោងវិនិយោគ។ គួរកត់សំគាល់ថា ចំនួនគម្រោងវិនិយោគឯកជន ទាំងក្នុងស្រុក និងបរទេស ក្នុងទម្រង់ជា ELCs នៅឃុំក្រយា បានកើនឡើង និងមានរបាយករណ៍ជាច្រើនពីវិវាទរវាងក្រុមហ៊ុនវៀតណាម

ដូចជា Tam Bien Investment និង Phuck Fa Investment (Phuck Fa កាលពីមុនមានឈ្មោះថា Mean Rithy Investment ជារបស់វិនិយោគិនកម្ពុជាម្នាក់) ហើយនិងសហគមន៍មូលដ្ឋាននានា។

មុខរបរចម្បង នៅឃុំក្រយា គឺដាំស្រូវ ដំឡូងឈើ និងប្រមូលអនុផលព្រៃឈើ។ អ្នកភូមិអះអាងថា ចំណូលបានពីដំណាំស្រូវមិនគ្រប់គ្រាន់ទេ ហើយត្រូវរកចំណូលបន្ថែមទៀតតាមការទៅរកជ័រ បោចវល្លិ៍ ឬលក់ពលកម្មស៊ីប្រាក់ថ្ងៃទៅធ្វើស្រែឬធ្វើចំការឲ្យគេ។ អ្នកខ្លះទៅរកចាប់សត្វប្រមាដែលមានតម្រូវការច្រើនសម្រាប់យកធ្វើឱសថបុរាណ។ អ្នកខ្លះយកប្រាក់ចំណូលបានពីការលក់អនុផលព្រៃឈើទៅទិញជី ដើម្បីលើកគុណភាពដីដែលមិនសូវមានជីជាតិ និងបង្កើនទិន្នផលស្រូវ (ទិន្នផលមធ្យម ២តោន/ហិកតា)។ ដោយសារតម្រូវការទីផ្សារក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ប្រជាជនក្នុងភូមិប្រហែលពាក់កណ្តាល បានសម្រេចចិត្តរានយកដីព្រៃរបស់រដ្ឋដើម្បីដាំដំឡូងឈើដែលអាចផ្តល់ចំណូលបានប្រហែល ៣០០.០០០រៀល/តោន (ប្រហែល ៧៣ដុល្លារ) ហើយអ្នកភូមិឯទៀតបានដាំស្វាយចន្ទី ឬខ្នុរ។ ដោយដឹងពីការលំបាករបស់អ្នកភូមិ ក្រុមប្រឹក្សាឃុំក៏បានបិទភ្នែកចំពោះការកាប់រានព្រៃនេះ។

***ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គមកិច្ច៖*** នៅពេលចាប់ដំណើរការ ក្រុមហ៊ុន Tan Bien បានបង្កើតការងារច្រើនគួរសម (គ្មានការបញ្ជាក់ទិន្នន័យពីក្រុមប្រឹក្សាឃុំទេ) ជាពិសេសបានជួលប្រើប្រជាជនក្នុងឃុំច្រើននាក់ណាស់ក្នុងការងារជម្រះស្មៅ ជីកដី បាញ់ថ្នាំសម្លាប់សត្វចង្រៃ និងស្រោចទឹក ដោយផ្តល់ប្រាក់ឈ្នួលជាមធ្យម ១២.០០០-១៣០០០រៀល/ថ្ងៃ (ប្រហែល ៣-៣,៥ដុល្លារ)។ ប៉ុន្តែអ្នកភូមិភាគជាច្រើនបានឈប់ធ្វើការវិញដោយអះអាងថា លំបាកពេកទ្រាំទ្រមិនបាន។ បញ្ហាចោទមានតាំងពី កង្វះជំនាញថែទាំកូនកៅស៊ូ និងបាញ់ថ្នាំសម្លាប់សត្វចង្រៃ រហូតដល់ការខ្លែងបន្លំក្នុងការបើកប្រាក់កម្រៃ។ ជាដំណោះស្រាយ ក្រុមហ៊ុនបានប្រមូលយកពលករពីឃុំជិតខាង និងពីខេត្តផ្សេង (ភាគច្រើនពី កំពង់ចាម) ពីព្រោះអ្នកនៅទីនោះធ្លាប់ឆ្លងកាត់ច្រើនជាងក្នុងការថែកូនកៅស៊ូ និងដើមកៅស៊ូ ។

ផលប៉ះពាល់មួយទៀត គឺ ការបាត់បង់ប្រភពចំណូលជាប្រពៃណី ជាពិសេស ការរកជ័រ និងបោចវល្លិ ដោយសារក្រុមហ៊ុនបានឈូសព្រៃក្នុងឃុំអស់ហើយ។ គ្រួសារជាច្រើនក៏បានបាត់បង់ ចំការដំឡូងឈើដែលខ្លួនបានរានយកដោយខុសច្បាប់ពីដីព្រៃរបស់រដ្ឋ ហើយឥឡូវស្ថិតក្នុង ELCs។ ដូចបានបញ្ជាក់នៅខាងលើ ការកាប់រាននេះកើតមានឡើងពីដំបូងដោយសារក្រុមប្រឹក្សាឃុំបានបិទភ្នែក។ សរុបមក គម្រោង ELCs នេះ បានប៉ះពាល់ពីរយ៉ាង ដល់គ្រួសារនានា គឺ បាត់បង់ប្រភពចំណូលផង និង គ្មានទទួលបានឱកាសការងារឬរៀនជំនាញទេ។

ដើម្បីជាសំណងប៉ះប៉ូវដល់ការបាត់បង់ដីធ្លី ក្រុមហ៊ុនបានផ្តល់ឲ្យគ្រួសារប្រជាជននូវប្រាក់ ២០០ដុល្លារសម្រាប់ដីរានហើយនិងមានដំណាំមួយហិកតា និង ១០០ដុល្លារសម្រាប់ដីរានហើយតែគ្មានដំណាំមួយហិកតា។ ចំណុចគួរកត់សំគាល់មួយក្នុងការដោះស្រាយវិវាទ រវាងក្រុមហ៊ុន និងអ្នកភូមិ គឺថ្វីបើតំណាងក្រុមហ៊ុនបានយល់ព្រមធ្វើតាមសំណើរបស់អ្នកសម្របសម្រួលខាងឃុំក្តី ក៏ក្នុងការអនុវត្តជាក់ស្តែងក្រុមហ៊ុនបានក្បត់ការសន្យា។ ឧទាហរណ៍ ក្រុមហ៊ុនបានយល់ព្រមមិនប៉ះពាល់ ឬបង្វែរជ្រោះ/អូរទេទោះតូចក្តីធំក្តី ដែលសម្រាប់ឲ្យសត្វផឹក និងប្រើកសិកម្មផ្សេងៗ ប៉ុន្តែក្រោយមកបានចាក់ដីបំពេញអស់ ដោយគ្មានឃើញប្រឹងធ្វើតាមការសន្យាទេ។ ខាងក្រុមប្រឹក្សាឃុំ មិនសូវមានអំណាចលើក្រុមហ៊ុនទេព្រោះគេបានការអនុញ្ញាតឲ្យធ្វើសកម្មភាពពីអាជ្ញាធរកម្រិតខេត្ត។ សព្វថ្ងៃនេះ បើសិនអ្នកភូមិនៅតែលែងសត្វឲ្យដើរចូលដីចំការក្រុមហ៊ុន ពួកឆ្មាំនឹងចាប់វាទុក ហើយអ្នកភូមិត្រូវបង់ប្រាក់ពិន័យ ១០០.០០០រៀល (ប្រហែល ២៥ដុល្លារ) ទើបអាចលោះវាយកទៅវិញ។

***ផលប៉ះពាល់ផ្នែកបរិស្ថាន៖*** ពុំមានភស្តុតាងអ្វីបង្ហាញពីការប្រជែងប្រើប្រាស់ទឹករវាងក្រុមហ៊ុន នឹងអ្នកភូមិថ្មសំលៀងទេ។ ស្រូវ ដំឡូងឈើ និងដំណាំឯទៀតរបស់អ្នកភូមិ ពឹងផ្អែកលើទឹកភ្លៀង ចំណែកឯខាងក្រុមហ៊ុនបានជីកអាងទឹករបស់គេមួយសម្រាប់ស្រោចកូនកៅស៊ូ។ អ្នកភូមិក៏ពុំឃើញមានត៉វ៉ាពី ការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃលើសកម្រិតធ្វើឲ្យខូចគុណភាពដីនិងបំពុលទឹកក្នុងដី ឬក៏ការខាតបង់ដោយសារលែងបានប្រមូលផលពីព្រៃឈើនៅជុំវិញភូមិ និងនៅក្នុងឃុំនោះទេ។ ប៉ុន្តែរឿងនេះអាចមកពី អ្នកភូមិមានការយល់ដឹងតិចតួចពីផលប៉ះពាល់ពីចំការកៅស៊ូទៅលើបរិស្ថាន។

***ផលប៉ះពាល់ផ្នែកហេដ្ឋារចនាសម្ព័ន្ធ៖*** ក្រុមហ៊ុនបានកសាងផ្លូវថ្នល់តភ្ជាប់ដីរបស់ខ្លួន ទៅដល់កណ្តាលឃុំ។ ថ្វីបើខាងក្រុមហ៊ុនបានធ្វើផ្លូវទាំងនេះសម្រាប់បម្រើអាជីវកម្មរបស់គេក្តី ក៏ប្រជាជននៅភូមិថ្មសំលៀងដែលនៅជិតដីរបស់ក្រុមហ៊ុន បានទទួលអត្ថប្រយោជន៍ដែរ។ ប៉ុន្តែពុំមានភស្តុតាងអ្វីបង្ហាញថា ក្រុមហ៊ុនបានចូលរួមក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន ដូចជា មន្ទីរពេទ្យ សាលារៀន ប្រព័ន្ធធារាសាស្ត្រ ជាដើមនោះទេ។

***គំរូអាជីវកម្ម៖*** ក្រុមហ៊ុនមិនបានអនុវត្តគំរូអាជីវកម្មអ្វីឲ្យច្បាស់លាស់ ឬជាផ្លូវការទេ និងបានរានព្រៃ និងរឹបយកដីចំការរបស់គ្រួសារនានា ប៉ុន្តែបានផ្តល់ការងារក្នុងចំការកៅស៊ូដល់អ្នកភូមិ ទោះបីមានលក្ខណៈមិនទៀងទាត់ក្តី។

### ***៥.១.៣. ចំការពោតនៅខេត្តកំពង់ស្ពឺ***

*ក្រុមហ៊ុន HLH Agriculture*

ក្រុមហ៊ុន HLH Group Limited ដែលជាកម្មសិទ្ធិសិង្ហបុរី ១០០% និងមានចុះបញ្ជីនៅថ្ងៃទី ២១ មិថុនា ២០០០ នៅលើ SGX Mainboard ធ្វើអាជីវកម្មផ្នែកកសិកម្ម អចលនទ្រព្យនិងវិនិយោគ សំណង់ ការស្រាវជ្រាវនិងអភិវឌ្ឍន៍ខាងធ្វើកសិកម្ម។ ក្រុមហ៊ុនបានដាក់ពាក្យសុំធ្វើវិនិយោគនៅកម្ពុជា និងបានទទួលការយល់ព្រមក្នុងឆ្នាំ២០០៧ ហើយបានចាប់ផ្តើមធ្វើចំការពោតនៅឆ្នាំ២០០៩ លើដី ៩៨០០ហិកតានៅស្រុកឱរ៉ាល់ និង ៤៥០០០ហិកតានៅស្រុកថ្ពង (ឃុំអមលាំង) ខេត្តកំពង់ស្ពឺ(៤៨ គ.ម ពីក្រុងភ្នំពេញ)។

ក្រុមហ៊ុនមានកិច្ចសន្យាជួលរយៈពេល ៧០ឆ្នាំ លើដីសម្បទានខាងលើ។ ដោយមានមូលធនវិនិយោគប្រហែល ៤៥លានដុល្លារ ក្រុមហ៊ុនបាននាំចូលគ្រឿងម៉ាស៊ីនប្រើបច្ចេកទេសខ្ពស់មកពីសិង្ហបុរី បានដំឡើងរោងចក្រកែច្នៃមួយមានសមត្ថភាពផលិតកម្មប្រហែល ៦០០តោន/ថ្ងៃ និងមានចំការបួន ទំហំពី ៤៥០ទៅ ២០០០ហិកតា។

គ្រប់កសិដ្ឋានស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកត្រួតពិនិត្យមកពី ហ្វីលីពីន តៃវ៉ាន់ សិង្ហបុរី ចិន និង មីយ៉ាន់ម៉ា ដែលមានរបៀបគ្រប់គ្រងខុសៗគ្នា។ អ្នកត្រួតពិនិត្យជំនួយការទាំងអស់ជាជនកម្ពុជា ហើយត្រូវទទួលការងារគ្រប់គ្រងបន្តពីគេ នៅពេលទទួលបានជំនាញ និងបទពិសោធន៍គ្រប់គ្រាន់ហើយ។ ក្រុមហ៊ុនមានបុគ្គលិកពេញម៉ោងទាំងអស់ ៤៥០នាក់ ក្នុងនេះបុគ្គលិកការិយាល័យមាន ៣០នាក់ដែលមានពីរនាក់មកពីសិង្ហបុរី។ កម្មករធ្វើការក្នុងចំការមានប្រហែល ២០០នាក់នៅរដូវមិនសូវមមាញឹក និង១០០០នាក់នៅរដូវរវល់ខ្លាំង និងសុទ្ធតែជាប្រជាជនកម្ពុជា។

***ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គមកិច្ច៖*** នៅពេលចាប់ដំណើរការនៅឆ្នាំ២០០៧ ក្រុមហ៊ុនបង្កើតការងារបានច្រើនគួរសមដោយផ្តល់ប្រាក់កម្រៃប្រចាំថ្ងៃពី ១០.០០០ ដល់ ១២.០០០រៀល (ប្រហែល ២,៥ ទៅ ៣ដុល្លារ) ប៉ុន្តែអ្នកភូមិត្រូវចំណាយអស់ប្រហែល ១០០០រៀល/ថ្ងៃ លើការដឹកជញ្ជូនទៅមកកន្លែងចំការ។ ថ្មីៗនេះ ចំនួនកម្មករធ្វើការបានថយចុះជាខ្លាំង ដោយសារក្រុមហ៊ុនបាននាំចូលគ្រឿងម៉ាស៊ីន (ឧ. ម៉ាស៊ីនសាបព្រួស ម៉ាស៊ីនប្រមូលផល) មកជំនួសពួកកម្មករប្រើកម្លាំង។ មធ្យោបាយនេះបានកាត់បន្ថយឱកាសរកបានប្រភពចំណូលថ្មីរបស់អ្នកភូមិ។ ខាងក្រុមហ៊ុនបានអះអាងថា ខ្លួនមិនអាចអនុវត្តគំរូអាជីវកម្មអ្វីបានទេ ពីព្រោះកសិករគ្មានលទ្ធភាពទិញគ្រាប់ពូជ និងគ្រឿងម៉ាស៊ីន និងខ្វះខាតបច្ចេកទេសសមស្របសម្រាប់ដាំពោត។

ក្នុងពេលជាមួយគ្នា ក្រុមហ៊ុន HLH Agriculture បានទាមទារយកប្រហែល ៤០% នៃដីស្រែ និងដីរានព្រៃហើយរបស់អ្នកភូមិ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រភពចំណូលចម្បង និងជាប្រពៃណីរបស់អ្នកភូមិ ពោលគឺ ធ្វើស្រែ និងផលិតធ្យូង។ ក្រុមហ៊ុនវិនិយោគឯកជនដ៏ធំមួយទៀតគឺ Kompong Speu Sugar របស់អ្នកឧកញ៉ា លី យ៉ុងផាត់ (ជាម្ចាស់ក្រុមហ៊ុន Koh Kong Sugarcane ដែលមានរៀបរាប់លំអិតនៅខាងលើ) ក៏បានប៉ះពាល់ដល់ប្រហែល ៩០% នៃដីស្រែរបស់អ្នកភូមិដែរ។

កន្លងមកការដោះស្រាយវិវាទលំបាកជាខ្លាំង ដោយសារអ្នកភូមិគ្មានលិខិតស្នាមបញ្ជាក់កម្មសិទ្ធិលើដីធ្លីដែលពួកគាត់ធ្លាប់ដាំដុះតាំងពីដើមមក។ ក្រុមហ៊ុនបានអះអាងថា គ្មានបញ្ហាអ្វីធំដុំជាមួយសហគមន៍មូលដ្ឋានទេ ពីព្រោះខ្លួន

បានធ្វើការតាមរបៀបពិគ្រោះគ្នា ដោយបានអញ្ជើញប្រជាជនមូលដ្ឋាន អាជ្ញាធរ និងអង្គភាពពាក់ព័ន្ធនានាមកជួបជុំគ្នាស្វែងរកដំណោះស្រាយលើបញ្ហាដែលផុសឡើង។ ក្រុមហ៊ុនបានសន្យាផ្តល់សំណងប៉ះប៉ូវដល់ប្រជាជនតាមការផ្តល់ដីថ្មីឲ្យវិញ ប៉ុន្តែដីទាំងនោះនៅឆ្ងាយពីភូមិខ្លាំងណាស់ មានតែប្រជាជនមួយចំនួនតូចទេដែលបានយល់ព្រម។ ចំពោះសំណងប៉ះប៉ូវជាប្រាក់វិញ អ្នកភូមិប្រាប់ថា ក្រុមហ៊ុនបានសន្យាផ្តល់ឲ្យគ្រួសារនីមួយៗពី ១០០០ ទៅ ២០០០ដុល្លារ/ហិកតា ប៉ុន្តែប្រាក់នេះគេមិនទាន់ឃើញនៅឡើយទេ។

ដោយសារកង្វះប្រព័ន្ធស្រោចស្រព គេអាចធ្វើស្រែតែនៅរដូវវស្សាប៉ុណ្ណោះ។ ដូច្នេះអ្នកភូមិភាគច្រើនបានផលិតធ្យូងថែមទៀត ដោយត្រូវចូលព្រៃទៅកាប់យកដើមឈើតូចៗ។ គ្រួសារនីមួយៗមានឡធ្យូងពី ពីរ ទៅ បួន ជាមធ្យម ដោយឡតូចមួយអាចកែច្នៃឈើបានប្រហែល ៥ ម៣ ក្នុងរយៈ ១៥ថ្ងៃ និងផ្តល់ជាចំណូលបានប្រហែល ៣៥០.០០០រៀល (ប្រហែល ៨៥ដុល្លារ) ហើយ ឡធំមួយអាចកែច្នៃឈើបានប្រហែល ១០ ម៣ ក្នុងរយៈ ២០-២៥ថ្ងៃ និងផ្តល់ចំណូលបានប្រហែល ៧០០.០០០រៀល (ប្រហែល ១៧០ដុល្លារ)។ ប៉ុន្តែអ្នកភូមិផលិតធ្យូងលែងបានទៀតហើយ ពីព្រោះព្រៃនៅជិតភូមិគេកាប់រានអស់ ហើយក្រុមហ៊ុនមិនអនុញ្ញាតឲ្យអ្នកភូមិចូលក្នុងព្រំដែនដីរបស់គេទេ។ ឥឡូវនេះដើម្បីបានឈើ អ្នកភូមិត្រូវចូលទៅក្នុងព្រៃជ្រៅ តែភាគច្រើនមិនចង់ទៅទេ។ តាំងពីក្រុមហ៊ុនចូលមកដល់ អ្នកភូមិមើលឃើញជីវភាពរបស់ខ្លួនខ្មៅងងឹតទៅអនាគត ហើយអ្នកខ្លះឈប់ពីការងារក្នុងចំការក្រុមហ៊ុនហើយ។ ទន្ទឹមគ្នានេះ ក្រុមហ៊ុនបានទាមទារយកដីព្រៃដែលបានរានហើយតាំងពីមុនពេលក្រុមហ៊ុនមកដល់ថែមទៀត។

***ផលប៉ះពាល់ផ្នែកបរិស្ថាន៖*** គម្របព្រៃបានថយចុះ ព្រោះមានការកាប់រានយកដីកាន់តែច្រើន។ បញ្ហានេះអាចមានផលប៉ះពាល់អាក្រក់លើប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះក្នុងតំបន់។ ប្រជាជនក្នុងភូមិមានការបារម្ភជាខ្លាំងពីការខូចខាតបរិស្ថាននេះ។

***ផលប៉ះពាល់ផ្នែកហេដ្ឋារចនាសម្ព័ន្ធ៖*** ការប្រជុំ FDG បានបង្ហាញថា កន្លងមកក្រុមហ៊ុន HLH Agriculture និង Kompong Speu Sugar បានកសាងហេដ្ឋារចនាសម្ព័ន្ធតិចតួចណាស់។ ផ្លូវថ្នល់ និងស្ពានខ្លះៗដែលក្រុមហ៊ុនបានកសាង គឺ សម្រាប់ក្រុមហ៊ុនប្រើប្រាស់ប៉ុណ្ណោះ ហើយផ្លូវថ្នល់ភាគច្រើន គឺ រដ្ឋាភិបាលបានកសាងវាឡើង។

## ៥.២. ព្រៃឈើនៅខេត្តក្រចេះ

*ក្រុមហ៊ុន Tong Ming Group Engineering និង ELCs ប្រាំបីផ្សេងទៀត*

មាន ELCs ចំនួនប្រាំបីនៅឃុំក្បាលដំរី ដូចមានបញ្ជាក់ក្នុងបទសម្ភាសន៍ជាមួយជំទប់ទី២ ក្នុងខែមេសា ២០០១។ តារាង ១១ បង្ហាញពី ការបែងចែកគម្រោងតាមសញ្ជាតិ។ គួរកត់សំគាល់ជាសំខាន់ថា លទ្ធផលនៃការវាយតម្លៃជាដំបូងៗពីផលប៉ះពាល់នេះ បានមកពីការពិនិត្យស្រាវជ្រាវលើគម្រោងវិនិយោគមួយរបស់ក្រុមហ៊ុន Tong Ming Group Engineering នៅដើមឆ្នាំ២០១០ ដូច្នេះ មិនអាចឆ្លុះបញ្ចាំងពីផលប៉ះពាល់ពេញលេញ ឬទូទាំងឃុំ នៃគម្រោងវិនិយោគទាំងអស់ដូចមានរៀបរាប់ក្នុង តារាង ១១ នេះទេ។

តារាង ១១៖ លក្ខណៈនៃ ELCs នៅឃុំក្បាលដំរី ស្រុកសំឡូត ខេត្តក្រចេះ

| លេខរៀង | ក្រុមហ៊ុន | ឆ្នាំអនុម័ត | រយៈពេលនៃកិច្ចសន្យា | ទំហំ (ហ.ត) | គោលដៅនៃវិនិយោគ | សញ្ជាតិ |
|---|---|---|---|---|---|---|
| 1 | Great Island Agricultural Development Co., Ltd | 2006 | 70 ឆ្នាំ | 9583 | ចំការម៉ៃសាក់ និងរោងចក្រកែច្នៃ | សហរដ្ឋអាមេរិក |
| 2 | Global Agricultural Development Co., Ltd | 2006 | 70 ឆ្នាំ | 9800 | ចំការម៉ៃសាក់ និងរោងចក្រកែច្នៃ | សហរដ្ឋអាមេរិក |
| 3 | Asia World Agricultural Development Co., Ltd | 2006 | 70 ឆ្នាំ | 10000 | ចំការម៉ៃសាក់ និងរោងចក្រកែច្នៃ | ចិន |
| 4 | Great Asset Agricultural Development Co., Ltd | 2006 | 70 ឆ្នាំ | 8985 | ចំការ Pistacia Chinasis Bunge និងដើមឈើផ្សេងទៀត | ចិន |
| 5 | Great Wonder Agricultural Development | 2006 | 70 ឆ្នាំ | 8231 | ចំការ Pistacia Chinasis Bunge និងដើមឈើផ្សេងទៀត | ចិន |
| 6 | Tong Ming Group Engineering | 2007 | 70 ឆ្នាំ | 7465 | ចំការកៅស៊ូ អាកាស្យា ល្ហុងខ្វង និងរោងចក្រកែច្នៃ | ចិន |
| 7 | Agri-industrial Crops Development | 2008 | 70 ឆ្នាំ | 7000 | ចំការកៅស៊ូ និងអាកាស្យា | ចិន |
| 8 | Carmadeno Venture Limited | 2009 | 70 ឆ្នាំ | 7635 | ចំការអំពៅ | ឥណ្ឌា |

ប្រភព៖ បទសម្ភាសន៍ជាមួយជំទប់នៃឃុំក្បាលដំរី ខែមេសា ២០១១; MAFF ELC profiles 2011 ( http://www.elc.maff.gov.kh/profiles.html )

***ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គមកិច្ច៖*** ការប្រាស្រ័យទាក់ទងរវាងអ្នកភូមិ ក្រុមហ៊ុន និងអាជ្ញាធរ មានលក្ខណៈទន់ខ្សោយ។ ក្នុងករណីខ្លះ អ្នកភូមិបានភ្ញាក់ផ្អើលជាខ្លាំងនៅពេលឃើញក្រុមហ៊ុនមករានដីនៅជិតៗក្រោយផ្ទះរបស់ខ្លួន។ កន្លងមកមានវិវាទជាច្រើន រវាងសហគមន៍មូលដ្ឋាន និងក្រុមហ៊ុន លើការរំលោភយកដី និងការហាមឃាត់មិនឲ្យចូលព្រៃ។ ឥឡូវនេះអ្នកភូមិលែងអាចទៅប្រមូលវល្លិ ជ័រឈើ ផ្តៅ ឬស្សី ឬក៏ទៅបរបាញ់ក្នុងព្រៃទៀតហើយ ពោលគឺបានបាត់បង់ប្រភពចំណូលចម្បងរបស់ខ្លួន។ ចំការព្រៃឈើមានឆ្មាំប្រដាប់អាវុធនៅការពារ ហើយបើសិនគេឃើញអ្នកភូមិចូលទៅក្នុងនោះ គេចាប់រូបគាត់ ធ្វើការផាកពិន័យ រឹបអូសយករបស់ទ្រព្យគាត់។

ទន្ទឹមគ្នានោះ អ្នកភូមិក៏លែងចង់ធ្វើការក្នុងក្រុមហ៊ុនចិនទៀតដែរ ដោយសារលក្ខខណ្ឌការងារតឹងតែង ( ឧ. កាត់ប្រាក់ខែបើសិនឈប់ធ្វើការមួយថ្ងៃ មិនអនុញ្ញាតឲ្យពលករទៅផ្ទះទេបើសិនចាំបាច់ត្រូវធ្វើការបន្ថែមម៉ោង ) និងសកម្មភាពក្រុមហ៊ុនរំលោភយកដីធ្លី។ ពលករភាគច្រើនមកពីខេត្តព្រៃវែង និង ស្វាយរៀង។

***ផលប៉ះពាល់ផ្នែកបរិស្ថាន៖*** ក្រុមស្រាវជ្រាវបានសង្កេតឃើញថា ក្រុមហ៊ុនបានប្រើគ្រឿងចក្រធុនធ្ងន់ដើម្បីរានព្រៃ ហើយជារឿយៗបានរំលោភបទបញ្ញត្តិដែលតម្រូវឲ្យក្រុមហ៊ុនរក្សាទុក ព្រៃទទឹង ២០០ម នៅម្ខាងៗនៃអូរធំៗ ( ទទឹង ២០-៣០ ម ) និង ព្រៃទទឹង ១០០ ម នៅម្ខាងៗនៃអូរតូចជាងនោះ ដើម្បីធានានិរន្តរភាពនៃការប្រើប្រាស់ទឹក និងការការពារបរិស្ថាន។ ក្នុងការអនុវត្តជាក់ស្តែង ក្រុមហ៊ុនបានទុកតែព្រៃ ១០ ម ប៉ុណ្ណោះនៅម្ខាងៗនៃអូរ។ អ្នកភូមិក៏លើកដែរថា ជារឿយៗមានឈើដឹកចេញនៅពេលយប់ទៅវៀតណាម។

***ផលប៉ះពាល់ផ្នែកហេដ្ឋារចនាសម្ព័ន្ធ៖*** ឃើញមានការកសាងផ្លូវជាក់ស្តែង ប៉ុន្តែគ្មានការកសាងអាគារសិក្សា ឬវត្តទេ។ ផ្លូវថ្មីៗក្រុមហ៊ុនបានកសាងសម្រាប់ការប្រើប្រាស់របស់ខ្លួនជាសំខាន់ មិនមែនសម្រាប់សាធារណជនទេដែលគេហាមឃាត់មិនឲ្យចូលទៅក្នុងបរិវេណដីរបស់ក្រុមហ៊ុននោះទេ។

## ៥.៣. ការវាយតម្លៃជារួម

ដោយផ្អែកលើការពិនិត្យអង្កេតរបស់ក្រុមស្រាវជ្រាវ ជារួមបន្ទុកចំណាយរបស់គម្រោង FDI ហាក់ដូចធំជាងអត្ថប្រយោជន៍ ប៉ុន្តែធំជាងប៉ុណ្ណាៗគេពិបាកធ្វើការប៉ាន់ស្មាន។ គម្រោង FDI មានទាំងឥទ្ធិពលវិជ្ជមាន និងអវិជ្ជមាន។ គម្រោងខ្លះបានបង្កើតការងារច្រើនគួរសមសម្រាប់សហគមន៍មូលដ្ឋាន និងប្រជាជននៅខេត្តជិតខាង ប៉ុន្តែគម្រោងឯទៀតគ្មានបង្កើតអ្វីទេ។ ទន្ទឹមគ្នានោះ វិវាទដីធ្លីឃើញមានពាសពេញក្នុងគម្រោង ELC ដោយសារការកាន់កាប់ដីពុំមានសុវត្ថិភាព និងកង្វះការពិគ្រោះជាមួយសហគមន៍មូលដ្ឋានមុនពេលអនុម័តលើ ELCs។ ម្យ៉ាងទៀត គម្រោង ELC ខ្លះមានការរានដីព្រៃ ដែលបានបំបាត់ប្រភពចំណូលចម្បងរបស់សហគមន៍ ដូចជា ការប្រមូលអនុផលព្រៃឈើ និងការបរបាញ់។ ការចាក់ដីបំពេញជ្រោះអូរនៅក្នុងគម្រោងខ្លះ អាចនាំឲ្យមានកង្វះខាតទឹក។

ក្នុងមួយទសវត្សរ៍កន្លងទៅ កម្ពុជាពុំមានជួបឱនភាពស្បៀងទេ។ ផលិតកម្មស្រូវ និងផ្ទៃដីដាំស្រូវសរុប បានរីកចម្រើនឡើងដោយមានអត្រាកំណើនជាមធ្យម ៩,៤% និង ២,៧% ក្នុងចន្លោះពេលពីឆ្នាំ២០០៤ ដល់ ២០០៩។ នៅឆ្នាំ២០០៩ ផ្ទៃដីដាំស្រូវសរុបឡើងដល់ជាង ២,៧ លានហិកតា ដែលផ្តល់ផលស្រូវបាន ៧,៦ លានតោន និងអតិរេកស្រូវ ៣,៥ លានតោន (តារាង ១១)។ ដូច្នេះបើមើលមួយភ្លែត កម្ពុជាហាក់ដូចគ្មានត្រូវបារម្ភអ្វីធ្ងន់ធ្ងរពីរឿងសន្តិសុខស្បៀងក្នុងរយៈពេលខ្លី និងមធ្យមនោះទេ។ ដោយឡែក កំណើនយ៉ាងខ្លាំងក្នុងចំនួនសរុប និងទំហំនៃគម្រោង ELC ហាក់ដូចមិនទំនងគំរាមកំហែងដល់សន្តិសុខស្បៀងរបស់ជាតិក្នុងរយៈពេលមធ្យមបានទេ ពីព្រោះកំណើនយ៉ាងទៀងទាត់នាបច្ចុប្បន្ននៃផ្ទៃដីដាំស្រូវ នឹងបន្តផ្តល់អតិរេកស្រូវសម្រាប់ការប្រើប្រាស់ក្នុងស្រុកនៅក្នុងរយៈពេលខ្លី និងមធ្យម។ ដូចគ្នាដែរ ការពង្រីក ELC ហាក់ដូចមិនប្រជែងប្រើប្រាស់ទឹក ជាមួយនឹងដំណាំស្រូវទេ។ ប៉ុន្តែក្នុងរយៈពេលវែង ការប្រជែងគ្នាប្រើប្រាស់ទឹក និងដី វាអាចប៉ះពាល់ដល់សន្តិសុខស្បៀងកម្រិតជាតិ ប្រសិនបើគម្រោង ELCs នៅតែកើនឡើងក្នុងល្បឿនដូចសព្វថ្ងៃ។

តារាង ១២៖ កំណើនផ្ទៃដីដាំស្រូវ និងទំហំដី ELC ឆ្នាំ២០០៤-២០០៩

| ប្រភេទ | 2004 | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|---|
| ផ្ទៃដីដាំស្រូវ (ហិកតា) | 2374175 | 2443530 | 2541433 | 2585905 | 2615741 | 2719080 |
| ការពង្រីកផ្ទៃដីដាំស្រូវ (%) | 2.6 | 2.9 | 4.0 | 1.7 | 1.2 | 4.0 |
| ផលិតកម្មស្រូវ (តោន) | 4170284 | 5986179 | 6264123 | 6727127 | 7175473 | 7585870 |
| កំណើនផលិតកម្មស្រូវ (%) | -11.5 | 43.5 | 4.6 | 7.4 | 6.7 | 5.7 |
| អតិរេកស្រូវ (តោន) | 650184 | 2061830 | 2240438 | 2577562 | 3164114 | 3507185 |
| អតិរេកអង្ករ (តោន) | 416118 | 1319571 | 1433880 | 1649640 | 2025033 | 2244598 |
| | | | | | | |
| ELCs បូកបង្គរទុក (ហិកតា) (សរុប) | 583273 | 650316 | 818572 | 847573 | 888509 | 1024639 |
| ការពង្រីក ELC (%) | 1.1 | 11.5 | 25.9 | 3.5 | 4.8 | 15.3 |
| ELCs បូកបង្គរទុក (ហិកតា) (FDI) | 73100 | 97480 | 188499 | 217500 | 258436 | 355914 |

ប្រភព: MAFF (2010)

កំណើនតម្រូវការក្នុងពិភពលោកនូវស្បៀង (អង្ករ) និង ដំណាំឧស្សាហកម្មដូចជា កៅស៊ូ ដំឡូងឈើ និងអំពៅសម្រាប់ផលិតថាមពលជីវឥន្ធនៈអាចធ្វើឲ្យកម្ពុជាស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់បើសិនគោលនយោបាយខាងពាណិជ្ជកម្ម និងវិនិយោគរបស់កម្ពុជា មិនបានគិតគូរខ្លាំងដល់បញ្ហាសន្តិសុខស្បៀងទេ។ ក្នុងរយៈពេលវែង វិវាទលើការប្រើប្រាស់ដីរវាងអ្នកភូមិ នឹង ELCs ដែលផលិតស្រូវអង្ករ និងដំណាំឧស្សាហកម្មសម្រាប់នាំចេញ ការប្រជែងគ្នាតឹងតែងដណ្តើមទឹកដែលសព្វថ្ងៃគេប្រើក្នុងការដាំស្រូវ និងការបាត់បង់ប្រភពចំណូលជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន អាចនាំឲ្យថយចុះដល់ការហូបចុកស្បៀងអាហារក្នុងគ្រួសារ និងកាត់បន្ថយកម្រិតអាហារូបត្ថម្ភ។

# ៦
# សេចក្តីសន្និដ្ឋាន

កន្លងមក កសិកម្មបានរួមចំណែកយ៉ាងទៀងទាត់ដល់សេដ្ឋកិច្ចជាតិ ដោយផ្តល់ការងារដល់កម្លាំងពលកម្មមួយភាគធំនៅតំបន់ជនបទ និងបង្កើតប្រាក់ចំណូលជារូបិយប័ណ្ណបានយ៉ាងច្រើន។ ក្នុងអាណត្តិទី៤ រដ្ឋាភិបាលកម្ពុជាបានផ្តោតកាន់តែខ្លាំងឡើងលើការលើកកម្ពស់វិស័យកសិកម្ម ដោយបានបន្ធូរបន្ថយពន្ធលើផលិតផលកសិកម្ម និងធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ជនបទ ដូចជា ផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ ជាដើម និងបានអនុវត្តវិធានការថ្មីៗដើម្បីជួយដល់សហគមន៍មូលដ្ឋាន រួមទាំងការបើកឲ្យប្រជាជនប្រើប្រាស់ឡូត៍នៃសាទខ្នាតធំមួយចំនួន ដែលធ្លាប់តែស្ថិតក្រោមការគ្រប់គ្រងរបស់ឯកជន ។

ម៉្យាងទៀត រដ្ឋាភិបាលបានធ្វើកំណែទម្រង់ព្រៃឈើ ដើម្បីផ្តល់ជួយសម្រួលដល់វិនិយោគខាងផ្នែកព្រៃឈើ និងដំណាំ តាមរយៈការបង្កើតច្បាប់ស្តីពីសម្បទាន ការបង្កើតសហគមន៍ព្រៃឈើ និងការការពារបរិស្ថាន។ នៅឆ្នាំ២០០៥ រដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ដើម្បីជួយសម្រួលការផ្តល់ដីសម្បទានដល់វិនិយោគិនក្នុងស្រុក និងបរទេស ដើម្បីឲ្យធ្វើអាជីវកម្មលើដីធ្លីមិនប្រើប្រាស់ និង/ឬ ដីគ្មានជីជាតិ។

ច្បាប់ទាក់ទងនឹងបញ្ហាអនាម័យ ភូតគាមអនាម័យ និងសុខភាពសត្វ បានអនុម័តចេញ ដើម្បីគ្រប់គ្រងលើផលិតកម្មសត្វចិញ្ចឹម ព្រមទាំងទប់ស្កាត់ការបាត់បង់ និងការឆ្លងជំងឺសត្វ។ នាពេលថ្មីៗនេះ រដ្ឋាភិបាលតាមរយៈ MAFF បានហាមឃាត់ការនាំចូលសត្វចិញ្ចឹមពីប្រទេសជិតខាង ដើម្បីទប់ស្កាត់ជំងឺផ្តាសាយជ្រូក និងកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺសត្វ។

រដ្ឋាភិបាល ដោយមានជំនួយគាំទ្រពីដៃគូអភិវឌ្ឍន៍នានាផង បានផ្តល់ជំនួយបច្ចេកទេសខាងការដាំស្រូវ ជលផល (វារីវប្បកម្ម) និងផលិតកម្មសត្វចិញ្ចឹម និង បានបន្តកិច្ចខំប្រឹងប្រែងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រដើម្បីកាត់បន្ថយការពឹងផ្អែករបស់កសិករទៅលើទឹកភ្លៀង ជាពិសេសក្នុងការដាំស្រូវ និងបង្កើនភាពធន់ទ្រាំនឹងការប៉ះទង្គិចពីបម្រែបម្រួលអាកាសធាតុ។

ដោយសារកសិកម្មជាវិស័យចម្បងដែលជម្រុញកំណើនសេដ្ឋកិច្ចកម្ពុជា ដូច្នេះក៏មានការបង្កើតយន្តការទីផ្សារមួយឡើងដើម្បីលើកកម្ពស់ពាណិជ្ជកម្ម និងតម្រែតម្រង់ឲ្យផលិតផលកសិកម្មហូរចូលទីផ្សារជាតិ និងអន្តរជាតិ ។ ដើម្បីលើកកម្ពស់កម្លាំងប្រកួតប្រជែងនៃវិស័យកសិកម្ម កន្លងមកមានការកែសម្រួលច្បាប់និងបទញ្ញត្តិ និងការកាត់បន្ថយបែបបទការិយាធិបតេយ្យ និងបន្ទុកចំណាយក្នុងការធ្វើពាណិជ្ជកម្ម។ ការទាក់ទាញវិនិយោគឲ្យចូលមកក្នុងវិស័យថាមពលក៏មានអាទិភាពខ្ពស់ដែរ ពីព្រោះ អគ្គិសនីនៅប្រទេសកម្ពុជា នៅថ្លៃខ្ពស់ជាខ្លាំង បើធៀបនឹងប្រទេសឯទៀតក្នុងតំបន់។

ទោះបីមានការយកចិត្តទុកដាក់កាន់តែខ្លាំងពីសំណាក់វិនិយោគិនមកពីប្រទេសដូចជា ថៃ ចិន វៀតណាម កូរ៉េ សិង្ហបុរី ជប៉ុន ម៉ាឡេស៊ី កាណាដា សហរដ្ឋអាមេរិក តណ្ហៅ បារាំង អង់គ្លេស និង ដាណឺម៉ាក ក្តី ក៏វិនិយោគខាងកសិកម្មនៅមានចំណែកតូចត្រឹម ៦%នៃវិនិយោគសរុបប៉ុណ្ណោះ ពីឆ្នាំ២០០០ ដល់ ខែមិថុនា ២០១០។ វិនិយោគិនចូលរួមជាចម្បងក្នុងផ្នែកដំណាំ ដូចជា កៅស៊ូ ដំឡូងឈើ ពោត អំពៅ និងស្វាយចន្ទី និងក្នុងផ្នែកព្រៃឈើ ដូចជា ដើមម៉ៃសាក់ និងអាកាស្យា។ កំណើនការយកចិត្តទុកដាក់ជាខ្លាំងក្នុងពេលប៉ុន្មានឆ្នាំថ្មីៗ បានបង្កក្តីបារម្ភពីសំណាក់អ្នកពាក់ព័ន្ធនានា ចំពោះ ឥទ្ធិពលនៃគម្រោង ELC របស់បរទេស ទៅលើជីវភាពរស់នៅក្នុងសហគមន៍ គុណភាពបរិស្ថាននៅ មូលដ្ឋាន និង សន្តិសុខស្បៀងក្នុងប្រទេស។

ការពិនិត្យជាដំបូងៗដោយប្រើទិន្នន័យបានពីCDC និងMAFF បានបង្ហាញទាំងពីរឥទ្ធិពលល្អនិងឥទ្ធិពលអាក្រក់នៃគម្រោង FDI ។ គម្រោងមួយចំនួនបានបង្កើតឱកាសការងារយ៉ាងច្រើនសម្រាប់ សហគមន៍មូលដ្ឋាន ប៉ុន្តែគម្រោងខ្លះ

ទៀតគ្មានបង្កើតទេ។ដោយឡែកទំនាស់ដីធ្លីដែលភាគច្រើនកើតចេញពីប្រព័ន្ធសិទ្ធិកាន់កាប់ដីធ្លីមានលក្ខណៈអន់ខ្សោយ និង ការពិគ្រោះតិចតួចជាមួយសហគមន៍ មូលដ្ឋានមុនពេលផ្តល់គម្រោង ELC ឃើញមានច្រើនពាសពេញ។ ម្យ៉ាងទៀត គម្រោងមួយចំនួនដែលមានការកាប់បំផ្លាញព្រៃឈើ បានលុបបំបាត់ប្រភពចំណូលជាប្រពៃណីរបស់សហគមន៍ ពោលគឺ ការប្រមូលអនុផលព្រៃឈើ ដូចជា វល្លិ៍ ជ័រឈើ ឫស្សីនិងផ្តៅ និងការប្រមាញ់។ លើសពីនេះទៀត ការចាក់ដីបំពេញជ្រោះអូរដោយគម្រោងមួយចំនួន វាអាចបង្កកង្វះខាតទឹក។ សរុបមក គម្រោង FDI នានា ហាក់ដូចមានបន្ទុកចំណាយ ធំជាងផលចំណេញ។

ដោយសារប្រជាជនកើន ហើយដីធ្លីក៏កាន់តែខ្វះខាតទៅ នៅកម្ពុជាក៏ផុសចេញក្តីបារម្ភមួយពីបញ្ហាសន្តិសុខស្បៀង។ តាមការវិភាគលើទិន្នន័យវិនិយោគបានពី CDC (2000-09) និង ទិន្និន័យវិនិយោគលើគម្រោង ELC បានពី MAFF រួមទាំងការចុះប្រមូលទិន្នន័យដល់កន្លែងជាដំបូងៗលើគម្រោង FDI មួយចំនួនផង ការសិក្សានេះបានរកឃើញថា ទោះបីមាន ការនាំចេញស្រូវក្រៅផ្លូវការជាប្រពៃណី និងជាច្រើនទៅប្រទេសថៃ និងវៀតណាមក្តី ក៏កម្ពុជានឹងមិនជួបអសន្តិសុខស្បៀងទេ ក្នុងរយៈពេលខ្លី និងមធ្យម។ ប៉ុន្តែក្នុងរយៈពេលវែង ទំនាស់លើការប្រើប្រាស់ដីនិងទឹក កង្វះទឹក និង ការបាត់បង់ប្រភពចំណូលជាប្រពៃណី ដែលទាំងអស់នេះផុសចេញពី ការរីកលូតលាស់វិនិយោគជាខ្លាំងក្នុងប៉ុន្មានឆ្នាំថ្មីៗលើ ELC វាអាចនាំឲ្យមានការថយចុះរបបហូបចុកក្នុងគ្រួសារ និងការថយចុះកម្រិតអាហារូបបត្ថម្ភ។ ប្រជាជនងាយរងគ្រោះជាងគេ គឺគ្រួសារធ្វើកសិកម្មបានត្រឹមមួយរស់ និងអ្នកដែលមិនអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់មកពីការដាំដុះស្រូវ ដូចជានៅភូមិក្រយា ក្នុងខេត្តកំពង់ធំ ជាដើម។

# ៧

# អនុសាសន៍ខាងគោលនយោបាយ

ដើម្បីធានាឲ្យឱកាសសម្រាប់វិនិយោគបរទេសខាងកសិកម្មនៅកម្ពុជាមាននិរន្តរភាព និងផ្តល់អត្ថប្រយោជន៍ដល់គ្រប់គ្នា រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានាគួរពិចារណាអនុវត្តវិធានការដូចរៀបរាប់នៅខាងក្រោម៖

## ៧.១. រដ្ឋាភិបាលមជ្ឈឹម និងមូលដ្ឋាន

- ការវាយតម្លៃផលប៉ះពាល់បរិស្ថានគួរធ្វើឡើង ដោយមានការចូលរួមធំទូលាយពីអ្នកពាក់ព័ន្ធនានា ជាពិសេសបណ្តាសហគមន៍ស្ថិតនៅជិតកន្លែងគម្រោង នៅមុនពេលផ្តល់ការយល់ព្រមដល់ ELC។ នៅពេលវាយតម្លៃផលប៉ះពាល់កាន់តែអនុវត្តបានល្អអាចទុកចិត្តបាន និងមានតម្លាភាព ចំនួននិងទំហំនៃវិវាទដីធ្លីពិតជានឹងថយចុះ។
- ដើម្បីចៀសវាងវិវាទដីធ្លី និងការទាមទារកម្មសិទ្ធិត្រួតគ្នា MAFF និងស្ថាប័នជាប់ទាក់ទងនានា គួរកំណត់ព្រំដែន ELC ឲ្យច្បាស់ ដោយពិគ្រោះយោបល់ជាមួយសហគមន៍នៅជាប់នោះផង។
- រដ្ឋាភិបាលគួរពិនិត្យតាមដានប្រតិបត្តិការរបស់ ELC ឲ្យកាន់តែជិតដល់ថែមទៀត ដើម្បីទប់ស្កាត់របៀបអនុវត្តកាប់រានព្រៃមិនល្អ និងសកម្មភាពផ្សេងទៀត ដូចជា ការចាក់ដីបំពេញប្រភពទឹកក្នុងតំបន់នៅខ្សែទឹកខាងលើ និងការកាប់ឈើច្រើនហួសពេក។
- អាជ្ញាធរទាំងនៅកម្រិតមជ្ឈឹម និងកម្រិតខេត្ត គួរធ្វើការពិគ្រោះយោបល់ជារឿយៗជាមួយសហគមន៍នានា និងក្រុមហ៊ុន ដើម្បីទប់ស្កាត់បញ្ហាជាមុន។
- MAFF គួរធ្វើបច្ចុប្បន្នភាពឲ្យបានទៀងទាត់ និងផ្សព្វផ្សាយនៅលើវេបសាយរបស់ខ្លួន និងនៅក្នុងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ អំពីការជឿនលឿនក្នុងប្រតិបត្តិការនៃ ELCs ដើម្បីញ៉ាំងឲ្យមានតម្លាភាព និងទំនុកចិត្តកាន់តែច្រើន។
- ក្នុងការអនុម័តលើ ELCs រដ្ឋាភិបាលគួរយកចិត្តទុកដាក់ខ្លាំងថែមទៀតអំពីសន្តិសុខស្បៀង ដើម្បីចៀសវាងបញ្ហាប្រជែងគ្នាប្រើប្រាស់ដីរវាងផលិតកម្មដំណាំឧស្សាហកម្មសម្រាប់នាំចេញ ហើយនិងផលិតកម្មស្រូវអង្ករសម្រាប់ការហូបចុកក្នុងស្រុក។
- ទាក់ទិននឹងសន្តិសុខស្បៀងដែរ រដ្ឋាភិបាលគួរសើរើពិនិត្យឡើងវិញនូវគោលនយោបាយរួមស្តីពីវិនិយោគខាងកសិកម្ម ជាពិសេស គោលនយោបាយពាក់ព័ន្ធនឹង ELCs ដែលកើនឡើងជាខ្លាំងនាពេលថ្មីៗ ដើម្បីធានាថា គោលនយោបាយពាណិជ្ជកម្មមិនមែនផ្តោតតែលើការស្វែងរកចំណូលរូបិយប័ណ្ណនោះទេ។
- ដើម្បីកាត់បន្ថយទំនាស់ដីធ្លី និងធានាឲ្យបានអត្ថប្រយោជន៍ពីវិនិយោគខ្នាតធំខាងកសិកម្ម ទាំងពីប្រភពក្នុងស្រុក និងបរទេស រដ្ឋាភិបាលត្រូវចាត់វិធានការយ៉ាងលឿន និងប្រយ័ត្នប្រយែង ផ្តល់ប័ណ្ណកម្មសិទ្ធិមានសុវត្ថិភាពនិងអស់សោហ៊ុយតិចដល់បណ្តាសហគមន៍មូលដ្ឋាន ដោយផ្តល់អាទិភាពខ្ពស់ដល់សហគមន៍ណាដែលត្រូវប៉ះពាល់ក្នុងពេលឆាប់ៗដោយគម្រោងវិនិយោគ។
- វិធាន និងបទបញ្ញត្តិផ្សេងៗនាអនាគត គួរផ្តោតកាន់តែខ្លាំងលើការការពារសហគមន៍មូលដ្ឋាន ដោយធ្វើការវាយតម្លៃពីផលប៉ះពាល់ខាងសង្គមកិច្ចនៅមុនពេលអនុម័តគម្រោង ហើយវិធាន និងបទបញ្ញត្តិទាំងនេះត្រូវរលូនគ្នាជាមួយបទបញ្ញត្តិស្តីពីការការពារវិនិយោគិន។

- ការលុបបំបាត់ប្រាក់កម្រៃក្រៅផ្លូវការ និងការដាក់ដំណើរការប្រព័ន្ធកុំព្យូទ័រសម្រាប់ចាត់ចែងលើ ពាក្យសុំធ្វើវិនិយោគ ពាក្យសុំអាជ្ញាប័ណ្ណធ្វើអាជីវកម្ម និង នីតិវិធីរដ្ឋបាលផ្សេងៗ គឺសំខាន់បំផុតដើម្បីកែលំអបរិយាកាសវិនិយោគ ហើយការងារនេះគួរធ្វើជាជំហានៗ ឬក៏ មួយក្រសួងម្តងៗ។
- យន្តការដោះស្រាយវិវាទគួរសើរើពិនិត្យឡើងវិញ ដើម្បីកសាងទំនុកចិត្តក្នុងចំណោមសហគ្រាសឯកជន។
- ក្រសួងនានាគួរបង្កើតជា នាយកដ្ឋានមួយសម្រាប់ផ្តល់ការណែនាំច្បាស់លាស់ និងការគាំទ្រដល់វិនិយោគិន នៅពេលពួកគេមានតម្រូវការ និងទទួលយកព័ត៌មានត្រឡប់។

## ៧.២. ក្រុមហ៊ុនឯកជន

- អ្នកទទួលបាន ELC គួរមានតម្លាភាព និងគណនេយ្យភាពចំពោះសហគមន៍នៅជិតខាង និងសាធារណជន ដោយចូលរួមវិភាគទានដល់ការអភិវឌ្ឍ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធនៅតាមមូលដ្ឋាន។
- ក្រុមហ៊ុននានា គួរមានការប្រាស្រ័យទាក់ទងល្អដោយផ្ទាល់ និងជារឿយៗ ជាមួយសហគមន៍មូលដ្ឋាន ដូចជា តាមរយៈពិធីបុណ្យផ្សេងៗក្នុងសហគមន៍។
- ការដោះស្រាយទំនាស់ ដូចជាទំនាស់ដីធ្លីជាដើម គួរផ្តែកលើវិធីសាស្ត្រឈ្នះឈ្នះ ដូចជាតាមគំរូអនុវត្តក្នុងគម្រោងចំការកៅស៊ូរបស់ក្រុមហ៊ុន DAK LAK ក្នុងខេត្តមណ្ឌលគិរី ជាដើម។
- ក្រុមហ៊ុននានា ELCs និងជាពិសេស រោងចក្រកែច្នៃផ្សេងៗ គួរមានការទទួលខុសត្រូវខ្ពស់ជួយថែរក្សាគុណភាពបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី ក្នុងតំបន់នៃគម្រោងរបស់ខ្លួន។
- សារធាតុគីមីផ្សេងៗដែលប្រើក្នុងរោងចក្រ គួរគោរពតាមបទបញ្ញត្តិខាងបរិស្ថាន ដើម្បីការពារមនុស្ស និងសត្វ ពីការបំពុលផ្សេងៗ និងការខូចគុណភាពប្រភពទឹក។

## ៧.៣. សហគមន៍រងការប៉ះពាល់

- សហគមន៍នានាគួរមានការប្រាស្រ័យទាក់ទងល្អ ដោយផ្ទាល់ និងជារឿយៗជាមួយក្រុមហ៊ុន តាមរយៈពិធីបុណ្យក្នុងសហគមន៍ និងការជួបជុំផ្សេងៗ។
- សហគមន៍នានាគួរចូលរួមឲ្យបានកាន់តែច្រើនក្នុង កម្មវិធីអប់រំផ្សេងៗផ្តល់ឡើងដោយរដ្ឋាភិបាល និង NGOs និងពាក់ព័ន្ធដល់សិទ្ធិលើទ្រព្យសម្បត្តិ និងវិធីដោះស្រាយទំនាស់ដីធ្លី។
- សហគមន៍នានាគួររាយការណ៍ភ្លាមទៅអាជ្ញាធរឃុំ ឬខេត្ត អំពីប្រតិបត្តិការមិនប្រក្រតីផ្សេងៗរបស់ក្រុមហ៊ុន ELC ដូចជាការចាក់ដីបំពេញជ្រោះអូរ ឬ ការកាប់ឈើច្រើនពេក ជាដើម។

## ៧.៤. អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល

- អង្គការមិនមែនរដ្ឋាភិបាល(NGOs) ក្នុងស្រុក គួរជួយបង្កើនចំណាប់អារម្មណ៍របស់សហគមន៍អំពីសិទ្ធិជាពលរដ្ឋ និងវិធីអនុវត្តសិទ្ធិទាំងនោះ។
- NGOsនៅតាមសហគមន៍គួរតាមដានឲ្យបានដិតដល់នូវទំនាស់ផ្សេងៗដែលអាចកើតឡើងរវាងសហគមន៍មូលដ្ឋាន និងក្រុមហ៊ុន ELC និងប្រមូលសេចក្តីរាយការណ៍ផ្សេងៗដើម្បីផ្តល់ព័ត៌មានដល់សាធារណជន។
- ក្រុមសង្គមស៊ីវិលនានាគួរធ្វើការតស៊ូមតិដើម្បីឲ្យក្រុមហ៊ុននានា និងអាជ្ញាធរមូលដ្ឋានទទួលស្គាល់បានកាន់តែច្រើននូវសិទ្ធិរបស់សហគមន៍។

# ឯកសារយោង


ADB (2009), "Cambodia: Agriculture Sector Development Program," Progress Report on Tranche Release

ADB (2007), "RETA 6091: Capacity Building for Resettlement Risk Management—Cambodia Country Report" (Manila: ADB)

ADB (2003), "Report and Recommendation of the President to the Board of Directors on Proposed Loans and Technical Assistance Grant to the Kingdom of Cambodia for the Agriculture Sector Development Program" (Manila: ADB)

Amos, A. Akinola (1986), "Prospects and Problems for Foreign Investment in Nigerian Agriculture," Commonwealth Secretariat (London: UK)

Braun, Joachim & Ruth Meinzen-Dick (2009), "Land Grabbing by Investors in Developing Countries: Risks and Opportunities", Policy Brief 13 (Washington, DC: IFPRI)

CDC (2010), "Cambodian Investment Board: Projects by Sector Approved," (Phnom Penh: CDC)

Clay, Jason (2003), *World Agriculture and the Environment: A Commodity-by-Commodity Guide to Impact and Practices* (Washington, DC: Island Press)

Ear, Sophal (2009), "Sowing and Sewing Growth: The Political Economy of Rice and Garments in Cambodia" (Unpublished)

FAO (2011), "National Fishery Sector Overview: Cambodia", Fishery and Aquaculture Country Profiles, March 2011 (Rome: FAO)

FAO (2010), "Food and Agriculture Organisation's Online Database," (http://faostat.fao.org/site/567/default.aspx#ancor)

FAO, ADB & OIE SEAFMD (2009), "FAO, ADB, OIE SEAFMD Study on Cross-Border Movement and Market Chains of Large Ruminants and Pigs in the Greater Mekong Sub-Region"

GTZ (2009), "Foreign Direction Investment in Land in Developing Countries" (Eschborn: GTZ)

Hansen, K. Kasper & Top Neth (2006), "Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia," (Phnom Penh: CDRI)

Hem Socheth & Tong Kimsun (2010), "Maximising Chinese Investment Opportunity in Cambodia's Natural Resources" (Phnom Penh: CDRI)

IMF (2009), "Cambodia: 2009 Article IV Consultation—Staff Report; Staff Supplement; and Public Information Notice on the Executive Board Discussion," *IMF Country Report No. 09/325* (Washington: IMF)

IMF (2007), "Cambodia: 2007 Article IV Consultation—Staff Report; Staff Supplement; and Public Information Notice on the Executive Board Discussion," *IMF Country Report No. 07/290* (Washington: IMF)

MAFF (2005), "Agricultural Sector Strategic Development Plan, 2006-2010" (Phnom Penh: MAFF)

MAFF (2007), "Agriculture Statistics 2006–2007" (Phnom Penh: MAFF)

MAFF (2008), "Report on the Achievement of the Ministry of Agriculture, Forestry and Fisheries in Implementing the Government's Rectangular Strategy 2004-2007," Report for National Conference on the Progress of the People over various Achievements of Implementation of the Government's Rectangular Strategy 2004-2007 on 29-31 May – 02 June 2008 (Phnom Penh: MAFF)

MAFF (2009), "Annual Report for Agriculture, Forestry and Fisheries 2008–2009" (Phnom Penh: MAFF)

MAFF (2010), "Annual Report for Agriculture, Forestry and Fisheries 2009–2010 and Goals 2010–2011" (Phnom Penh: MAFF)

Mihalache-O'Keef, Andrea & Quan Li (2010), "Modernization vs. Dependency Revisited: Effects of Foreign Direct Investment on Food Security in Less Developing Countries," Paper for American Political Science Association Meeting 2010, Washington, DC

MoP (2010), "National Strategic Development Plan Update 2009-2013" (Phnom Penh: MoP)

MoP (2006), "National Strategic Development Plan 2006-2010" (Phnom Penh: MoP)

MRB (2010), "Malaysian Rubber Exchange," http://www3.lgm.gov.my/mre/MonthlyPrices.aspx#

Ngo Sothath & Chan Sophal (2010), "Does Large Scale Agricultural Investment Benefit the Poor?" (Phnom Penh: CEA)

Rostow, Walt Whitman (1960), *The Stage of Economic Growth: A Non-Communist Manifesto* (Cambridge: Cambridge University Press)

Smaller, Carin & Howard Mann (2009), "A Thirst for Distant Lands: Foreign Investment in Agricultural Land and Water" (Manitoba: IISD)

SOFRECO & CEDAC (2005), "Study on the Evolution of the Cambodian Rubber Sector," Draft report. Clichy-Cedex France and Phnom Penh

Stockbridge, Michael (2006), "Competitive Commercial Agriculture in Africa: Environmental Impacts" (Rome: FAO)

Tasker, P. (2003), *A Review of the Current Status of the State Owned Rubber Estates in Cambodia*, Agriculture Sector Development Programme Appraisal (Phnom Penh: ADB)

Todaro, Michael P. & Stephen C. Smith (2003), Economic Development (Edinburgh: Pearson Education Limited)

UNDP (2007), "Cambodia's 2007 Trade Integration Strategy: Executive Summary and Action Matrix" (Phnom Penh: UNDP)

Vermeulen, Sonja & Lorenzo Cotula (2010), "Making the Most of Agricultural Investment: A Survey of Business Models that Provide Opportunities for Smallholders" (London: IIED)

World Bank (2004a), "Cambodia at the Crossroads: Strengthening Accountability to Reduce Poverty" (Phnom Penh: World Bank)

World Bank (2004b), "Seizing Global Opportunity: Investment Climate Assessment and Reform Strategy for Cambodia" (Phnom Penh: World Bank)

World Bank (2006), "Halving Poverty by 2015? Poverty Assessment 2006" (Phnom Penh: World Bank)

World Bank (2009), "Sustaining Rapid Growth in a Challenging Environment", Cambodia Country Economic Memorandum (Phnom Penh: World Bank)

Yang, Lina (ed.) (2011), "Cambodian PM sacks fishery chiefs in 5 provinces", Xinhua News Agency (http://news.xinhuanet.com/english2010/world/2011-07/01/c_13961037.htm)

# ឧបសម្ព័ន្ធ ១៖ តារាងបន្ថែម

តារាង ក ១៖ បញ្ជីលំអិតពី ELCs ទទួលបានពី MAFF ១៩៩៥-២០០៩

| ឈ្មោះ | ខេត្ត | សញ្ជាតិ | ឆ្នាំនៃការអនុម័ត | ទំហំ (ហិកតា) | គោលបំណងនៃការវិនិយោគ | ស្ថានភាព |
|---|---|---|---|---|---|---|
| Cambodia Eversky Agricutural Development | កំពង់ធំ | ខ្មែរ | ២០០៥ | ១០០០០ | ចំការកប្បាស | អសកម្ម |
| An Mardy Group | កំពង់ធំ | ខ្មែរ | ២០០៥ | ៩៨៦៣ | កសិឧស្សាហកម្ម និងការចិញ្ចឹមសត្វ | សកម្ម |
| Mean Rithy | កំពង់ធំ | ខ្មែរ | ២០០៦ | ៩៧៨៤ | កសិឧស្សាហកម្ម | សកម្ម |
| HMH | កំពង់ធំ | ខ្មែរ | ២០០៦ | ៥៩១៤ | ចំការអាកាស្យា និងដើមឈើផ្សេងៗ | សកម្ម |
| Tan Bien-Kompong Thom Rubber Development | កំពង់ធំ | វៀតណាម | ២០០៧ | ៨១០០ | ចំការកៅស៊ូ និងការកែច្នៃ | សកម្ម |
| Gold Foison ( Cambodia ) A/C Import Export & Construction | កំពង់ធំ | ចិន | ២០០៧ | ៧០០០ | ចំការអាកាស្យា និងការកែច្នៃ | សកម្ម |
| BNA ( Cam ) Corp | កំពង់ធំ | កូរ៉េ | ២០០៩ | ៧៥០០ | ចំការកៅស៊ូ និងដំឡូងឈើ | សកម្ម |
| CAMLAND | កំពត | ខ្មែរ | ២០០០ | ១៦០០០ | ប្រេងត្នោត | សកម្ម |
| World Tristar Entertainment ( Cambodia ) | កំពត | ខ្មែរ | ២០០៥ | ៩៨០០ | ចំការពោត និងរោងចក្រកែច្នៃ | សកម្ម |
| First Bio-Tech Agricultural ( Cambodia ) | កំពត | ខ្មែរ | ២០០៥ | ១០០០០ | កសិឧស្សាហកម្ម និងការចិញ្ចឹមសត្វ | សកម្ម |
| Crystal Agro | ឧត្តរមានជ័យ | ថៃ | ២០០៦ | ៨០០០ | ចំការដំឡូងឈើ និងកសិឧស្សាហកម្ម | សកម្ម |
| Tonle Sugarcane | ឧត្តរមានជ័យ | ថៃ | ២០០៨ | ៦៦១៨ | ចំការអំពៅ និងការកែច្នៃ | សកម្ម |
| ( Cambodia ) Cane and Sugar Valley | ឧត្តរមានជ័យ | ថៃ | ២០០៨ | ៦៥៩៥ | ចំការអំពៅ និងការកែច្នៃ | សកម្ម |
| Angkor Sugar | ឧត្តរមានជ័យ | ថៃ | ២០០៨ | ៦៥២៣ | ចំការអំពៅ និងការកែច្នៃ | សកម្ម |
| LEANG HOUR HONG Import and Export | បាត់ដំបង | ខ្មែរ | ២០០០ | ៨០០០ | ចំការអំពៅ និងដំឡូងឈើ | សកម្ម |
| Rath Sambath | បាត់ដំបង | ខ្មែរ | ២០០៩ | ៥២០០ | ចំការកៅស៊ូ | សកម្ម |
| AGRO STAR Investment | កំពង់ចាម | ខ្មែរ | ១៩៩៦ | ២៤០០ | ដំណាំហូបផ្លែ និងការចិញ្ចឹមសត្វ | សកម្ម |
| TTY Industrial Crops Deveopment Import-Export | កំពង់ចាម | ខ្មែរ | ២០០០ | ១០៧០ | ចំការដំឡូងឈើ | សកម្ម |
| VANNMA Import-Export | កំពង់ចាម | ខ្មែរ | ២០០៤ | ១២០០ | ចំការអំពៅ និងដំឡូងឈើ | សកម្ម |
| Mieng Ly Heng Investment | កំពង់ចាម | ខ្មែរ | ២០០៥ | ៣០០០ | ចំការកៅស៊ូ Para | សកម្ម |
| Men Sarun Import-Export | កំពង់ចាម | ខ្មែរ | ២០០៦ | ៤៤០០ | ចំការកៅស៊ូ និងដំណាំផ្សេងៗ | សកម្ម |
| Phea Phimex | កំពង់ឆ្នាំង | ខ្មែរ | ២០០០ | ៣១៥០២៨ | ចំការដំណាំ និងរោងចក្រម្រេច | សកម្ម |
| The Cambodia Haining | កំពង់ស្ពឺ | ចិន | ១៩៩៨ | ២៣០០០ | កសិឧស្សាហកម្ម និងការកែច្នៃ | អសកម្ម |
| Cambo Victor Investment and Development | កំពង់ស្ពឺ | ចិន | ១៩៩៨ | ២៨៥០០ | ពោត សណ្តែក សណ្តែកសៀង ស្រូវ ដំឡូងឈើ | អសកម្ម |

